# ព្រះពុទ្ធ
# ពុទ្ធប្រវត្តិ និង ពុទ្ធវចនៈ

*The Buddha, His Life and Teachings*




ព្រះមហាថេរ បិយទស្សី

Piyadassī Thera

បកប្រែដោយ

ថ្នាក់សិក្សាពុទ្ធសាសនាជាភាសាអង់គ្លេស

បង្រៀនដោយ ភិក្ខុ មុនីបុត្តោ សុខ ធារី



ព.ស. ២៥៦៧ គ.ស. ២០២៣

# ព្រះពុទ្ធ ពុទ្ធប្រវត្តិ និង ពុទ្ធវចនៈ

## The Buddha, His Life and Teachings

## ភាសាអង់គ្លេស និង ភាសាខ្មែរ

ជំនួយដល់សិក្ខាកាមសិក្សាពុទ្ធសាសនាជាភាសាអង់គ្លេស


## វិទ្យាស្ថានធម្មិកៈអន្តរជាតិ

Dhammika Academy International

ថ្នាក់សិក្សាពុទ្ធសាសនាជាភាសាអង់គ្លេស (២០២០)

បង្រៀនដោយៈ ភិក្ខុ មុនីបុត្តោ សុខ ធាវី (Ven. Sok Theavy)

(គង់នៅវត្តខ្មែរហាវ៉ៃ រដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក)


ព.ស. ២៥៦៧ គ.ស. ២០២៣

| | |
|---|---|
| ឈ្មោះសៀវភៅ | **ព្រះពុទ្ធ ពុទ្ធប្រវត្តិ និង ពុទ្ធវចនៈ** |
| | (The Buddha, His Life and Teachings) |
| និពន្ធដោយ | ព្រះមហាថេរៈ បិយទស្សី (Piyadassī Thera) |
| បកប្រែជាភាសាខ្មែរ | ថ្នាក់សិក្សាពុទ្ធសាសនាជាភាសាអង់គ្លេស |
| | DAI-Buddhism in English |
| បង្រៀនដោយ | ភិក្ខុ មុនីបុត្តោ សុខ ធារី (រដ្ឋហាវ៉ៃ) |
| កត់ត្រាភាសាខ្មែរ | ឧបាសិកា ប៉េង សុវណ្ណា (រដ្ឋតិចសាស) |
| កត់ត្រាភាសាអង់គ្លេស | ឧទ្ទេសាចារ្យ ប៉ូ ពិសិដ្ឋ (រដ្ឋលូវីសៀណា) |
| រចនាក្រប | ឧបាសិកា ព្រុំ ចិន្តា (ក្រុងភ្នំពេញ) |
| ពិនិត្យអក្ខរាវិរុទ្ធ | សុខ ធារី, គង់ ប្រុស, ប៉ូ ពិសិដ្ឋ, ហ៊ីន គន្ធា, ចក់ សុភាព |
| បោះពុម្ពលើកទី១ | ចំនួន ១០០០ ពាន់ច្បាប់ សម្រាប់ចែកធម្មទាន |
| ការផ្សាយរបស់ | វិទ្យាស្ថានធម្មិកៈអន្តរជាតិ |
| ផ្សាយចេញពី | វត្តខ្មែរហាវ៉ៃ កោះធំ រដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក |
| ចេញផ្សាយ | ព.ស. ២៥៦៧ គ.ស. ២០២៣ |
| លេខសម្គាល់ | ISBN-13: 978-9924-9406-1-6 |

# Contents មាតិកា page


| | | | |
|---|---|---|---|
| | អារម្ភកថាអ្នកបកប្រែ | | 5 |
| | របៀបប្រើសៀវភៅនេះ | | 8 |
| 1. | The Buddha: Introduction | ព្រះពុទ្ធ÷ សេចក្តីផ្តើម | 9,12 |
| 2. | The Birth | ការប្រសូតិ | 14,17 |
| 3. | The Four Significant Visions | ទេវទូត (និមិត្ត) ៤ | 19,22 |
| 4. | The Great Renunciation | អភិនេស្ក្រម៍ | 25,28 |
| 5. | Self-mortification | ទុក្ករកិរិយា | 31,34 |
| 6. | The Final Triumph | ជ័យជម្នះចុងក្រោយ | 36,42 |
| 7. | Misconceptions | ការភ័ន្តច្រឡំ | 47,51 |
| 8. | Dependent Arising | បដិច្ចសមុប្បាទ | 55,58 |
| 9. | The First Sermon | បឋមទេសនា | 60,64 |
| 10. | The Middle Path | មជ្ឈិមាបដិបទា | 68,71 |
| 11. | The Siṃsapā Grove | សឹសបាវ័ន (ព្រៃឆ្លង់) | 73,76 |
| 12. | The Peerless Physician | គ្រូពេទ្យគ្មានគូប្រៀប | 78,80 |
| 13. | The Spread of the Dhamma | ការផ្សព្វផ្សាយព្រះធម៌ | 81,84 |
| 14. | The Buddha‟s Ministry | ពុទ្ធកិច្ច | 86,93 |
| 15. | Buddhahood & Arahatship | ពុទ្ធភាវៈ និងអរហត្តភាវៈ | 99,101 |
| 16. | Salient Features of the Dhamma | លក្ខណៈពិសេសនៃព្រះធម៌ | 103,108 |
| 17. | True Purification | សេចក្តីបរិសុទ្ធពិតប្រាកដ | 112,114 |
| 18. | Caste Problem | បញ្ហាវណ្ណៈ | 116,119 |
| 19. | Chief Disciples | អគ្គសាវ័ក | 122,126 |
| 20. | The Order of Nuns | ភិក្ខុនីសង្ឃ | 129,131 |

| | | |
|---|---|---|
| 21. At Kapilavatthu | នៅនគរកបិលវត្ថុ | 132,135 |
| 22. Women in Buddhism | ស្ត្រីក្នុងព្រះពុទ្ធសាសនា | 138,140 |
| 23. Ministering to the Sick | ការជួយផ្គត់ផ្គង់អ្នកជំងឺ | 141,144 |
| 24. Equanimity and Self-composure | ឧបេក្ខា និងលំនឹងចិត្ត | 146,148 |
| 25. Devadatta | ភិក្ខុទេវទត្ត | 150,153 |
| 26. The Last Days | សម័យចុងក្រោយ | 155,159 |
| 27. The Last Convert | បច្ឆិមសាវ័ក | 162,165 |
| 28. The Last Scene | ព្រឹត្តិការណ៍ចុងក្រោយ | 167,171 |
| Dornor‟s Name List | នាមសប្បុរសជនបោះពុម្ពសៀវភៅ | 174 |
| ប្រវត្តិសង្ខេបអ្នកបកប្រែ | | 176 |
| ប្រវត្តិសង្ខេបវិទ្យាស្ថានធម្មិកៈអន្តរជាតិ (វ.ធ.អ) | | 176 |
| About Dhammika Academy International (DAI) | | 179 |

# អារម្ភកថាអ្នកបកប្រែ

សៀវភៅនេះ កើតចេញពី **ថ្នាក់សិក្សាពុទ្ធសាសនាជាភាសាអង់គ្លេស** (អនឡាញ) ដែលបានបង្រៀនដោយខ្ញុំព្រះករុណាអាត្មាភាព **មុនីបុរ្តោ សុខ ឆាវី** កាលពីឆ្នាំ ២០២០ កន្លងទៅ។ ទោះបីជាថ្នាក់សិក្សាបានបញ្ចប់ទៅជាង ៣ ឆ្នាំហើយមែន តែទើបសម្រេចចិត្តរៀបចំបោះពុម្ពសម្រាប់ចែកជាធម្មទាននៅចុងឆ្នាំ ២០២៣ នេះប៉ុណ្ណោះ អាស្រ័យដោយមានការចំណាយពេលច្រើនទៅលើ ការវាយកុំព្យូទ័រជាភាសាអង់គ្លេស ទាំងស្រុង ការផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ និងការសម្រួលខ្លឹមសារបកប្រែជាភាសាខ្មែរជាដើម។ ទោះបីយ៉ាងណាក៏ដោយ សិក្ខាកាមដែលបានសិក្សាក្នុងថ្នាក់ **ព្រះពុទ្ធ ពុទ្ធប្រវត្តិ និងពុទ្ធវចនៈ** ពិតជាចង់ឃើញសៀវភៅនេះបោះពុម្ពចេញមកដើម្បីចែកជាធម្មទាន ដោយជឿជាក់ថា វានឹងបានជាប្រយោជន៍យ៉ាងច្រើនដល់ពុទ្ធសាសនិកសកលទូទៅ។ ខ្ញុំព្រះករុណាអាត្មាភាព ក្នុងនាមជាអ្នកដែលចូលចិត្តបង្រៀនធម៌ ជាភាសាអង់គ្លេសផ្ទាល់យល់ឃើញថា សៀវភៅនេះពិតជាចាំបាច់បំផុតសម្រាប់អ្នកចង់សិក្សា **ព្រះពុទ្ធសាសនាជាភាសាអង់គ្លេស** ក្នុងគោលបំណងជាធម្មទូត ឬដើម្បីផ្សព្វផ្សាយព្រះធម៌ដល់ជនបរទេសក្តី។ មួយវិញទៀត សៀវភៅនេះ ពិតជាមានប្រយោជន៍ណាស់សម្រាប់កូនខ្មែរកើតនៅបរទេស ដែលចង់អានព្រះធម៌ជាភាសាអង់គ្លេស ហើយអមដោយការបកប្រែជាភាសាខ្មែរផង អាចជួយសម្រួលដល់ការស្វែងយល់របស់ពួកគេបន្ថែម។ ដោយមានការសំណូមពរពីសំណាក់ មាតាបិតាដែលរស់នៅក្នុងសហរដ្ឋអាមេរិកយោងតាម ហេតុផលខាងលើនេះ កាន់តែជម្រុញ ទឹកចិត្តឱ្យខ្ញុំខិតខំប្រឹងប្រែងធ្វើសៀវភៅនេះ ឡើងដើម្បីជាប្រយោជន៍ដល់សាធារណជនទូទៅ។

ត្រង់នេះសូមទាញស្មារតីមិត្តអ្នកអាន អ្នកសិក្សាទាំងឡាយថា សៀវភៅនេះបានបកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរ ដូច្នេះខ្លឹមសារ និងសេចក្តីទាំងស្រុងគឺផ្តោតសំខាន់ទៅតាមសំណេរភាសាអង់គ្លេសដែលជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់។

សូមកុំប្រៀបធៀបខ្លឹមសារនៃសេចក្តីបកប្រែនេះជាមួយព្រះត្រៃបិដកខ្មែរ ព្រោះថាសៀវភៅនេះ គឺជាការបរិយាយនូវដំណើរជីវិតនៃព្រះសម្មាសម្ពុទ្ធ ចាប់តាំងពីប្រសូតិ

រហូតទល់បរិនិព្វាន ដោយការលើកយកខ្លឹមសារផ្នែកតាមព្រះត្រៃបិដកបាលីផង និងបូក បញ្ចូលដោយការវិភាគ និងពន្យល់របស់អ្នកនិពន្ធផ្ទាល់តែម្តង។ ការបកប្រែរបស់ខ្ញុំ គឺរក្សា ខ្លឹមសារដែលជាកម្មសិទ្ធិ បញ្ញារបស់អ្នកនិពន្ធ។ ហើយការនេះ ក៏សំខាន់សម្រាប់អ្នក ចង់សិក្សាពុទ្ធប្បវត្តិ ជាភាសាខ្មែរផង និងអង់គ្លេសផង។

**ចំណុចពិសេសនៃសៀវភៅពុទ្ធប្បវត្តិ** ដ៏អស្ចារ្យនេះមានដូចខាងក្រោម៖

**១**. អ្នកនិពន្ធ លោកជាសាស្ត្រាចារ្យបានបញ្ចប់ការសិក្សានៅសកលវិទ្យាល័យ Harvard

**២**.លោកជាធម្មកឋិកដ៏ឆ្នើមមួយរូបនៅប្រទេសស្រីលង្កាក្នុងអំឡុងឆ្នាំ ១៩៨០

**៣**.លោកជាធម្មទូតពិសេសផ្សព្វផ្សាយពុទ្ធសាសនាទៅកាន់ប្រទេសជាច្រើន មានប៉ែកបូព៌ាប្រទេស និងបស្ចឹមប្រទេសជាដើម។

**៤**.ការប្រើវោហារសព្ទរបស់លោក ពីរោះរណ្តំ ក្បោះក្បាយ មានលក្ខណៈផ្សារភ្ជាប់ ច្រើនជាមួយសង្គម និងវិទ្យាសាស្ត្រ ធ្វើឱ្យគេឆាប់ងាយយល់ ជាពិសេសសម្រាប់អ្នកប្រាជ្ញ បញ្ញវ័ន្ត និងយុវជនជំនាន់ថ្មីនាសម័យទំនើបភាវូបនីយកម្ម។

**៥**.ការពន្យល់រៀបរាប់មានហេតុផលច្បាស់ៗ អាចញ៉ាំងអ្នកអានឱ្យងាយយល់ និងយកជា គតិសម្រាប់ប្រើប្រាស់គ្រប់វិស័យក្នុងជីវិតរបស់មនុស្សរៀងៗខ្លួន។

**៦**.ការសរសេរភាសាអង់គ្លេសរបស់លោក រាងបុរាណមែន តែមានចម្ងាញ់ ជាពិសេស សម្រាប់អ្នកស្ទាត់ជំនាញភាសាអង់គ្លេសខាងផ្នែកសរសេរបរិយាយរៀបរាប់។

**៧**.សៀវភៅនេះអាចយកមកសិក្សាបាន ទាំងជនជាតិខ្មែរ និងបរទេស ព្រោះពីរភាសា

**៨**.ទាំង ២៨ ប្រធានបទ ដែលបានលើកមកបង្ហាញក្នុងសៀវភៅនេះ សមគួរល្មមអាច ឱ្យអ្នកសិក្សាឈ្វេងយល់បានច្រើន អំពីដំណើរជីវិតរបស់ព្រះពុទ្ធ តាំងពីប្រសូតិ រៀងដរាប ដល់ថ្ងៃចុងក្រោយបំផុតនៃជីវិតរបស់ព្រះអង្គ ជាពិសេសគឺខ្លឹមសារនៃការបង្រៀនរបស់ ព្រះអង្គ ដែលប្រកបដោយអត្ថន័យជ្រាលជ្រៅ មានតម្លៃកាត់ថ្លៃមិនបាន។

ខ្ញុំសូមថ្លែងអំណរគុណដល់ជន ដែលមានឧបការៈច្រើនក្នុងការរៀបចំសៀវភៅ នេះឱ្យចេញជារូបរាងឡើង៖

**១. ឧទ្ទេសាចារ្យ ប៉ូ ពិសិដ្ឋ** ជួយវាយកុំព្យូទ័រជាភាសាអង់គ្លេស

**២. ឧបាសិកា ម៉េង សុវណ្ណា** ជួយវាយកុំព្យូទ័រជាភាសាខ្មែរ

**៣. ឧបាសិកា ហ៊ីន គន្ធា** ពិនិត្យផ្នែកអក្ខរាវិរុទ្ធ

**៤. ឧបាសិកា ចក់ សុភាព** ពិនិត្យផ្នែកអក្ខរាវិរុទ្ធ

**៥. ឧបាសិកា ហ៊ុំ ស្រីពេជ្រ** ពិនិត្យផ្នែកអក្ខរាវិរុទ្ធ

**៦. ភិក្ខុបញ្ញាបទីបោ គង់ ប្រុស** ជួយសម្រួលខាងការបោះពុម្ព និងអក្ខរាវិរុទ្ធ

**៧. អភិធម្មាចរិយានី មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ វណ្ណារី ទេព ប្រណម្យ**

ជួយសម្រួលសុំលេខកូដពីបណ្ណាល័យជាតិកម្ពុជាសម្រាប់ការបោះពុម្ព

**៨.សប្បុរសជនទាំងអស់** ទាំងក្នុងនិងក្រៅប្រទេស ដែលបានចូលរួមថវិកាបោះពុម្ពសៀវភៅនេះ ដូចមានរាយនាមនៅខាងចុងនៃសៀវភៅ។

សូមឱ្យបុណ្យកុសលដែលកើតអំពីធម្មទាននេះ បានជាបច្ច័យធ្វើនូវទីបំផុតទុក្ខក្នុងសង្សារវដ្តនេះ។ សូមឱ្យព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ស្ថិតនៅក្នុងក្រអៅបេះដូងនៃជនានុជនគ្រប់រូប។ សូមឱ្យសព្វសត្វក្នុងពិភពលោកទាំងមូល បានសេចក្ដីសុខសន្តិភាព រួចរដោះចាកទុក្ខផងទាំងពួង។ សូមអនុមោទនា!!!

**វត្តខ្មែរហាវ៉ៃ រដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក**

ថ្ងៃអាទិត្យ ១២កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ត្រូវនឹងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣

**ភិក្ខុ មុនីបុណ្ណោ សុខ ឆាវី**

ព្រះនាយកវិទ្យាស្ថានធម្មិកៈអន្តរជាតិ

# គន្លឹះក្នុងការប្រើសៀវភៅនេះ

សៀវភៅនេះមាន **ពីរភាសា** និង **បីផ្នែក** សំខាន់ៗ ដូចគ្នាគ្រប់ប្រធានបទទាំង ២៨។ ពីរភាសាមានៈ **ភាសាអង់គ្លេស** និង **ភាសាខ្មែរ** រីឯបីផ្នែកគឺដូចនេះ៖

- *ភាសាអង់គ្លេស នៅខាងដើម*
- *វាក្យសព្ទព្រះធម៌ (សម្រង់ពាក្យអង់គ្លេស និងបកប្រែខ្មែរ) នៅកណ្តាល*
- *ភាសាខ្មែរ  នៅខាងចុង*

**ឧទាហរណ៍៖ នៅប្រធានបទដំបូងបង្អស់**

- ✓ **ភាសាអង់គ្លេស៖** **The Buddha, Introduction**
- ✓ **វាក្យសព្ទព្រះធម៌៖** **Dhamma Terminology** វាក្យសព្ទព្រះធម៌
- ✓ **ភាសាខ្មែរ៖** **ព្រះពុទ្ធ**  សេចក្តីផ្តើម

**មូលហេតុនៃការរៀបចំបែបនេះ ៖**

១. ភាសាអង់គ្លេស នៅខាងដើម៖ ដោយសារអត្ថបទដើមជាសៀវភៅអង់គ្លេស

២. វាក្យសព្ទព្រះធម៌ នៅកណ្តាល៖ ព្រោះចង់ឱ្យអ្នកអាន បានសិក្សាវាក្យសព្ទអង់គ្លេសបែបព្រះធម៌ខ្លះ ដែលស្រង់ចេញពីប្រធានបទនីមួយៗ

៣. ភាសាខ្មែរ នៅខាងចុង៖ បើអ្នកបានអានជាភាសាអង់គ្លេសម្តងហើយ ប្រាកដជាអាចចាប់ខ្លឹមសារបានខ្លះជាមិនខាន ដូចនេះនឹងរឹងរឹតតែជាក់ច្បាស់ពេលអ្នកចាប់ផ្តើមអានជាភាសាខ្មែរ។

តាមរបៀបនេះឯង សៀវភៅនេះត្រូវបានរៀបចំឡើងដើម្បីជាជំនួយដល់ការសិក្សាពុទ្ធប្បវត្តិជាភាសាអង់គ្លេស ជាពិសេសសម្រាប់ជនជាតិខ្មែរតែម្តង។

# THE BUDDHA

## Introduction

"The ages roll by and the Buddha seems not so far away after all; his voice whispers in our ears and tells us not to run away from the struggle but, calm-eyed, to face it, and to see in life ever greater opportunities for growth and advancement. Personality counts today as ever, and a person who has impressed himself on the thought of mankind as the Buddha has, so that even today there is something living and vibrant about the thought of him, must have been a wonderful man --a man who was, as Barth says, "the finished model of calm and sweet majesty, of infinite tenderness for all that breathes and compassion for all that suffers, of perfect moral freedom and exemption from every prejudice."

"His message old and yet very new and original for those immersed in metaphysical subtleties, captured the imagination of the intellectuals; it went deep down into the hearts of the people."

Buddhism had its birth at Sarnath near the city of Varanasi (Benares),
India. With only five followers at the beginning, it penetrated into many lands, and is today the religion of more than 600 million.

Buddhism made such rapid strides chiefly due to its intrinsic worth and its appeal to the reasoning mind. But there were other factors that aided its progress: never did the Dhammadūtas, the messengers of the Dhamma, the teaching, use any iniquitous methods in spreading the Dhamma. The only weapon they wielded was that of universal love and compassion.

Furthermore, Buddhism penetrated to these countries peaceably, without disturbing the creeds that were already there. Buddhist missions, to which the annals of religious history scarcely afford a parallel, were carried on neither by force of arms nor by the use of any coercive or reprehensible methods. Conversion by compulsion was unknown among the Buddhists, and repugnant to the Buddha and his disciples. No decrying of other creeds has ever existed in Buddhism. Buddhism

was thus able to diffuse itself through a great variety of cultures throughout the civilized world.

"There is no record known to me," wrote T.W. Rhys Davids,

"In the whole of the long history of Buddhism throughout the many centuries where its followers have been for such lengthened periods supreme, of any persecution by the Buddhists of the followers of any other faith."

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

| | |
|---|---|
| The Buddha | ព្រះពុទ្ធ |
| compassion | ករុណា (សេចក្ដីអាណិតអាសូរចង់ឱ្យអ្នកដទៃបានសុខ) |
| metaphysical subtleties | ទ្រឹស្ដីបរមត្ថវិជ្ជា (ទស្សនវិជ្ជាដែលមានគំនិតល្អិតជ្រៅ) |
| suffer | រងទុក្ខ (suffering សេចក្ដីទុក្ខ) |
| perfect moral freedom | ការរួចរដោះដែលប្រកបដោយធម៌ |
| prejudice | សេចក្ដីលម្អៀង ឬការប្រកាន់ពូជសាសន៍ |
| intellectual | បញ្ញវន្តជន |
| intrinsic worth | គុណតម្លៃខាងក្នុង |
| reasoning mind | សមហេតុផល |
| spreading the Dhamma | ការផ្សព្វផ្សាយធម៌ |
| Buddhism penetrated to | ពុទ្ធសាសនាបានផ្សព្វផ្សាយ ឬជ្រួតជ្រាបទៅកាន់ |
| universal love and compassion | សេចក្ដីស្រឡាញ់ឥតដែនកំណត់ (មេត្តាករុណា) |
| annals of religious history | កំណត់ត្រាប្រចាំឆ្នាំនៃប្រវត្តិសាសនា |
| conversion by compulsion | ការផ្លាស់ប្ដូរសាសនាដោយការបង្ខិតបង្ខំ |
| the followers of any other faith | សាវ័កនៃសាសនាដទៃទៀត |

Dhammadūta, a messenger of the Dhamma ធម្មទូត, អ្នកផ្សព្វផ្សាយធម៌

repugnant ដែលមិនគួរឱ្យចូលចិត្ត/គួរឱ្យស្អប់ខ្ពើម (ក្នុងបរិបទខ្លះប្រែថា បដិឃៈ)

# ព្រះពុទ្ធ

## សេចក្ដីផ្ដើម

"អាយុសង្ខារនៃសព្វសត្វកាន់តែរំកិលទៅមុខ ព្រះពុទ្ធក៏ហាក់ដូចជានៅមិនឆ្ងាយពីយើងឡើយ។ ពុទ្ធដីការហាក់ដូចជានៅខ្សាវៗ ខ្សឹបដាក់ត្រចៀកយើង ប្រាប់យើងកុំឱ្យរត់គេចពីសេចក្ដីព្យាយាមតស៊ូពុះពារ ប៉ុន្តែត្រូវរក្សាលំនឹងចិត្តស្ងប់ស្ងាត់ ប្រឈមមុខនឹងបញ្ហា ហើយមើលឱ្យឃើញថាជីវិតគឺជាឱកាសដ៏ប្រសើរសម្រាប់ការលូតលាស់ និងការអភិវឌ្ឍន៍ខ្លួន។ បុគ្គលិកលក្ខណៈរបស់មនុស្សគឺសំខាន់តាំងពីដើមរៀងមក ហើយបុគ្គលដែលបានធ្វើខ្លួនឱ្យទៅជាមនុស្សមានការចាប់អារម្មណ៍សម្រាប់មនុស្សជាតិ ដូចជាព្រះពុទ្ធ សូម្បីសព្វថ្ងៃនេះ ក៏គង់មានអ្វីមួយនៅរស់រវើកជានិច្ច ជាពិសេសគឺទស្សនៈការបង្រៀនរបស់ព្រះអង្គ (មិនដែលសាបសូន្យទេ)។ ព្រះពុទ្ធគឺពិតជាបុគ្គលមួយអង្គដ៏អស្ចារ្យ បុគ្គលមួយអង្គដែលបានដើរគំរូ ដូចលោក **Barth** បាននិយាយថា "ព្រះពុទ្ធគឺជាកំពូលមនុស្សដែលបានដល់នូវសេចក្ដីស្ងប់ និងមានអានុភាពក្រៃលែង ភាពទន់ភ្លន់ឥតព្រំដែនចំពោះសព្វសត្វដែលមានជីវិត និងសេចក្ដីករុណាយ៉ាងក្រៃលែងដល់សព្វសត្វដែលមានទុក្ខ ជាបុគ្គលបានរួចរដោះប្រកបដោយធម៌ ប្រាសចាកសេចក្ដីលម្អៀង និងការប្រកាន់ពូជសាសន៍ជាដើម"។

"សាររបស់ព្រះពុទ្ធដ្បិតមានវ័យចំណាស់ ប៉ុន្តែនៅថ្មីស្រឡាងជានិច្ច សំរាប់បុគ្គលដែលបានមុជជ្រៅទៅក្នុងទស្សនៈបរមត្ថវិជ្ជា និងបានឆក់យកការស្រមើស្រមៃរបស់បញ្ញាវ័ន្តជនជាច្រើន ឱ្យដក់ជាប់ក្នុងក្រអៅបេះដូងរបស់ពួកគេ"។

ពុទ្ធសាសនាមានដើមកំណើតនៅទីក្រុងសារណាត ជិតពារាណសី នៃប្រទេសឥណ្ឌា។ ការចាប់ផ្ដើមដំបូង មានសាវ័កតែប្រាំអង្គប៉ុណ្ណោះ បន្ទាប់មកក៏បានជ្រួតជ្រាបផ្សព្វផ្សាយទៅក្នុងដែនដីជាច្រើន មកដល់បច្ចុប្បន្នមានអ្នកគោរពរាប់អាន ជាង ៦០០ លាននាក់។

ពុទ្ធសាសនាបានបោះជំហានយ៉ាងលឿនដោយសារគុណតម្លៃរបស់ខ្លួន និងលក្ខណៈសមហេតុផល ប៉ុន្តែនៅមានកត្តាផ្សេងៗទៀតដែលជួយបន្ថែមទៅលើការរីកចម្រើន នៃព្រះពុទ្ធសាសនាដូចជា **ធម្មទូត** ដែលជាអ្នកនាំសារផ្សព្វផ្សាយព្រះធម៌ មិនដែលប្រើវិធីសាស្ត្រអសីលធម៌ណាមួយក្នុងការផ្សព្វផ្សាយព្រះធម៌ឡើយ។ អាវុធដែលធម្មទូតបានប្រើមានតែម្យ៉ាងគត់គឺ **សេចក្ដីស្រឡាញ់ និងមេត្តាករុណាឥតដែនកំណត់។**

លើសពីនេះទៅទៀត ពុទ្ធសាសនាបានផ្សព្វផ្សាយជ្រួតជ្រាបដល់ប្រទេសនានាដោយសន្តិភាព ដោយគ្មានការរំខាន ឬការប្រជែងជាមួយលទ្ធិសាសនាដែលមានស្រាប់នៅក្នុងប្រទេសទាំងនោះឡើយ។ បេសកកម្មរបស់អ្នកកាន់ពុទ្ធសាសនា បើយោងតាមកំណត់ត្រាប្រចាំឆ្នាំនៃប្រវត្តិសាសនា គឺមិនដែលបានប្រើនូវទម្រង់ណាមួយដោយការបង្ខិតបង្ខំ ដោយប្រើអាវុធ ឬដោយប្រើវិធីសាស្ត្របង្គាប់បញ្ជា ឬវិធីសាស្ត្រគួរឱ្យតិះដៀលណាមួយឡើយ។ ការផ្លាស់ប្តូរដោយការបង្ខិតបង្ខំ គឺមិនត្រូវបានទទួលស្គាល់ និងមិនបានជាទីគាប់ព្រះទ័យនៃព្រះពុទ្ធ និងសាវ័កព្រះអង្គឡើយ។ ការបង្ខូចនិងការមួលបង្កាច់សាសនាដទៃមិនដែលមានវត្តមានកើតឡើងនៅក្នុងពុទ្ធសាសនាឡើយ។ ហេតុនេះហើយ ពុទ្ធសាសនាបានបញ្ជ្រាបខ្លួនតាមរយៈវប្បធម៌ដ៏សម្បូរណ៍បែបផ្សេងៗ រហូតបានផ្សាយទៅកាន់អារ្យប្រទេសទំនើបជាច្រើន។

លោកសាស្ត្រាចារ្យ T.W.Rhys Davids បានសរសេរថា "មិនមានកំណត់ត្រាណាមួយដែលខ្ញុំបានដឹងឡើយ" "នៅក្នុងប្រវត្តិសាស្ត្រដ៏យូរលង់នៃពុទ្ធសាសនា អស់កាលជាច្រើនសតវត្សរ៍មកហើយ ដែលពុទ្ធសាសនិកបានរក្សាសេចក្តីថ្លៃថ្នូរដ៏ខ្ពង់ខ្ពស់ ពោលគឺមិនដែលមានការបៀតបៀនទៅលើសាវ័កនៃសាសនាដទៃឡើយ។"

## The Birth

The Buddha, the founder of Buddhism, lived over 2,500 years ago and is known as Siddhattha Gotama. His father, Suddhodana, the Kshatriya king, ruled over the land of the Sākyans at Kapilavatthu on the Nepalese frontier. As he came from the Gotama family, he was known as Suddhodana Gotama. Mahāmāyā, princess of the Koliyas, was Suddhodana's queen.

In 623 B.C. on a full-moon day of May -Vasanta-tide, when in India the trees were laden with leaf, flower, and fruit, and man, bird, and beast were in joyous mood - Queen Mahāmāyā was travelling in state from Kapilavatthu to Devadaha, her parental home, according to the custom of the times, to give birth to her child. But that was not to be, for halfway between the two cities, in the beautiful Lumbinī Grove, under the shade of a flowering Sāla tree, she brought forth a son.

Lumbini, or Rummindei, the name by which it is now known, is one hundred miles north of Vārāṇasī and within sight of the snowcapped Himālayas. At this memorable spot where Prince Siddhattha, the future Buddha, was born, Emperor Asoka, 316 years after the event, erected a mighty stone pillar to mark the holy spot. The inscription engraved on the pillar in five lines consists of ninety-three Asokan characters, among which occurs the following: **"hida budhe jāte sākyamuni.** Here was born the Buddha, the sage of the Sākyans."

The mighty column is still to be seen. The pillar, as crisp as the day it was cut, had been struck by lightning even when Hiuen Tsiang, the Chinese pilgrim, saw it towards the middle of the seventh century A.C. The discovery and identification of Lumbini Park in 1896 is attributed to the renowned archaeologist, General Cunningham. On the fifth day after the birth of the prince, the king summoned eight wise men to choose a name for the child and to speak of the royal babe's future. He was named Siddhārtha, which means one whose purpose has been achieved. The brahmins deliberated and seven of them held up two fingers each and declared: "O King, this prince will become a **cakravarti**, a universal monarch, should he deign to rule, but should he renounce the world, he will

become a sammā-sambuddha, a Supremely Enlightened One, and deliver humanity from ignorance." But Koṇḍañña, the wisest and the youngest, after watching the prince, held up only one finger and said: "O King, this prince will one day go in search of truth and become a Supremely Enlightened Buddha."

Queen Mahāmāyā, the mother, passed away on the seventh day after the birth of her child, and the babe was nursed by his mother's sister, Pajāpati Gotamī. Though the child was nurtured till manhood in refinement amid an abundance of material luxury, the father did not fail to give his son the education that a prince ought to receive. He became skilled in many branches of knowledge, and in the arts of war easily excelled all others. Nevertheless, from his childhood the prince was given to serious contemplation.

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

| | |
|---|---|
| The Founder of Buddhism | ស្ថាបនិកពុទ្ធសាសនា |
| Full-moon day of May | ១៥ កើត ពេញបូណ៌មី ខែឧសភា (វិសាខ) |
| Vasanta-tide | វស្សន្តរដូវ, ជំនោរវស្សា |
| Lumbinī Grove | ឧទ្យានលុម្ពិនី |
| a flowering Sal tree | ដើមសាលព្រឹក្សដែលមានផ្ការីកស្គុះស្គាយ |
| Prince Siddhattha | ព្រះសិទ្ធត្ថ រាជកុមារ |
| Emperor Asoka | ព្រះបាទអសោកមហារាជ |
| pilgrim | អ្នកធម្មយាត្រា; pilgrimage ធម្មយាត្រា |
| brahmin | ព្រាហ្មណ៍ |
| cakravarti, a universal monarch | ចក្កវត្តិ ស្តេចចក្រព័ត្តិ |
| renounce the world (renunciation) | អភិនេស្រ្កម ឬដំណើរចេញចាកកាម (សាងផ្នួស) |
| deliver humanity from ignorance | សង្គ្រោះសត្តនិករឱ្យផុតពីអវិជ្ជា |
| material luxury | សេចក្តីសុខក្នុងភោគសម្បត្តិ |
| contemplation | ការយកចិត្តទុកដាក់ ការត្រិះរិះពិចារណា |
| Sammāsambuddha, a Supremely Enlightened One | ព្រះសម្មាសម្ពុទ្ធជាបុគ្គលដែលបានត្រាស់ដឹងហើយដោយប្រពៃ |

# ការប្រសូតិ

ព្រះពុទ្ធ ជាស្ថាបនិកពុទ្ធសាសនា បានគង់ព្រះធរមានកាលពីជាង២៥០០ឆ្នាំកន្លងទៅ ត្រូវបានគេស្គាល់ព្រះនាមថា សិទ្ធត្ថគោតម ។ ព្រះបិតាព្រះនាម សុទ្ធោទនៈ ជាក្សត្រនៃខត្តិយវង្ស គ្រប់គ្រងដែនដីសាក្យៈនៃនគរកបិលវត្ថុ ស្ថិតនៅជាប់ព្រំប្រទល់ប្រទេសនេប៉ាល់។ ដោយសារព្រះអង្គមកពីត្រកូលគោតម ទើបបានគេស្គាល់ព្រះនាមថា សុទ្ធោទនគោតម រីឯព្រះនាងមហាមាយា ជាក្សត្រីយ៍នៃកោលិយវង្ស ជាអគ្គមហេសីរបស់ទ្រង់ ។

ក្នុងឆ្នាំ៦២៣ នៃព.ស. ថ្ងៃពេញបូរណ៍មី ខែពិសាខ នារដូវស្សន្តរដូវ ជាពេលដែលដើមឈើទាំងឡាយកំពុងលូតលាស់ដោយស្លឹក បញ្ចេញនូវផ្កា និងផល្លានុផល មនុស្សម្នា បក្សាបក្សី និងសត្វពាហនៈទាំងឡាយ នៅក្នុងប្រទេសឥណ្ឌា ពោរពេញដោយសេចក្តីរីករាយស្រស់ស្រាយ ពេលនោះឯង មហាមាយាទេវី បានកំពុងធ្វើដំណើរពីនគរកបិលពស្តុឆ្ពោះទៅកាន់ទេវទហៈ ដែលជានគរព្រះមាតាបិតារបស់ព្រះនាង ដើម្បីប្រសូតិព្រះរាជបុត្រាតាមទំនៀមទំលាប់នាសម័យនោះ។ ប៉ុន្តែមិនទាន់បានដល់គោលដៅផង នាពាក់កណ្ដាលផ្លូវ នៅចន្លោះនៃនគរទាំងពីរ ក្នុងឧទ្យានលុម្ពិនី ដ៏ស្រស់ស្អាត ក្រោមម្លប់សាលព្រឹក្សប្រកបដោយផ្កាភ្ញី រីកស្គុះស្គាយបង្ហួតកាយ ព្រះនាងបានប្រសូតិព្រះរាជបុត្រ។

លុម្ពិនី ឬ រុម្មិនទី (Lumbinī or Rummindei) គឺជាឈ្មោះដែលគេបានស្គាល់ក្នុងពេលបច្ចុប្បន្ន មានចម្ងាយ១០០ ម៉ាលស៍(miles) ខាងជើងក្រុងពារាណសី ហើយអាចមើលឃើញជួរភ្នំទឹកកកហិមាល័យ (ហេមពាន្ត)។ នៅកន្លែងដ៏គួរចងចាំនេះហើយដែលព្រះសិទ្ធត្ថរាជកុមារ អនាគតព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រសូតិឡើងក្នុងលោក។ ៣១៦ ឆ្នាំក្រោយមក ព្រះបាទអសោកមហារាជ បានលើកឡើងនូវសសរស្តូបដ៏មានអានុភាព ដើម្បីកត់ចំណាំនូវទីសក្ការបូជា។ សិលាចារឹកដែលបានឆ្លាក់នៅលើសសរស្តូបមាន៥ បន្ទាត់ មានតួអក្សរសរុបចំនួន៩៣ ជាភាសាអសោកៈ ។ ក្នុងចំណោមនោះមានពាក្យប៉ុន្មានម៉ាត់ដូចតទៅ៖ *"ហិដា ពុទ្ធេ ជាតេ សាក្យមុនី។ នេះជាកន្លែងប្រសូតិរបស់ព្រះពុទ្ធ ជាគ្រូនៃសាក្យវង្ស។"*

សសរស្តូបដ៏មានអានុភាព ឃើញនៅមានរហូតដល់ពេលបច្ចុប្បន្ន ។ សសរស្តូបមានសភាពស្រួយ នៅថ្ងៃដែលត្រូវបានបាក់បែក ដោយការវាយពីរន្ទះបាញ់ សូម្បីតែអ្នកធ្វើដំណើរធម្មយាត្រាជនជាតិចិនឈ្មោះ Hiuen Tsiang (ថាំងចេង) ក៏បានឃើញសសរស្តូបនោះកាលពីពាក់កណ្តាលសតវត្សរ៍ទី៧ដែរ។ ការរកឃើញ និងកំណត់អត្តសញ្ញាណនៃឧទ្យានលុម្ពិនីស្ថិតនៅឆ្នាំ១៨៩៦ ជាស្នាដៃរបស់បុរាណវិទូដ៏ល្បីល្បាញ មួយរូបគឺ ឧត្តមសេនីយ៍ ខាន់នីងហែម (Cunnigham)។

នៅថ្ងៃទី៥ ក្រោយការប្រសូតិរបស់ព្រះរាជបុត្រ ព្រះរាជាបានកោះហៅបញ្ញវ័ន្ត៨រូបដើម្បីជ្រើសរើសព្រះនាម និងនិយាយអំពីអនាគតរបស់ព្រះរាជបុត្រ។ ព្រះរាជកុមារមានព្រះនាមថា សិទ្ធត្ថ (Siddhattha) មានន័យថាបុគ្គលដែលបានសម្រេច នូវគោលបំណងឬញុំាងប្រយោជន៍ឱ្យសម្រេច។ ព្រាហ្មណ៍ទាំងអស់បានរៀបរាប់ ហើយក្នុងចំណោមនោះព្រាហ្មណ៍៧នាក់បានលើកម្រាមដៃ២ រៀងៗខ្លួនហើយប្រកាសថាៈ "បពិត្រមហារាជ ព្រះរាជកុមារនឹងក្លាយជាស្តេចចក្រព័ត្រិប្រសិនបើព្រះអង្គនៅគ្រប់គ្រងរាជ្យ ប៉ុន្តែបើព្រះអង្គចេញសាងផ្នួស នឹងបានជាព្រះសម្មាសម្ពុទ្ធ ជាបុគ្គលដែលត្រាស់ដឹងដោយប្រពៃ ហើយនឹងជួយរំដោះសត្វលោកចេញចាកមោហៈអវិជ្ជា។" ប៉ុន្តែកោណ្ឌញ្ញៈ (Koṇḍañña) ដែលមានបញ្ញា និងនៅក្មេងជាងគេ ក្រោយពីបានគន់គូរមើលព្រះរាជកុមារហើយ បានលើកម្រាមដៃតែ១គត់ ហើយពោលថាៈ "បពិត្រមហារាជ ព្រះរាជកុមារអង្គនេះ ថ្ងៃមួយនឹងយាងស្វែងរកសច្ចធម៌ ហើយនឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធយ៉ាងពិតប្រាកដ។"

ព្រះនាងមហាមាយា ជាព្រះមាតា បានសោយព្រះវិលាល័យនៅថ្ងៃទី៧ បន្ទាប់ពីប្រសូតិព្រះរាជបុត្រ ហើយព្រះរាជបុត្រត្រូវបានចិញ្ចឹមបីបាច់ថែរក្សាដោយព្រះមាតុច្ឆា ព្រះនាម បជាបតិគោតមី (Pajāpati Gotamī) ។ ទោះបីព្រះរាជកុមារត្រូវបានចិញ្ចឹមតាំងពីតូចដល់ធំដោយការផ្ចិតផ្ចង់បំផុតក្តី បរិបូរណ៍ដោយគំនរទ្រព្យសម្បត្តិយ៉ាងណាក្តី ព្រះរាជបិតាមិនដែលខកខានក្នុងការផ្តល់ការសិក្សានូវវិជ្ជានានាដែលព្រះរាជបុត្រគួរទទួលបានឡើយ។ ព្រះរាជកុមារមានការស្ទាត់ជំនាញក្នុងចំណេះវិជ្ជាគ្រប់ប្រភេទ ព្រមទាំងក្នុងសិល្បៈនៃពិជ័យសង្គ្រាម ដែលអាចយកឈ្នះអ្នកដទៃបានដោយងាយ។ ទោះបីយ៉ាងណាក៏ដោយ តាំងពីកុមារភាព ព្រះរាជបុត្រតែងត្រូវបានផ្តល់ការយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅបំផុត។

# The Four Significant Visions

When the prince grew up, the father's fervent wish was that his son should marry, bring up a family, and be his worthy successor; for he often recalled to mind with dread the prediction of the sage Koṇḍañña, and feared that the prince would one day give up home for the homeless life of an ascetic. According to the custom of the time, at the early age of sixteen the prince was married to his cousin, the beautiful Princess Yasodharā, the only daughter of King Suppabuddha and Queen Pamitā of the Koliyas. The princess was of the same age as the prince.

His father provided him with the greatest comforts. He had, so the story tells, three palaces, one for each of the Indian year's three seasons. Lacking nothing of the earthly joys of life, he lived amid song and dance, in luxury and pleasure, knowing nothing of sorrow. Yet all the efforts of the father to hold his son a prisoner to the senses and make him worldly- minded were of no avail. King Suddhodana's endeavours to keep away life's miseries from his son's inquiring eyes only heightened Prince Siddhartha's curiosity and his resolute search for truth and Enlightenment. With the advance of age and maturity, the prince began to glimpse the woes of the world.

On one occasion, when the prince went driving with his charioteer Channa to the royal gardens, he saw to his amazement what his eyes had never beheld before: a man weakened with age, and in the last stage of ageing, crying out in a mournful voice: "Help master! lift me to my feet; oh, help! Or I shall die before I reach my house!"

This was the first shock the prince received. The second was the sight of a man, mere skin and bones, supremely unhappy and forlorn, "smitten with some pest. The strength is gone from ham, and loin, and neck, and all the grace and joy of manhood fled. On a third occasion he saw a band of lamenting kinsmen bearing on their shoulders the corpse of one beloved for cremation. These woeful signs, seen for the first time in his life, deeply moved him. From the charioteer he learned

that even he, his beloved Princess Yasodhara, and his kith and kin all, without exception, are subject to ageing, disease, and death.

Soon after this the prince saw a recluse moving with measured steps and down-cast eyes, calm and serene, aloof and independent. He was struck by the serene countenance of the man. He learned from Channa that this recluse was one who had abandoned his home to live a life of purity, to seek truth and answer the riddle of life. Thoughts of renunciation flashed through the prince's mind and in deep contemplation he turned homeward. The heart throb of an agonized and ailing humanity found a responsive echo in his own heart. The more he came in contact with the world outside his palace walls, the more convinced he became that the world was lacking in true happiness. But before reaching the palace he was met by a messenger with the news that a son had been born to Yasodharā. "A fetter is set upon me," uttered the prince and returned to the palace.

# Dhamma Terminology វាក្យសព្ទព្រះធម៌

**The Four Significant Visions (Omens/Signs)** **និមិត្ត (ប្រផ្នូល) ៤**

the prediction of the sage Koṇḍañña ការព្យាករណ៍របស់កោណ្ឌញ្ញព្រាហ្មណ៍

to give up home for the homeless life of an ascetic លះបង់ផ្ទះ ចេញសាងផ្នួស

earthly joys of life ជីវិតដែលពោរពេញដោយសេចក្តីសុខលើផែនដី

to hold his son a prisoner to the senses បង្ខាំងកូនទុកជាអ្នកទោសនៃគុកកាមគុណ

to make him worldly-minded ញុំាងចិត្តរបស់គេឱ្យជាប់ជំពាក់ក្នុងលោក

endeavor, effort, exertion, energy, perseverance, persistence សេចក្តីព្យាយាម (វីរិយៈ)

misery, unsatisfactoriness, suffering, discomfort, pain, sorrow, stress សេចក្តីទុក្ខ (ទុក្ខ)

to glimpse the woes of the world ឃើញនូវសេចក្តីទុក្ខក្នុងលោក

charioteer Channa ឆន្នមាត្យ នាយសារថី

kith and kin ព្រះញាតិវង្សានុវង្ស (ញាតិមិត្តសាច់សារលោហិត)

are subject to ageing, disease, and death ដែលនឹងត្រូវជួប ជរា ព្យាធិ និង មរណៈ

recluse (Samaṇa) សមណៈ ascetic, hermit : ឥសី, តាបស

woeful signs និមិត្តផ្សេងៗដ៏គួរឱ្យសង្វេគតក់ស្លុត

down-cast eyes, calm and serene, aloof and independent
មានចក្ខុឱនចុះ ស្ងប់ស្ងាត់ គត់មត់ និងឯករាជ្យ

resolute search for truth and enlightenment ការស្វែងរកយ៉ាងមុតមាំនូវ
សច្ចធម៌ និងការត្រាស់ដឹង

thought of renunciation (Nekkhamma-Saṅkappa) នេក្ខម្មសង្កប្បៈ
គំនិតចេញចាកកាម គឺចេញសាងផ្នួស

fetter, bond (Saṃyojana) សំយោជនៈ គ្រឿងចង គ្រឿងទាក់ទ្វាក់សត្វលោក

to live a life of purity, to seek truth and answer the riddle of life រស់នៅក្នុងជីវិតបរិសុទ្ធ (ព្រហ្មចរិយធម៌) ស្វែងរកសច្ចធម៌ និងដំណោះស្រាយជីវិត (ឆ្លើយប្រស្នាជីវិត)

# និមិត្ត (ប្រផ្នូល) ៤ យ៉ាង

ពេលដែលព្រះរាជបុត្រចំរើនវ័យ បំណងប្រាថ្នាដ៏ធំរបស់ព្រះបិតាគឺចង់ឱ្យព្រះរាជបុត្ររៀបអភិសេក បង្កើតគ្រួសារ និងក្លាយជាអ្នកស្នងរាជ្យបន្ត ដោយសារជារឿយៗ ព្រះបិតាតែងតែនឹកឃើញដោយសេចក្តីព្រួយបារម្ភអំពីការព្យាករណ៍របស់កោណ្ឌញ្ញព្រាហ្មណ៍ ហើយភ័យខ្លាចនៅថ្ងៃណាមួយ ព្រះរាជបុត្រនឹងលះបង់រាជសម្បត្តិ ដើម្បីចេញសាងផ្នួស។ យោងទៅលើប្រពៃណីនាសម័យនោះ ពេលមានព្រះជន្ម១៦ព្រះវស្សា ព្រះរាជបុត្របានទ្រង់រាជាភិសេកជាមួយបងប្អូនជីដូនមួយគឺព្រះរាជធីតាដ៏ស្រស់ស្អាតព្រះនាម យសោធរា (Yasodharā) ដែលជាបុត្រីតែមួយរបស់ព្រះបាទសុប្បពុទ្ធ (Suppabuddha) និងព្រះនាងបមិតា (Pamitā) នៃកោលិយវង្ស (Koliyas)។ ព្រះរាជធីតា និងព្រះរាជបុត្រ មានព្រះជន្មដូចគ្នា (១៦ ព្រះវស្សា)។

ព្រះបិតាទ្រង់បានផ្តល់នូវសេចក្តីសុខដ៏ក្រៃលែងដល់ព្រះរាជបុត្រ។ តាមនិទានព្រះអង្គមានប្រាសាទបី ប្រាសាទនីមួយៗសំរាប់រដូវកាលទាំងបីនៃប្រទេសឥណ្ឌា។ គ្មានខ្វះអ្វីសោះក្នុងជីវិតដែលពោរពេញទៅដោយសេចក្តីសុខនៅលើផែនដីនេះ ព្រះរាជបុត្របានរស់នៅក្នុងបណ្តានៃការច្រៀងរាំតូរ្យតន្ត្រី ប្រណីតភាព និងសេចក្តីសប្បាយ មិនដែលស្គាល់អ្វីហៅថាទុក្ខឡើយ។ ប៉ុន្តែការប្រឹងប្រែងទាំងអស់របស់ព្រះបិតាដើម្បីរក្សាព្រះរាជបុត្រ ដោយបង្ខាំងទុកដូចជាអ្នកទោសក្នុងកាមគុណ ដើម្បីធ្វើឱ្យព្រះទ័យរបស់ទ្រង់ជាប់ជំពាក់ក្នុងលោក បែរជាមិនបានសម្រេចដូចបំណងឡើយ។ សេចក្តីព្យាយាមរបស់ព្រះបាទសុទ្ធោទនៈ គឺពង្វាងព្រះរាជបុត្រមិនឱ្យឃើញនូវសេចក្តីទុក្ខនៃជីវិត តែផ្ទុយទៅវិញកាន់តែបន្ថែមការងឿងឆ្ងល់ដល់ព្រះសិទ្ធត្ថទៅវិញ ហើយទ្រង់ក៏បានប្តេជ្ញាចិត្តដើម្បីស្វែងរកការពិត និងការត្រាស់ដឹង។ ដោយព្រះជន្មចម្រើនឡើងវ័យវឌ្ឍនាការហើយ ព្រះរាជបុត្របានចាប់ផ្តើមឃើញសេចក្តីទុក្ខក្នុងលោក។

ក្នុងគ្រាមួយ ពេលព្រះរាជកុមារធ្វើដំណើរជាមួយឆន្នមាត្យជានាយសារថីឆ្ពោះទៅកាន់រាជឧទ្យាន ព្រះអង្គបានទតឃើញដោយភ្ញាក់ផ្អើលនូវអ្វីដែលព្រះអង្គមិនដែលបាន

ជួបដោយព្រះនេត្រផ្ទាល់ពីមុនមក មនុស្សម្នាក់ទ្រុឌទ្រោមទន់ខ្សោយជ្រេដោយអាយុ ស្ថិតក្នុងដំណាក់កាលចុងក្រោយនៃជរា កំពុងស្រែកយំទួញថ្ងូរដោយសំឡេងទុក្ខសោក "ជួយខ្ញុំផង លោកម្ចាស់! ជួយលើកខ្ញុំផង អូហ៍ ជួយ! បើមិនដូច្នោះទេ ខ្ញុំនឹងត្រូវស្លាប់មុនទៅដល់ផ្ទះ!"

នេះគឺជាសេចក្ដីសង្វេគតក់ស្លុតលើកទី១ដែលព្រះរាជកុមារបានជួប។ សេចក្ដីសង្វេគលើកទី២ គឺការឃើញបុរសម្នាក់ដែលមានតែស្បែកនិងឆ្អឹង មានសេចក្ដីទុក្ខដ៏ក្រៃលែង កំសត់អានាថា "មានសត្វបៀតបៀនរោមខាំ។ កម្លាំងពលំក៏បានបាត់បង់ទៅ ចាប់តាំងពីសាច់ភ្លៅ សាច់ចំឡក និងសាច់ក ហើយភាពរីករាយនិងសេចក្ដីសប្បាយនៃភាពជាមនុស្សក៏បានបាត់បង់អស់។"

សេចក្ដីសង្វេគលើកទី៣ ព្រះរាជកុមារបានឃើញនិមិត្តនៃញាតិមួយក្រុមកំពុងកាន់ទុក្ខ សែងសាកសពនៃមនុស្សជាទីស្រឡាញ់នៅលើស្មា យកទៅបូជា។ និមិត្តដែលប្រកបដោយទុក្ខទាំងអស់នេះ គឺជាលើកទី១ក្នុងជីវិតរបស់ព្រះអង្គដែលបានជួបប្រទះ ហើយក៏បានធ្វើឱ្យព្រះរាជកុមាររន្ធត់ព្រះរាជហឫទ័យជាខ្លាំង ។ ព្រះរាជបុត្របានស្វែងយល់ពីនាយសារថីថា សូម្បីតែព្រះអង្គ ព្រះនាងពិម្ពាយសោធរាជាទីស្រឡាញ់ ព្រះញាតិវង្សានុវង្ស និងមនុស្សគ្រប់គ្នា គ្មាននរណាម្នាក់គេចផុតអំពីជរា ព្យាធិ មរណៈឡើយ។

ភ្លាមនោះ ព្រះរាជបុត្របានទតឃើញសមណៈមួយអង្គកំពុងនិមន្តដោយជំហានស្មើៗ មានចក្ខុសំឡឹងចុះ ស្ងប់ស្ងាត់និងគត់មត់ រម្យទមនិងឯករាជ្យ (មានភាពម្ចាស់ការ) ។ ព្រះរាជកុមារសព្វព្រះរាជហឫទ័យយ៉ាងខ្លាំង ដោយឥន្រ្ទិយ៍ដ៏ស្រគត់ស្រគំរបស់សមណៈនោះ។ ព្រះអង្គបានស្វែងយល់ពីឆន្នមាត្យថា សមណៈរូបនេះ ជាបុគ្គលដែលបានលះបង់ផ្ទះ ដើម្បីរស់នៅក្នុងជីវិតដ៏បរិសុទ្ធ (ប្រព្រឹត្តនូវព្រហ្មចរិយធម៌) ស្វះស្វែងនូវសច្ចធម៌ និងដំណោះស្រាយជីវិត។ នេក្ខម្មសង្កប្បៈ គឺគំនិតចេញសាងផ្នួសបានកើតឡើងភ្លាមមួយរំពេចក្នុងព្រះទ័យព្រះអង្គ ដោយផ្ដោតការយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅ ហើយក៏បានយាងត្រឡប់ទៅព្រះរាជវាំងវិញ។ ចង្វាក់បេះដូងលោតដុកដាក់ ក្នុងសេចក្ដីទុក្ខនិងជំងឺរបស់មនុស្សជាតិ ហើយសំឡេងឆ្លើយតបក៏កើតមាននៅក្នុងបេះដូងព្រះអង្គ។ កាលបើព្រះរាជកុមារកាន់តែមានទំនាក់ទំនងជាមួយពិភពលោកខាងក្រៅជញ្ជាំងព្រះរាជវាំងរបស់ទ្រង់ គឺកាន់តែធ្វើឱ្យព្រះអង្គបានឃើញថា ពិភពលោកកំពុងខ្វះនូវសេចក្ដីសុខពិត

ប្រាកដ។ ប៉ុន្តែមុននឹងយាងទៅដល់ព្រះរាជវាំង ព្រះអង្គបានជួបអ្នកនាំសារដែលនាំពត៌មានថា ព្រះនាងយសោធរា បានប្រសូតិព្រះរាជបុត្រហើយ។ "សំយោជនៈ (ចំណង) បានកើតឡើងហើយដល់អាត្មាអញ"។ ព្រះរាជបុត្របានឧទានបែបនេះហើយ ក៏យាងត្រឡប់ចូលព្រះរាជវាំងវិញ។

## The Great Renunciation

In the silence of that moonlit night (it was the full-moon day of July, Āsāḷha) such thoughts as these arose in him: "Youth, the prime of life, ends in old age and man's senses fail him at a time when they are most needed. The hale and hearty lose their vigour and health when disease suddenly creeps in. Finally death comes, sudden perhaps and unexpected, and puts an end to this brief span of life. Surely there must be an escape from this unsatisfactoriness, from aging and death."

Thus the great intoxication of youth (yobbana-mada), of health (ārogya-mada), and of life (jīvita-mada) left him. Having seen the vanity and the danger of the three intoxications, he was overcome by a powerful urge to seek and win the Deathless, to strive for deliverance from old age, illness, misery, and death not only for himself but for all beings (including his wife and child) that suffer. It was his deep compassion that led him to the quest ending in enlightenment, in Buddhahood. It was compassion that now moved his heart towards the great renunciation and opened for him the doors of the golden cage of his home life. It was compassion that made his determination unshakeable even by the last parting glance at his beloved wife asleep with the baby in her arms.

Thus at the age of twenty-nine, in the flower of youthful manhood, on the day his beautiful Yasodharā had given birth to his only son, Rāhula, Prince Siddhattha Gotama, discarding and disdaining the enchantment of the royal life, scorning and spurning joys that most young men yearn for, tore himself away, renouncing wife and child and a crown that held the promise of power and glory.

He cut off his long locks with his sword, doffed his royal robes, and putting on a hermit's robe retreated into forest solitude to seek a solution to those problems of life that had so deeply stirred his mind. He sought an answer to the riddle of life, seeking not a palliative, but a true way out of suffering -to perfect enlightenment and Nibbāna. His quest for the supreme security from bondage-Nibbāna (Nirvāna) - had begun. This was the great renunciation, the greatest adventure known to humanity.

First he sought guidance from two famous sages, from Alāra Kālāma and Uddaka Rāmaputta, hoping that they, being masters of meditation, would teach him all they knew, leading him to the heights of concentrative thought. He practised concentration and reached the highest meditative attainments possible thereby, but was not satisfied with anything short of Supreme Enlightenment. These teachers range of knowledge, their ambit of mystical experience, however, was insufficient to grant him what he so earnestly sought, and he saw himself still far from his goal. Though both sages, in turn, asked him to stay and succeed them as the teacher of their following, the ascetic Gotama declined. Paying obeisance to them, he left them in search of the still unknown.

In his wanderings he finally reached Uruvela, by the river Neranjarā at Gayā. He was attracted by its quiet and dense groves, and the clear waters of the river were soothing to his senses and stimulating to his mind. Nearby was a village of simple folk where he could get his alms. Finding that this was a suitable place to continue his quest for enlightenment, he decided to stay. Soon five other ascetics who admired his determined effort joined him. They were Koṇḍañña, Bhaddiya, Vappa, Mahānāma, and Assaji.

# Dhamma Terminology វាក្យសព្ទព្រះធម៌

**The Great Renunciation** **អភិនេស្រ្កម៍, ការលះបង់រាជសម្បត្តិចេញសាងផ្នួស**

moonlit night (full-moon day of July, āsāḷha) រាត្រីចែងចាំងចន្ទពេញបូណ៌មី ខែកក្កដា (អាសាឡ្ហ)

escape from unsatisfactoriness ចេញចាកពីសេចក្តីទុក្ខ

intoxication of youth (yobbana-mada) យោព្វនមទៈ ការស្រវឹងក្នុងវ័យ

intoxication of health (ārogya-mada) អារោគ្យមទៈ ការស្រវឹងក្នុងការមិនមានរោគ

intoxication of life (Jīvita-mada) ជីវិតមទៈ ការស្រវឹងក្នុងជីវិត

to strive for deliverance from ព្យាយាមដើម្បីការរួចរដោះចាក

paying obeisance នមស្ការ/ថ្វាយបង្គំ

ascetic, hermit តាបស, ឥសី

discarding and disdaining លះបង់ និងមិនឱ្យតម្លៃ

scorning and spurning បដិសេធ និងច្រានចោល

supreme enlightenment ការត្រាស់ដឹងដ៏ប្រសើរក្រៃលែង

meditation, concentration សមាធិ

retreated into forest solitude សំងំនៅក្នុងព្រៃស្ងាត់ (អភិរម្យសំងំនៅក្នុងកម្មដ្ឋាន)

supreme security from bondage -Nibbāna សេចក្តីក្សេមចាកចំណង(វដ្តៈ) គឺព្រះនិព្វាន

made his determination unshakable បានប្តេជ្ញាចិត្តរបស់ខ្លួនដោយឥតញាប់ញ័រ (មិនរាថយ)

highest meditative attainment ការសម្រេចនូវឈាន ឬសមាធិដែលខ្ពស់បំផុត

renouncing wife and child and a crown លះបង់អគ្គមហេសី និងបុត្រ ព្រមទាំងរាជសម្បត្តិ

misery, unsatisfactoriness, suffering, pain, sorrow, discomfort, stress សេចក្តីទុក្ខ

# អភិនេស្រ្កម៍ (ការចេញសាងផ្នួស)

ក្នុងសភាពស្ងប់ស្ងាត់នារាត្រីចន្ទមានពន្លឺចែងចាំង (ពេញបូណ៌មី ខែអាសាធ (កក្កដា)) គំនិតយ៉ាងនេះបានកើតឡើងចំពោះព្រះអង្គ "យុវវ័យ បឋមវ័យនៃជីវិត នឹងត្រូវបញ្ចប់ដោយជរាភាព ហើយអាយតនៈទាំងឡាយរបស់មនុស្សក៏នឹងត្រូវសាបសូន្យទៅនៅពេលដែលមនុស្សត្រូវការបំផុត។ ភាពរឹងប៉ឹងនិងមាំមួន នឹងបាត់បង់ឋាមពល ហើយសុខភាពក៏នឹងទ្រុឌទ្រោមពេលព្យាធិចូលមកយាយី។ ចុងក្រោយ សេចក្ដីស្លាប់ក៏មកដល់ ភ្លាមៗ ហើយប្រហែលជាអ្វីដែលមិនរំពឹងទុកក៏កើតឡើង ញុំាងទីបំផុតនៃអាយុដ៏ខ្លីនេះឱ្យដល់ព្រម។ ប្រាកដណាស់ ច្បាស់ជាមានការចាកចេញពីទុក្ខ ជរា និងមរណៈជាក់ជាមិនខាន"។

ដូច្នេះ ការស្រវឹងដ៏ក្រៃលែងក្នុងវ័យ(យោព្វនមទៈ) ការស្រវឹងក្នុងភាពមិនមានរោគ (អារោគ្យមទៈ) និងការស្រវឹងក្នុងជីវិត(ជីវិតមទៈ) បានចេញចាកពីព្រះអង្គ។ ដោយបានឃើញនូវភាពឥតខ្លឹមសារ និងគ្រោះថ្នាក់នៅក្នុងសេចក្តីស្រវឹងទាំងបីយ៉ាងនេះ ព្រះអង្គបានយកឈ្នះដោយជំរុញនូវកម្លាំងចិត្តដើម្បីស្វែងរក និងជម្នះ គឺអមតធម៌ (សេចក្ដីមិនស្លាប់) ដើម្បីព្យាយាមរដោះខ្លួនពីជរា ព្យាធិ ទុក្ខៈ និងមរណៈ មិនសម្រាប់តែព្រះអង្គផ្ទាល់ តែសព្វសត្វទាំងអស់ (រួមទាំងព្រះមហេសី និងព្រះរាជបុត្រ) ដែលរងទុក្ខ។ ព្រោះតែមហាករុណាដ៏ជ្រាលជ្រៅរបស់ព្រះអង្គ ដែលបាននាំទ្រង់ស្វែងរកនូវ គោលដៅទីបំផុតគឺ សម្មាសម្ពោធិញាណជាពុទ្ធភាវៈ។ សេចក្ដីករុណា បានជំរុញព្រះទ័យព្រះអង្គចេញសាងផ្នួស និងបានបើកទ្វារនៃទ្រុងមាសចេញចាកឃរាវាស។ សេចក្ដីករុណា បានធ្វើឱ្យការប្ដេជ្ញាចិត្តរបស់ព្រះអង្គមិនញាប់ញ័រមិនរាថយ សូម្បីមុនពេលចាកចេញជាចុងក្រោយ ព្រះអង្គបានចោលព្រះនេត្រក្រឡេកមើលព្រះមហេសីជាទីស្រឡាញ់កំពុងផ្ទុំលង់លក់ជាមួយព្រះរាជបុត្រនៅក្នុងព្រះហស្ត។

ដូច្នេះ នៅព្រះជន្ម២៩ព្រះវស្សា ដូចជាបុប្ផាក្នុងយុវវ័យនៃបុរសភាព នៅថ្ងៃដែលព្រះមហេសីដ៏ស្រស់ស្អាត យសោធរា (Yasodharā) បានប្រសូតិព្រះរាជបុត្រតែមួយគត់របស់ទ្រង់គឺ **រាហុលកុមារ** ។ ព្រះសិទ្ធត្ថគោតម បានបោះបង់ និងមិនខ្វល់ខ្វាយក្នុងរាជសម្បត្តិឡើយ ព្រមទាំងបានបដិសេធ និងច្រានចោលនូវការសប្បាយដែលយុវជន

ទាំងឡាយប្រាថ្នាចង់បាន បង្វិចិត្តចាកចេញ លះបង់ព្រះមហេសី ព្រះរាជបុត្រ និងរាជសម្បត្តិ ដែលជាអំណាច និងភាពរុងរឿងនៃនគរ។

ព្រះអង្គបានកាត់ផ្នួងសក់ដោយព្រះខាន់របស់ទ្រង់ ដោះព្រះពស្ត្រ ហើយស្លៀកដណ្តប់នូវសំពត់ជាតាបស ហើយសំងំនៅក្នុងព្រៃស្ងាត់ អភិរម្យបន្ទំក្នុងកម្មដ្ឋាន ដើម្បីស្វែងរកដំណោះស្រាយបញ្ហានៃជីវិតដែលបានអង្រួនព្រះទ័យព្រះអង្គយ៉ាងជ្រៅ។ ព្រះអង្គបានស្វែងរកឃើញនូវចម្លើយនៃប្រស្នាជីវិត មិនមែនគ្រាន់តែដើម្បីបន្ធូរបន្ថយនូវសេចក្តីទុក្ខប៉ុណ្ណោះទេ តែជាមាគ៌ាពិតប្រាកដចេញចាកទុក្ខ ពោលគឺការត្រាស់ដឹងដោយបរិបូណ៌ និងព្រះនិព្វាន។ ការស្វែងរករបស់ព្រះអង្គនូវសេចក្តីក្សេមដ៏ខ្ពង់ខ្ពស់ចាកចំណងវដ្តៈ គឺព្រះនិព្វាន បានចាប់ផ្តើមហើយ។ នេះគឺជាអភិនេស្ក្រមណ៍ (ការលះបង់ចេញសាងផ្នួសដ៏ប្រសើរក្រៃលែង)ជាដំណើរផ្សងព្រេងដ៏អស្ចារ្យល្បីរន្ទឺនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។

លើកដំបូង ព្រះអង្គបានស្វែងរកការណែនាំពីសំណាក់តាបសដ៏មានកេរ្តិ៍ឈ្មោះល្បីពីររូបគឺ៖ អឡារៈកាលាម និង ឧទ្ទករាមបុត្ត (Alāra Kālāma and Uddaka Rāmaputta) ដោយសង្ឃឹមថាតាបសទាំងពីររូបដែលជាអាចារ្យកម្មដ្ឋាន នឹងបង្រៀនព្រះអង្គទាំងអស់នូវអ្វីដែលពួកគេចេះ និងអាចឱ្យព្រះអង្គបានសម្រេចដល់ឈានសមាធិជាន់ខ្ពស់។ ព្រះអង្គបានបដិបត្តិសមាធិ ហើយបានសម្រេចឈានសមាបត្តិជាន់ខ្ពស់បំផុតនាសម័យនោះ ប៉ុន្តែព្រះអង្គពុំបានពេញព្រះទ័យនូវអ្វីដែលជាការខ្វះខាត គឺការត្រាស់ដឹងដែលពេញបរិបូណ៌។ ចំណេះដឹង និងវិសាលភាពបទពិសោធន៍នៃគ្រូទាំងពីរ ទោះបីយ៉ាងណាក៏ដោយ ក៏មិនគ្រប់គ្រាន់ដើម្បីផ្តល់នូវអ្វីដែលព្រះអង្គកំពុងស្វែងរកយ៉ាងស្វិតស្វាញបានឡើយ ព្រះអង្គឃើញខ្លួនឯងនៅឆ្ងាយណាស់ពីគោលដៅ។ ក្រៅពីមិនមានអ្វីដើម្បីបង្រៀនតទៅទៀត អាចារ្យទាំងពីរបានស្នើព្រះអង្គឱ្យគង់នៅ ដើម្បីបន្តស្នងតំណែងជាគ្រូ តែត្រូវសាមណគោតមបដិសេធ។ ក្រោយពីថ្វាយបង្គំលាអាចារ្យទាំងពីរហើយ ព្រះអង្គក៏បានចាកចេញទៅដើម្បីបន្តរុករកនូវអ្វីដែលមិនទាន់រកឃើញ។

ក្នុងដំណើរត្រាច់ចររបស់ព្រះអង្គ ទីបំផុតបានយាងដល់ ឧរុវេលា (Uruvelā) ជាប់ស្ទឹងនេរញ្ជរា (Nerañjarā) ក្នុងដែនគយា។ ព្រះអង្គបានសព្វព្រះទ័យនឹងសភាពស្ងប់ស្ងាត់ មួយអន្លើដោយដងព្រៃដ៏ក្រៃលក្រាស់ ប៉ះទឹកស្ទឹងដ៏ថ្លាយង់ ញ៉ាំងឥន្ទ្រីយ៍របស់ទ្រង់ ឱ្យស្រស់ស្រទ្បះរីករាយជាពន់ពេក។ នៅជិតនោះ មានភូមិអ្នកស្រុកដ៏សាមញ្ញមួយ

ដែលព្រះអង្គអាចយាងបិណ្ឌបាត។ ដោយទ្រង់យល់ឃើញថា នេះជាកន្លែងសមគួរដើម្បី បន្តស្វែងរកនូវសម្ពោធិញ្ញាណ ព្រះអង្គក៏បានសម្រេចព្រះទ័យគង់នៅ។ ក្រោយមកភ្លាម តាបសទាំងប្រាំរូបដែលធ្លាប់ស្ញប់ស្ញែងនូវវិរិយភាពមិនរាថយរបស់ព្រះអង្គ ក៏បានមកចូល រួមអាស្រ័យ(ដើម្បីគាល់បម្រើព្រះអង្គ)។ តាបសទាំងប្រាំរូបគឺៈ កោណ្ឌញ្ញ ភទ្ទិយ វប្ប មហានាម និង អស្សជិ។

## Self-mortification

There was, and still is, a belief in India among many of her ascetics that purification and final deliverance can be achieved by rigorous self-mortification, and the ascetic Gotama decided to test the truth of it. And so there at Uruvelā he began a determined struggle to subdue his body in the hope that his mind, set free from the shackles of the body, might be able to soar to the heights of liberation. Most zealous was he in these practices. He lived on leaves and roots, on a steadily reduced pittance of food; he wore rags from dust heaps; he slept among corpses or on beds of thorns. The utter paucity of nourishment left him a physical wreck. Says the Master: "Rigorous have I been in my ascetic discipline. Rigorous have I been beyond all others. Like wasted withered reeds became all my limbs.’’ In such words as these, in later years, having attained to full enlightenment, did the Buddha give his disciples an awe-inspiring description of his early penances.

Struggling thus for six long years, he came to death's very door, but he found himself no nearer to his goal. The utter futility of self-mortification became abundantly clear to him by his own experience. He realized that the path to the fruition of his ardent longing lay in the direction of a search inward into his own mind. Undiscouraged, his still active mind searched for new paths to the aspired goal. He felt, however, that with a body so utterly weakened as his, he could not follow that path with any chance of success. Thus he abandoned self-torture and extreme fasting and took normal food.

His emaciated body recovered its former health and his exhausted vigour soon returned. Now his five companions left him in their disappointment, for they thought that he had given up the effort and had resumed a life of abundance. Nevertheless, with firm determination and complete faith in his own purity and strength, unaided by any teacher, accompanied by none, the Bodhisatta resolved to make his final effort in complete solitude.

On the forenoon of the day before his enlightenment while the Bodhisatta was seated in meditation under a banyan tree, Sujātā, the daughter of a rich

householder, not knowing whether the ascetic was divine or human, offered milk-rice to him saying: "Lord, may your aspirations be crowned with success! This was his last meal prior to his enlightenment.

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| **Self-mortification** | **អត្តកិលមថានុយោគ** |

The Two Extremes (Anta-dhamma): អន្តធម៌ ២ ធម៌ជាផ្លូវប្រតិបត្តិអមខាង ដ៏លាមកអាក្រក់

1.Sensual-indulgence (Kāmasukhallikā-nuyoga កាមសុខល្លិកានុយោគ)

| | |
|---|---|
| | ធម៌ដែលប្រកបខ្លួនឱ្យជាប់ជំពាក់ |
| 2.Self-mortification (Attakilamathā-nuyoga | អត្តកិលមថានុយោគ) |
| | ធម៌ដែលប្រកបសេចក្តីលំបាកដល់ខ្លួន |
| self-torture, self-mortification | ទុក្ករកិរិយា ឬការធ្វើខ្លួនឱ្យលំបាក |
| purification | សេចក្តីបរិសុទ្ធ |
| rigorous | ដែលតឹងរឹង |
| ardent | ដែលក្លៀវក្លា |
| faith, conviction, confidence | ជំនឿ (សទ្ធា) |
| banyan tree | ដើមពោធិ៍ |
| householder | គហបតី |
| divine or human | ទេវតា ឬ មនុស្ស |
| the utter paucity of nourishment | កង្វះខាតអាហារយ៉ាងខ្លាំងក្លា |
| awe-inspiring description | ការបរិយាយដ៏គួរឱ្យស្ញើចសរសើរ |
| to subdue his body | បង្ក្រាប ឬជម្នះលើរាងកាយរបស់ព្រះអង្គ |
| ardent longing | សេចក្តីប្រាថ្នាយ៉ាងក្លៀវក្លាជាយូរមកហើយ |
| extreme fasting | ការបង្អត់ ឬតមអាហារយ៉ាងសម្បើម |
| firm determination | ការអធិដ្ឋានចិត្តយ៉ាងមុតមាំ |
| disciple, votary, follower, retinue, adherent | សាវ័ក (អ្នកស្តាប់តាម ឬអ្នកដើរតាម) |
| liberation, emancipation, deliverance | ការរួចរំដោះ |
| penance | ការកែកំហុស (ការដឹងខ្លួនខុស ហើយកែប្រែឡើងវិញ) |

# ទុក្ករកិរិយា

កាលពីដើមឡើយធ្លាប់មាន ហើយបច្ចុប្បន្នក៏នៅតែមានជំនឿមួយនៅក្នុងប្រទេសឥណ្ឌាដែលក្នុងចំណោមតាបសជាច្រើនជឿថា សេចក្តីបរិសុទ្ធនិងការរួចចាកទុក្ខទាំងពួង អាចសម្រេចទៅបានដោយការប្រព្រឹត្តទុក្ករកិរិយាដ៏តឹងរឹង ហើយព្រះសមណគោតម ក៏បានសម្រេចព្រះទ័យសាកល្បងនូវបដិបទានោះដែរ។ ដូច្នេះហើយ នៅឧរុវេលា (Uruvelā) ព្រះអង្គបានចាប់ផ្តើមពុះពារប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ដើម្បីជម្នះរាងកាយក្នុងក្តីសង្ឃឹមថាចិត្តព្រះអង្គនឹងរួចរដោះចេញពីច្រវាក់នៃរាងកាយ ហើយអាចសម្រេចបាននូវកំពូលនៃការរួចចាកទុក្ខ។ ព្រះអង្គជាប់ព្រះទ័យយ៉ាងខ្លាំងក្នុងការបដិបត្តិ ទាំងនេះ។ ព្រះអង្គគង់នៅដោយអាស្រ័យស្លឹកឈើ និងមើមឈើ ពោលគឺកាត់ បន្ថយអាហារជាលំដាប់។ ព្រះអង្គស្លៀកដណ្តប់ដោយសំពត់រហែករើសពីគំនរសំរាម ទ្រង់ផ្ទុំក្នុងចំណោមសាកសពលើបន្លាជាដើមប្រកបដោយភាពលំបាកក្រៃលែង។ កង្វះខាតអាហារយ៉ាងខ្លាំងក្លាបានធ្វើឱ្យព្រះអង្គមានព្រះកាយពលទ្រុឌទ្រោម ។ ព្រះអង្គមានព្រះវាចាថា៖ "ការបដិបត្តិតឹងរឹងអាត្មាអញបានធ្វើហើយក្នុងវិន័យរបស់តាបស។ ការបដិបត្តិតឹងរឹង អាត្មាអញបានធ្វើហើយ លើសនរណាៗទាំងអស់។ ដូចជាឥតប្រយោជន៍ រាងកាយអាត្មាអញក្រៀមស្វិតដូចស្មៅ..."។ នៅក្នុងពាក្យទាំងឡាយដូចព្រះអង្គបានពណ៌នាមកនេះ នៅឆ្នាំជាខាងក្រោយមក ដោយបានសម្រេចនូវការត្រាស់ដឹងដោយបរិបូរណ៌ហើយ ព្រះសម្មាសម្ពុទ្ធទ្រង់បានបរិយាយរៀបរាប់ពន្យល់ដល់សាវ័កនូវបទពិសោធនៃទុក្ករកិរិយាដ៏គួរឲ្យស្ញើចសរសើរ។

ដោយការពុះពារអស់រយៈពេល៦ព្រះវស្សា ព្រះអង្គបានចូលដល់ច្រកទ្វារមរណៈ ប៉ុន្តែព្រះអង្គបែរជាឃើញថាខ្លួនមិនបានទៅក្បែរគោលដៅសូម្បីបន្តិច។ ភាពឥតខ្លឹមសារនៃទុក្ករកិរិយា បានធ្វើឱ្យព្រះអង្គយល់យ៉ាងជាក់ច្បាស់ដោយការពិសោធន៍ផ្ទាល់របស់ព្រះអង្គ ។ ព្រះអង្គបានឈ្វេងយល់យ៉ាងច្បាស់ថា មាគ៌ាដែលអាចនាំព្រះអង្គឱ្យបានទៅដល់គោលដៅដែលប៉ងជាយូរមកហើយនោះ គឺស្ថិតនៅត្រង់ការស្វែងរកខាងក្នុងនៃចិត្តរបស់ព្រះអង្គផ្ទាល់។ ដោយការចុះញ៉ម ព្រះទ័យដែលនៅតែសកម្មបំផុតរបស់ទ្រង់ បានបន្តស្វែងរកនូវមាគ៌ាថ្មីឆ្ពោះទៅកាន់គោលដៅដែលជាក្តីស្រមៃ។ ព្រះអង្គមានអារម្មណ៍ថាជាមួយរាងកាយដែលទ្រុឌទ្រោមទន់ខ្សោយបែបនេះ ព្រះអង្គនឹងមិនអាចដើរទៅដល់

គោលដៅប្រកបដោយជោគជ័យបានឡើយ។ ទើបព្រះអង្គបានលះបង់នូវទុក្ករកិរិយា និងការផ្តាច់អាហារ ហើយបានត្រឡប់មកសោយចង្ហាន់ជាធម្មតាវិញ។

ព្រះកាយដ៏ស្គមស្វិតសល់តែគ្រោងឆ្អឹងរបស់ព្រះអង្គ ក៏បានជាសះស្បើយមកដូចដើមវិញ ហើយកម្លាំងពលំព្រះអង្គក៏បានត្រឡប់មកវិញជាបន្ត។ ពេលនោះ តាបសទាំង ៥ បានចាកចេញពីព្រះអង្គព្រោះការខកចិត្ត ដោយគិតថាព្រះអង្គបានបោះបង់ចោលនូវការព្យាយាមប្រឹងប្រែង ហើយត្រឡប់ទៅរកជីវិតដែលស្រណុកសុខស្រួលវិញ។ ទោះបីយ៉ាងនេះក្តី ដោយការប្តេជ្ញាចិត្តដ៏មុតមាំ និងសទ្ធាដ៏បរិបូរណ៍ នៅក្នុងសេចក្តីបរិសុទ្ធនិងកម្លាំងរបស់ព្រះអង្គ ដោយគ្មានជំនួយពីគ្រូអាចារ្យណា ដោយគ្មានអ្នកហែរហម ព្រះពោធិសត្វបានអធិដ្ឋានចិត្តក្នុងសេចក្តីព្យាយាមចុងក្រោយដើម្បីអភិរម្យសម្ងំក្នុងកម្មដ្ឋាន។

វេលាថ្ងៃត្រង់ មុនពេលព្រះអង្គបានត្រាស់ដឹង ខណៈដែលព្រះពោធិសត្វទ្រង់គង់នៅក្នុងកម្មដ្ឋានក្រោមម្លប់ពោធិព្រឹក្ស នាងសុជាតាដែលជាធីតានៃគហបតីដ៏ស្តុកស្តម (កុដុម្ពី)ម្នាក់ ដោយមិនបានដឹងថាតាបសនោះជាទេវតា ឬជាមនុស្ស បានថ្វាយនូវមធុបាយស (បាយលាយទឹកដោះគោ) ដល់ព្រះអង្គហើយទូលថា "បពិត្រព្រះជាម្ចាស់ សូមឱ្យសេចក្តីប្រាថ្នារបស់ព្រះអង្គបានសម្រេច"។ នោះគឺជាចង្ហាន់ចុងក្រោយ(របស់ព្រះពោធិសត្វ) មុនពេលត្រាស់ដឹង។

## The Final Triumph

Cross-legged he sat under a tree, which later became known as the Bodhi Tree, " the Tree of Enlightenment" or "Tree of Wisdom, on the bank of the river Nerañjarā, at Gayā (now known as Buddhagayā), making the final effort with the inflexible resolution: "Though only my skin, sinews, and bones remain, and my blood and flesh dry up and wither away, yet will I never stir from this seat until I have attained full enlightenment (sammā-sambodhi)."So indefatigable in effort, so unflagging in his devotion was he, and so resolute to realize truth and attain full enlightenment.

Applying himself to the "mindfulness of in-and-out breathing" (ānāpāṇa sati), the Bodhisatta entered upon and dwelt in the first meditative absorption (jhāna; Skt. dhyāna). By gradual stages he entered upon and dwelt in the second, third, and fourth jhānas. Thus cleansing his mind of impurities, with the mind thus composed, he directed it to the knowledge of recollecting past births (pubbenivāsānussatiñāṇa). This was the first knowledge attained by him in the first watch of the night. Then the Bodhisatta directed his mind to the knowledge of the disappearing and reappearing of beings of varied forms, in good states of experience, and in states of woe, each faring according to his deeds (cutūpapātaññāṇa). This was the second knowledge attained by him in the middle watch of the night. Next he directed his mind to the knowledge of the eradication of the taints (āsavakkhayaññāṇa).

He understood as it really is: "This is suffering (dukkha), this is the arising of suffering, this is the cessation of suffering, this is the path leading to the cessation of suffering. "He understood as it really is: "These are defilements (āsavas), this is the arising of defilements, this is the cessation of defilements, this is the path leading to the cessation of defilements."Knowing thus, seeing thus, his mind was liberated from the defilements of sense pleasures (kāmāsava), of becoming (bhavāsava), and of ignorance (avijjāsava). When his mind was thus liberated, there came the knowledge, "liberated' and he understood: "Destroyed is birth, the noble life (brahmacariya) has been lived, done is what was to be done,

there is no more of this to come" (meaning, there is no more continuity of the mind and body, no more becoming, rebirth). This was the third knowledge attained by him in the last watch of the night. This is known as tevijjā (Skt. trividyā), threefold knowledge.

Thereupon he spoke these words of victory:
"Seeking but not finding the house builder,
I hurried through the round of many births:
Painful is birth ever and again.
O house builder, you have been seen;
You shall not build the house again.
Your rafters have been broken up,
Your ridgepole is demolished too.
My mind has now attained the unformed Nibbāna
And reached the end of every sort of craving.

Thus the Bodhisatta" Gotama at the age of thirty-five, on another full moon of May (visākha, vesak), attained Supreme Enlightenment by comprehending in all their fullness the Four Noble Truths, the Eternal Verities, and he became the Buddha, the Great Healer and Consummate Master-Physician who can cure the ills of beings. This is the greatest unshakeable victory.

The Four Noble Truths are the priceless message that the Buddha gave to suffering humanity for their guidance, to help them to be rid of the bondage of dukkha, and to attain the absolute happiness, that absolute reality--Nibbāna.

These truths are not his creation. He only rediscovered their existence. We thus have in the Buddha one who deserves our respect and reverence not only as a teacher but also as model of the noble, self-sacrificing, and meditative life we would do well to follow if we wish to improve ourselves.

One of the noteworthy characteristics that distinguishes the Buddha from all other religious teachers is that he was a human being having no connection whatsoever with a God or any other "supernatural" being. He was neither God nor an incarnation of God, nor a prophet, nor any mythological figure. He was a man,

but an extraordinary man (acchariya manussa), a unique being, a man par excellence (purisuttama). All his achievements are attributed to his human effort and his human understanding. Through personal experience he understood the supremacy of man.

Depending on his own unremitting energy, unaided by any teacher, human or divine, he achieved the highest mental and intellectual attainments, reached the acme of purity, and was perfect in the best qualities of human nature. He was an embodiment of compassion and wisdom, which became the two guiding principles in his Dispensation (sāsana).

The Buddha never claimed to be a saviour who tried to save "souls" by means of a revealed religion. Through his own perseverance and understanding he proved that infinite potentialities are latent in man and that it must be man's endeavour to develop and unfold these possibilities. He proved by his own experience that deliverance and enlightenment lie fully within man's range of effort.

"Religion of the highest and fullest character can coexist with a complete absence of belief in revelation in any straightforward sense of the word, and in that kernel of revealed religion, a personal God. Under the term personal God I include all ideas of a so-called superpersonal god, of the same spiritual and mental nature as a personality but on a higher level, or indeed any supernatural spiritual existence or force." (Julian Huxley, Religion Without Revelation, pp.2 and 7.)

Each individual should make the appropriate effort and break the shackles that have kept him in bondage, winning freedom from the bonds of existence by perseverance, self-exertion, and insight. It was the Buddha who for the first time in the world's history taught that deliverance could be attained independently of an external agency, that deliverance from suffering must be wrought and fashioned by each one for himself upon the anvil of his own actions.

None can grant deliverance to another who merely begs for it. Others may lend us a helping hand by guidance and instruction and in other ways, but the highest freedom is attained only through self-realization and self-awakening to truth and not through prayers and petitions to a Supreme Being, human or divine. The

Buddha warns his disciples against shifting the burden to an external agency, directs them to the ways of discrimination and research, and urges them to get busy with the real task of developing their inner forces and qualities.

# Dhamma Terminology ពាក្យសព្ទព្រះធម៌

**Final triumph, final victory (of the Buddha) ជ័យជម្នះចុងក្រោយ** (**មារវិជ័យ**)

Bodhi Tree (Tree of Enlightenment, Tree of Wisdom) ដើមពោធិ, ពោធិព្រឹក្ស

Devotion, Conviction, Confidence សទ្ធា សេចក្តីជ្រះថ្លា ជំនឿ

first watch of the night បឋមយាមនៃរាត្រី

threefold knowledge (Tevijjā, Trividyā) វិជ្ជា ៣

round of birth, cycle of life (Saṃsāra) សំសារវដ្ត

craving, attachment, thirst, desire តណ្ហា

suffering (Dukkha) ទុក្ខៈ សេចក្តីទុក្ខ

the arising of suffering (Dukkhasamudaya) ទុក្ខសមុទយៈ ការកើតឡើងនៃទុក្ខ

the cessation of suffering (Dukkhanirodha) ទុក្ខនិរោធៈ ការរលត់ទៅនៃទុក្ខ

the path leading to the cessation of suffering (Dukkhanirodhagāminīpaṭipadā)
ទុក្ខនិរោធគាមិនីបដិបទា មាគ៌ានាំទៅរកការរំលត់(រម្លត់)ទុក្ខ

mindfulness of in-and-out breathing (Ānāpaṇassati) អានាបាណស្សតិកម្មដ្ឋាន

meditative absorption, trance, recueillement (Jhāna, Dhyāna) ឈាន (សមាធិ)

cleaning mind of impurities សម្អាតចិត្តចាកគ្រឿងសៅហ្មងទាំងឡាយ (កិលេស)

knowledge of recollecting past births (Pubbenivāsānussatiñāṇa)
បុព្វេនិវាសានុស្សតិញាណ

knowledge of the disappearing and reappearing of beings (Cutūpapātañāṇa)
ចុតូបបាតញាណ

knowledge of the eradication of the taints (Āsavakkhayaññāṇa) អាសវក្ខយញ្ញាណ

defilement, canker, fermentation, influx (Āsava) អាសវៈ គ្រឿងត្រាំធ្វើឱ្យចិត្តស្រវឹង

defilements of sense pleasures (Kāmāsava) កាមាសវៈ

Eternal Verities អមតធម៌ (សច្ចធម៌)

Consummate Master-Physician មហាវេជ្ជបណ្ឌិត

cure the ills of beings ព្យាបាលជំងឺរបស់សព្វសត្វ

priceless message សារ ឬវចនៈដែលមិនអាចកាត់ថ្លៃបាន

respect and reverence ការគោរព និងការធ្វើសក្ការៈ

supernatural being សត្វដែលហួសវិស័យធម្មជាតិ

an incarnation of God អាវតារនៃព្រះអាទិទេព

mythological figure តួអង្គក្នុងរឿងព្រេងបុរាណ

extraordinary man (Acchariya manussa) មនុស្សអស្ចារ្យ (អច្ឆរិយមនុស្សៈ)

a unique being, a man par excellence (Purisuttama) ឧត្តមបុរស

supremacy of man អធិបតីភាពរបស់មនុស្ស

unremitting energy សេចក្តីព្យាយាមឥតឈប់ឈរ

acme of purity កម្រិតកំពូលនៃភាពបរិសុទ្ធ

embodiment of compassion and wisdom តំណាង ឬគំរូនៃករុណា និងបញ្ញា

Dispensation (Sāsanā) សាសនា (សាសនព្រហ្មចរិយធម៌)

perseverance, endeavour, effort, exertion, persistence (Vīriya) វីរិយភាព ការព្យាយាម

kernel of revealed religion ស្នូលឬខ្លឹមសារសំខាន់នៃសាសនាដែលបានលាតត្រដាង

bond of existence ចំណងនៃជាតិកំណើត (ចំណងភព ចំណងសំសារវដ្ត)

self-realization and self-awakening ការត្រាស់ដឹងដោយព្រះអង្គឯង

# ជ័យជម្នះចុងក្រោយ

ព្រះអង្គគង់ពែនភ្នែននៅក្រោមដើមឈើមួយ ដែលក្រោយមកត្រូវបានស្គាល់ថាជាដើមពោធិ៍ ឬពោធិព្រឹក្ស "ដើមឈើនៃការត្រាស់ដឹង" ឬ "ដើមឈើនៃបញ្ញា" នៅមាត់ស្ទឹងនេរញ្ជរា (Nerañjarā) នៅដែនគយា (សព្វថ្ងៃហៅថា ពុទ្ធគយា Buddhagayā) ដោយវិរិយភាពចុងក្រោយជាមួយការអធិដ្ឋានចិត្តមិនផ្លាស់ប្តូរ "ទោះបីអាត្មាអញនៅសល់តែស្បែក សរសៃ និងឆ្អឹង ហើយឈាម និងសាច់របស់អាត្មាអញរីងស្ងួត ក្រៀមស្វិតយ៉ាងណាក៏ដោយ អាត្មាអញនឹងមិនក្រោកចាកអាសនៈឡើយ លុះត្រាតែអាត្មាអញបានសម្រេចសម្មាសម្ពោធិ (sammā-sambodhi)។" ដោយសេចក្តីព្យាយាមមិនខ្លាចនឿយហត់ ដោយមិនងាករេ ក្នុងសទ្ធារបស់ព្រះអង្គ ដោយក្តីអធិដ្ឋានដើម្បីចាក់ធ្លុះនូវសច្ចធម៌ការត្រាស់ដឹងដោយបរិបូណ៌ (សម្មាសម្ពោធិញ្ញាណ)។

ដោយការចម្រើននូវអានាបាណស្សតិកម្មដ្ឋាន (ānāpāṇassati) ព្រះពោធិសត្វបានចូលទៅកាន់ និងអាស្រ័យនៅក្នុងបឋមជ្ឈាន (ឈានទី១)។ តាមលំដាប់ ព្រះអង្គបានចូលទៅកាន់ទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈាន។ ទ្រង់បានបន្សុទ្ធចិត្តចាកគ្រឿងសៅហ្មងទាំងឡាយ ស្ថិតក្នុងសេចក្តីបរិសុទ្ធបែបនេះ ទ្រង់បានផ្គងចិត្តចូលទៅកាន់ញាណ ឬវិជ្ជាដែលរលឹកនូវអតីតៈ (បុព្វេនិវាសានុស្សតិញាណ pubbenivāsānussati-ñāṇa) ។ នេះគឺជាវិជ្ជាទី១ ដែលព្រះអង្គបានសម្រេចក្នុងបឋមយាមនៃរាត្រី។ បន្ទាប់មក ព្រះពោធិសត្វបានបង្អោនចិត្តទៅកាន់ញាណ ឬវិជ្ជាដែលរលឹកដឹងនូវការចុតិ និងបដិសន្ធិ នៃសព្វសត្វគ្រប់ប្រភេទ គ្រប់ជាតិកំណើត ក្នុងសុគតិភព និងទុគ្គតិភព ដែលខុសគ្នាទៅតាមទង្វើកម្មរៀងៗខ្លួន (ចុតូបបាតញ្ញាណ cutūpapātaññāṇa) ។ នេះគឺជាវិជ្ជាទី២ ដែលព្រះអង្គបានសម្រេចក្នុងមជ្ឈិមយាមនៃរាត្រី។ បន្ទាប់មកទៀត ព្រះពោធិសត្វបានបង្អោនចិត្តទៅកាន់ញាណ ឬវិជ្ជាដែលអស់ទៅ សូន្យទៅនៃអាសវៈទាំងឡាយ (អាសវក្ខយញ្ញាណ āsavakkhayaññāṇa)។

ព្រះអង្គទ្រង់ជ្រាបយ៉ាងជាក់ច្បាស់តាមសភាវៈពិត "នេះគឺជាទុក្ខ (dukkha) នេះគឺជាការកើតឡើងនៃទុក្ខ នេះគឺជាការរំលត់ទុក្ខ នេះគឺជាមាគ៌ានាំទៅរកការរំលត់ទុក្ខ។" ព្រះអង្គទ្រង់ជ្រាបយ៉ាងជាក់ច្បាស់តាមសភាវៈពិត "នេះគឺជាអាសវកិលេស (āsava គ្រឿង

ត្រាំធ្វើអោយចិត្តស្រវឹង) នេះជាការកើតឡើងនៃអាសវកិលេស នេះជាការរំលត់ទៅនៃអាសវកិលេស នេះជាមាគ៌ានាំទៅរកការរំលត់នូវអាសវកិលេស" ។

បានជ្រាបដូច្នេះ បានឃើញដូច្នេះ ចិត្តរបស់ព្រះអង្គបានរួចស្រឡះចាកកាមាសវៈ (kāmāsava) ភវាសវៈ (bhavāsava) និង អវិជ្ជាសវៈ (avijjāsava)។ នៅពេលព្រះទ័យព្រះអង្គបានរួចរដោះទាំងស្រុងហើយ ញាណក៏កើតឡើង "អាត្មាអញបានរួចរដោះហើយ" ហើយទ្រង់ជ្រាបថា "ជាតិកំណើតត្រូវបានផ្តាច់ឫសគល់ហើយ ព្រហ្មចរិយធម៌ (brahmacariya) អាត្មាអញបានរស់នៅហើយ អ្វីដែលត្រូវធ្វើបានធ្វើរួច មិនមានអ្វីដែលត្រូវធ្វើទៀតឡើយ" (មានន័យថា មិនមានការបន្តនៃនាមរូប មិនមានការបន្តនៃភព និងជាតិកំណើតទៀតឡើយ)។ នេះគឺជាវិជ្ជាទី៣ ដែលព្រះអង្គបានសម្រេចក្នុងបច្ឆិមយាមជាយាមចុងក្រោយនៃរាត្រី។ នេះត្រូវបានគេស្គាល់ថាជា តេវិជ្ជា (tevijjā) គឺវិជ្ជាប្រកបដោយអង្គ៣។

គ្រានោះឯង ព្រះអង្គទ្រង់បន្លឺនូវបឋមវចនៈ(វិជយវចនៈ) ដូចតទៅ៖

"តថាគតបានខំស្វែងរកនូវជាងធ្វើផ្ទះ តែរកមិនឃើញ
តថាគតបានអន្ទោលទៅអស់ជាតិជាច្រើន៖
ជាតិជាទុក្ខ ម្តងហើយម្តងទៀត
ម្នាលជាងផ្ទះ អ្នកត្រូវបានតថាគតឃើញហើយ
អ្នកនឹងមិនអាចសាងសង់នូវផ្ទះគឺអត្តភាពនេះតទៀតឡើយ
ធ្នឹមផ្ទះ(គ្រោងផ្ទះ)របស់អ្នកត្រូវបានកាច់បំបាក់អស់ហើយ
ព្រំដំបូលផ្ទះ(អវិជ្ជា)របស់អ្នកក៏ត្រូវបានបំផ្លាញអស់ហើយដែរ
ចិត្តតថាគតពេលនេះ បានពាល់ត្រូវនូវព្រះនិព្វានដែលជាអសង្ខតៈ
ហើយបានទៅដល់ទីបញ្ចប់នៃតណ្ហា ដែលជាប្រភពនៃទុក្ខទាំងពួង។"

ដូច្នេះ ព្រះពោធិសត្វគោតម នៅព្រះជន្ម **៣៥ ព្រះវស្សា នាថ្ងៃពេញបូរណ៌មី ខែឧសភា** (**វិសាខ**) **បានសម្រេចនូវអភិសម្មាសម្ពោធិញ្ញាណ** ដោយការពិចារណាយ៉ាងពិស្តារ ល្អិតល្អន់ក្នុងអរិយសច្ចៈ៤ អមតៈធម៌ ហើយព្រះអង្គបានត្រាស់ដឹងក្លាយជាព្រះសម្មា- សម្ពុទ្ធ ជាអ្នកព្យាបាលដ៏អស្ចារ្យ ជាមហាវេជ្ជបណ្ឌិតដែលអាចព្យាបាលជំងឺនៃសព្វសត្វឱ្យជាសះស្បើយបាន។ នេះគឺជាជ័យជម្នះដ៏អស្ចារ្យមហិមាមិនរង្គោះរង្គើ។

ចតុរារិយសច្ចៈ ឬអរិយសច្ចៈ៤ គឺជាសារមិនអាចកាត់ថ្លៃបានដែលព្រះ-សម្មាសម្ពុទ្ធ ទ្រង់ប្រទានដល់មនុស្សជាតិដែលកំពុងរងទុក្ខសម្រាប់ជាមគ្គុទេសក៍នាំផ្លូវពួកគេឱ្យបានរួចពីចំណងនៃសេចក្តីទុក្ខ ហើយឱ្យបានសម្រេចនូវបរមសុខ ដែលជាបរមត្ថសច្ច ពោលគឺព្រះនិព្វាន។

សច្ចធម៌នេះ មិនមែនជាការបង្កើតរបស់ព្រះអង្គឡើយ។ ព្រះអង្គគ្រាន់តែបានរកឃើញនូវអ្វីដែលមានស្រាប់រួចមកហើយ។ ដូច្នេះហើយទើបយើងយកព្រះពុទ្ធ ជាបុគ្គលមួយព្រះអង្គដែលគួរដល់ការគោរពនិងបូជា មិនមែនគ្រាន់តែជាគ្រូ ប៉ុន្តែជាគំរូនៃអរិយបុគ្គល ជាបុគ្គលដែលមានការលះបង់ខ្លួនខ្ពស់ និងជីវិតដែលប្រកបដោយសមាធិ យើងគួរយកគំរូតាម ប្រសិនបើប្រាថ្នាដើម្បីអភិវឌ្ឍខ្លួន។

លក្ខណៈដ៏គួរឱ្យកត់សម្គាល់មួយ ដែលញែកព្រះពុទ្ធឱ្យពិសេសប្លែកពីគ្រូនៃសាសនាដទៃគឺថា **ព្រះពុទ្ធជាមនុស្ស** មិនមានខ្សែស្រឡាយជាមួយព្រះអាទិទេព ឬបុគ្គលអស្ចារ្យណាមួយឡើយ។ ព្រះអង្គមិនមែនជាអាទិទេព ឬជាអវតានៃអាទិទេព ឬជាព្យាការី (prophet) ឬក៏ជាតួអង្គក្នុងរឿងព្រេងបុរាណឡើយ ។ ព្រះអង្គជាមនុស្ស ប៉ុន្តែជាមនុស្សអស្ចារ្យ(អច្ឆរិយមនុស្សៈ) ជាបុគ្គលល្អដាច់គេ ជាឧត្តមបុរស(បុរិសុត្តមៈ)។ សមិទ្ធផលទាំងអស់របស់ព្រះអង្គ ជាគុណសម្បត្តិដែលកើតឡើងដោយសារការប្រឹងប្រែង និងការយល់ដឹងរបស់ព្រះអង្គក្នុងភាពជាមនុស្សសុទ្ធសាធ។ តាមរយៈបទពិសោធន៍ផ្ទាល់ ព្រះអង្គបានឈ្វេងយល់ពីអធិបតីភាពរបស់មនុស្ស។

អាស្រ័យទៅលើការព្យាយាមដោយឥតឈប់ឈររបស់ព្រះអង្គ ដោយឥតមានជំនួយពីគ្រូបាអាចារ្យ មនុស្ស ឬទេវតាណាឡើយ ព្រះអង្គបានសម្រេចនូវការត្រាស់ដឹងខាងផ្លូវចិត្ត និងផ្លូវបញ្ញាយ៉ាងខ្ពស់បំផុត ហើយបានដល់នូវកម្រិតកំពូលនៃសេចក្តីបរិសុទ្ធបរិបូណ៌នៅក្នុងគុណសម្បត្តិដ៏ប្រសើរបំផុតនៃអត្តភាពជាមនុស្ស។ ព្រះអង្គជាតំណាង ឬគំរូនៃ **ករុណា និង បញ្ញា** ដែលគោលធម៌ទាំង២នេះ បានក្លាយទៅជាគោលការណ៍មគ្គុ-ទេសក៍នៅក្នុងសាសនៈរបស់ព្រះអង្គ (Sāsana : Dispensation) ។

ព្រះពុទ្ធមិនដែលបានប្រកាសអះអាងថា ព្រះអង្គជាអ្នកសង្គ្រោះដែលព្យាយាមជួយស្រោចស្រង់នូវ "ព្រលឹង" តាមវិធីនៃសាសនាដែលបានលាតត្រដាងមកឡើយ។ ប្រកបដោយសេចក្តីអត់ធន់ និងការយល់ដឹងរបស់ព្រះអង្គផ្ទាល់ ទ្រង់បានបង្ហាញនូវ

សក្កានុពលឥតដែនកំណត់ដែលពួនសម្ងំនៅក្នុងមនុស្ស ដូច្នេះហើយមានតែសេចក្តីព្យាយាមរបស់មនុស្សហ្នឹងឯងដែលអាចអភិវឌ្ឍ និងគាស់កកាយស្រាយត្រដាងនូវលទ្ធភាពទាំងនោះ ។ ព្រះអង្គបានបង្ហាញតាមរយៈបទពិសោធន៍ផ្ទាល់របស់ព្រះអង្គថា ការរួចចាកទុក្ខ និងការត្រាស់ដឹង ឋិតនៅលើសេចក្តីព្យាយាមរបស់មនុស្សទាំងស្រុង។

"សាសនាដែលមានលក្ខណៈខ្ពង់ខ្ពស់ និងពេញលេញបំផុត អាចកើតឡើងជាមួយគ្នាដោយមិនចាំបាច់មានជំនឿអ្វីមួយឡើយ តាមន័យត្រង់នៃពាក្យ ហើយនៅក្នុងស្នូល ឬខ្លឹមសារសំខាន់នៃសាសនាដែលបានលាតត្រដាងមកនេះគឺ personal God។ ពាក្យថា "personal God" ខ្ញុំបានបញ្ចូលគំនិតទាំងអស់ដែលហៅថា "superpersonal god" មានធម្មជាតិផ្លូវចិត្តដូចគ្នា ជាបុគ្គលិកលក្ខណៈ ប៉ុន្តែឋិតនៅកម្រិតខ្ពស់ជាង ឬក៏ជាភាវៈផ្លូវចិត្ត ឬឋាមពលម្យ៉ាងដែលហួសវិស័យធម្មជាតិ (supernatural spiritual existence or force." ។ (ដកស្រង់ពីសៀវភៅនិពន្ធដោយ: Julian Huxley, Religion Without Revelation, pp 2, and 7)។

បុគ្គលម្នាក់ៗគួរតែតាំងនូវសេចក្តីព្យាយាមដ៏សមគួរ ដើម្បីកាត់បំបែកនូវច្រវាក់ដែលឃុំខ្លួនគេនៅក្នុងចំណង ហើយឈ្នះបាននូវសេរីភាពពីចំណងនៃអត្តភាព ដោយសេចក្តីព្យាយាម ប្រឹងប្រែង និងបញ្ញា។ គឺព្រះពុទ្ធដែលជាបុគ្គលដំបូងបំផុតក្នុងប្រវត្តិសាស្ត្រពិភពលោកដែលបានបង្រៀនថា ការរួចចាកទុក្ខ(វិមុត្តិ) អាចសម្រេចបានដោយមិនពឹងផ្អែកទៅលើភ្នាក់ងារ(វត្ថុសក្តិសិទ្ធិ)ខាងក្រៅឡើយ ពោលគឺការរួចចាកទុក្ខអាចធ្វើទៅបានដោយបុគ្គលរៀងៗខ្លួនទៅតាមទង្វើកម្មផ្ទាល់ខ្លួនរបស់ពួកគេ។

ឥតមានបុគ្គលណាឡើយ អាចផ្តល់នូវការរួចចាកទុក្ខដល់នរណាម្នាក់ ដោយគ្រាន់តែធ្វើការសុំបន់ស្រន់នោះទេ។ អ្នកដទៃអាចជួយបានត្រឹមតែការណែនាំ និងបង្ហាត់បង្រៀនតាមវិធីផ្សេងៗប៉ុណ្ណោះ ប៉ុន្តែសេរីភាពដ៏កំពូល អាចសម្រេចបានតាមរយៈការចាក់ធ្លុះ និងត្រាស់ដឹងនូវសច្ចធម៌ដោយខ្លួនឯងតែម្យ៉ាង មិនអាចសម្រេចទៅបានដោយការបន់ស្រន់ សុំព្រះអាទិទេព បុគ្គលអស្ចារ្យ មនុស្ស ឬទេវតាណាមួយឡើយ។ ព្រះពុទ្ធបានទូន្មានសាវ័កទាំងឡាយមិនឱ្យដាក់បន្ទុក ឬពឹងពាក់ទៅលើអ្វីខាងក្រៅឡើយ ដោយតម្រង់សាវ័ករបស់ទ្រង់ឱ្យចេះវែកញែកស្រាវជ្រាវរាវរក និងជំរុញឱ្យខំប្រឹងប្រែងបំពេញការងា

រដោយពិតប្រាកដក្នុងការអភិវឌ្ឍន៍នូវថាមពល និងគុណសម្បត្តិខាងក្នុងរបស់ពួកគេ។ ការយល់ដឹងចេះបែងចែកអ្វីល្អអ្វីអាក្រក់ ខំប្រឹងប្រែងជាមួយការងារពិតប្រាកដ។

## Misconceptions

There are some who take delight in making the Buddha a non-human. They quote a passage from the Anguttara Nikāya, mistranslate it, and misunderstand it. The story goes thus:

Once the Buddha was seated under a tree in the meditation posture, his senses calmed, his mind quiet, and attained to supreme control and serenity. Then a Brahmin, Dona by name, approached the
Buddha and asked:

"Sir, will you be a god, a deva?"

"No, brahmin."

“Sir, will you be a heavenly angel, a gandhabba?"

"No, brahmin."

"Sir, will you be a demon, a yakkha?"

"No, brahmin."

"Sir, will you be a human being, a manussa?"

"No, brahmin."

"Then, sir, what indeed will you be?"

Now understand the Buddha's reply carefully:

"Brahmin, whatever defilements (āsavas) there be owing to the presence of which a person may be identified as a god or a heavenly angel or a demon or a human being, all these defilements in me are abandoned, cut off at the root, made like a palm-tree stump, done away with, and are no more subject to future arising.

"Just as, brahmin, a blue or red or white lotus born in water, grows in water and stands up above the water untouched by it, so too I, who was born in the world and grew up in the world, have transcended the world, and I live untouched by the world. Remember me as one who is enlightened (Buddhoti maṃ dhārehi brāhmana)."

What the Buddha said was that he was not a god or a heavenly angel or a demon or a human being full of defilements. From the above it is clear that the

Buddha wanted the brahmin to know that he was not a human being with defilements. He did not want the brahmin to put him into any of those categories. The Buddha was in the world but not of the world. This is clear from the simile of the lotus. Hasty critics, however, rush to a wrong conclusion and want others to believe that the Buddha was not a human being. In the Aṅguttara Nikāya (I, 22), there is a clear instance in which the Buddha categorically declared that he was a human being:

"Monks, there is one person (puggala) whose birth into this world is for the welfare and happiness of many, out of compassion for the world, for the gain and welfare and happiness of gods (devas) and humanity. Who is this one person (eka puggala)? It is the Tathāgata, who is a Consummate One (arahat), a Supremely Enlightened One (sammā-sambuddho).. Monks, one person born into the world is an extra-ordinary man, a marvellous man (acchariya manussa)."

Note the Pāli word **manussa**, a human being. Yes, the Buddha was a human being but not just another man. He was a marvellous man.

The Buddhist texts say that the Bodhisatta (as he is known before he became the Buddha) was in the Tusita heaven (devaloka) but came down to the human world to be born as a human being (manussatta). His parents, King Suddhodana and Queen Mahāmāyā, were human beings.

The Bodhisatta was born as a man, attained enlightenment (Buddhahood) as a man, and finally passed away into parinibbāna as a man. Even after his Supreme Enlightenment he did not call himself a God or Brahma or any "supernatural being," but an extraordinary man.

Dr. S. Radhakrishnan, a Hindu steeped in the tenets of the Vedas and Vedanta, says that Buddhism is an offshoot of Hinduism, and even goes to the extent of calling the Buddha a Hindu. He writes:

“The Buddha did not feel that he was announcing a new religion. He was born, grew up, and died a Hindu. He was restating with a new emphasis the ancient ideals of the Indo-Aryan civilization.”

But the Buddha himself declares that his teaching was a revelation of truths discovered by himself, not known to his contemporaries, not inherited from past tradition. Thus, in his very first sermon, referring to the Four Noble Truths, he says: “Monks, with the thought “This is the noble truth of suffering, this is its cause, this is its cessation, this is the way leading to its cessation, there arose in me vision, knowledge, wisdom, insight, and light concerning things unheard of before (pubbesu ananussutesu dhammesu).”

Again, while making clear to his disciples the difference between a Fully Enlightened One and the arhats, the consummate ones, the Buddha says: “The Tathagata, O disciples, while being an arahat is fully enlightened. It is he who proclaims a way not proclaimed before, he is the knower of a way, who understands a way, who is skilled in a way (maggaññū, maggavidū, maggakovido). And now his disciples are wayfarers who follow in his footsteps.

The ancient way the Buddha refers to is the Noble Eightfold Path and not any ideals of the Indo-Arvan civilization as Dr. Radhakrishnan imagines.

However, referring to the Buddha, Mahatma Gandhi, the architect of Indian independence, says: “By his immense sacrifice, by his great renunciation and by the immaculate purity of his life, he left an indelible impress upon Hinduism, and Hinduism owes an eternal debt of gratitude to that great teacher” (Mahadev Desai, With Gandhiji in Ceylon, Madras, 1928, p.26.)

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| misconception | ការភាន់ច្រឡំ |
| delight | សេចក្ដីរីករាយជ្រះថ្លា សេចក្ដីពេញចិត្ត (សទ្ធា) |
| simile | ការប្រៀបធៀប ពាក្យប្រៀបធៀប |
| transcended the world | បានឆ្លងផុតពីលោក (មិនលុះក្នុងអំណាចនៃលោក) |
| passed away (Parinibbāna) | បរិនិព្វាន |
| first sermon | បឋមទេសនា |
| vision | ចក្ខុ |
| knowledge | វិជ្ជា |
| wisdom | បញ្ញា |
| insight | ញាណៈ |
| light | អាលោកៈ |
| Tathāgata | តថាគត |

he is the knower of a way (Maggaññū) ជាអ្នកដឹងនូវមគ្គ (មគ្គញ្ញូ)

he understands a way (Maggavidū) ជាអ្នកជ្រាបច្បាស់នូវមគ្គ (មគ្គវិទូ)

who is skilled in a way (maggakovido) ជាអ្នកស្ទាត់ជំនាញក្នុងមគ្គ (មគ្គកោវិទោ)

| | |
|---|---|
| wayfarer, traveler (on foot) | អ្នកធ្វើដំណើរ |
| footsteps | យុគលបាទ (ស្នាមព្រះបាទ ឬយកតម្រាប់តាម) |
| owes an eternal debt of gratitude | ជំពាក់នូវបំណុលគុណគ្មានទីបញ្ចប់ |

# ការត័ន្តច្រឡំ

មានមនុស្សមួយចំនួនដែលរីករាយជ្រះថ្លា ក្នុងការប្រដូចព្រះពុទ្ធទៅជាបុគ្គលផ្សេងក្រៅពីមនុស្ស។ គេបានដកស្រង់ឃ្លាមួយពីគម្ពីរអង្គុត្តរនិកាយ (II, 37) ដោយការបកប្រែមិនត្រឹមត្រូវ ។ តំណាលរឿងដូចតទៅៈ

ពេលមួយព្រះពុទ្ធបានគង់នៅក្រោមដើមឈើមួយ ក្នុងឥរិយាបថសមាធិ មានឥន្ទ្រីយ៍ស្ងប់រម្ងាប់ ព្រះទ័យស្ងាត់ស្ងៀម ហើយព្រះអង្គបានឋិតនៅក្នុងការគ្រប់គ្រងចិត្តដោយស្ងប់ស្ងាត់យ៉ាងក្រៃលែង។ គ្រានោះឯង ព្រាហ្មណ៍ម្នាក់ឈ្មោះ ទោនៈ បានចូលទៅគាល់ព្រះអង្គហើយទូលសួរថា:

"បពិត្រព្រះអង្គ តើព្រះអង្គជាព្រះអាទិទេពឬ?"

"មិនមែនទេ ព្រាហ្មណ៍"

"បពិត្រព្រះអង្គ តើព្រះអង្គជាទេវតា ឬជាគន្ធព្វ?"

"មិនមែនទេ ព្រាហ្មណ៍"

"បពិត្រព្រះអង្គ តើព្រះអង្គជាយក្សឬ?"

"មិនមែនទេ ព្រាហ្មណ៍"

"បពិត្រព្រះអង្គ តើព្រះអង្គជាមនុស្សឬ?"

"មិនមែនទេ ព្រាហ្មណ៍"

"ដូច្នេះ បពិត្រព្រះអង្គ តើព្រះអង្គជាអ្វីឱ្យពិតប្រាកដ?"

*ឥឡូវនេះ ចូរយើងស្វែងយល់ដោយប្រុងប្រយ័ត្នអំពីការបកស្រាយរបស់ព្រះពុទ្ធដូចតទៅ:*

"ម្នាលព្រាហ្មណ៍ អាសវៈឯណាមួយដែលអាចមានក្នុងបុគ្គលត្រូវបានគេចាត់ទុកថា ជាអាទិទេពក្តី ជាទេវតាក្តី ជាយក្សក្តី ឬជាមនុស្សក្តី អាសវៈទាំងអស់នោះនៅក្នុងតថាគត បានកំចាត់បង់អស់ហើយ បានកាត់ផ្តាច់ឫសគល់អស់ហើយ តថាគតបានធ្វើឱ្យដូចដើមត្នោតកំបុតក្បាល បានត្រូវគេកាត់ចេញ ដូច្នេះមិនអាចលូតលាស់ទៅថ្ងៃមុខទៀតទេ។

"ម្នាលព្រាហ្មណ៍ ដូចជា ផ្កាឈូកមានពណ៌ខៀវក្តី ក្រហមក្តី សក្តី ដែលដុះក្នុងទឹក ធំលូតលាស់ក្នុងទឹក និងងើបឡើងផុតពីទឹក មិនពាល់ត្រូវដោយទឹកយ៉ាងណា

តថាគតដែលបានកើតឡើងក្នុងលោក មានវ័យចម្រើនឡើងក្នុងលោក បានកន្លងផុតពីលោក ហើយតថាគតអាស្រ័យនៅដោយមិនមានការពាល់ត្រូវដោយលោកឡើយ។ ម្នាលព្រាហ្មណ៍ ចូរចងចាំនូវតថាគតជា "**បុគ្គលត្រាស់ដឹង**" (**ពុទ្ធោតិ មំ ធារេហិ ព្រាហ្មណ**)។

អ្វីដែលព្រះអង្គបានសំដែង គឺថាព្រះអង្គមិនមែនជាអាទិទេព ឬជាទេវតា ឬជាយក្ស ឬជាមនុស្ស ដែលពោរពេញដោយអាសវៈកិលេសឡើយ។ ការរៀបរាប់ខាងលើនេះបានបង្ហាញយ៉ាងច្បាស់គឺ ព្រះពុទ្ធមានបំណងឱ្យព្រាហ្មណ៍ដឹងច្បាស់ថា ព្រះអង្គមិនមែនជាមនុស្សដែលនៅមានកិលេសនោះទេ។ ព្រះអង្គមិនចង់ឱ្យព្រាហ្មណ៍ចាត់ទុកព្រះអង្គក្នុងចំណោមបុគ្គលទាំងនោះដែលពោរពេញដោយអាសវៈកិលេសឡើយ។

ព្រះពុទ្ធបានកើតឡើងក្នុងលោក ប៉ុន្តែព្រះអង្គមិនលុះក្នុងវិស័យនៃលោកនេះទេ។ នេះកាន់តែជាក់ច្បាស់ ដោយសេចក្តីប្រៀបធៀបនៃផ្កាឈូក។

ទោះបីយ៉ាងណាក៏ដោយ បុគ្គលខ្លះឆាប់ធ្វើការសន្និដ្ឋានទាំងខុស ហើយចង់ឱ្យអ្នកដទៃជឿថាព្រះពុទ្ធមិនមែនជាមនុស្ស។

នៅក្នុងគម្ពីរអង្គុត្តរនិកាយ មានឧទាហរណ៍ជាក់ស្តែងមួយដែលព្រះពុទ្ធបានប្រកាសយ៉ាងជាក់ច្បាស់ថា ព្រះអង្គគឺជាមនុស្ស។

"**ម្នាលភិក្ខុទាំងឡាយ មានបុគ្គលមួយរូប ដែលការកើតឡើងរបស់បុគ្គលនោះក្នុងលោកនេះ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនច្រើនគ្នា ដោយព្រះទ័យករុណាចំពោះលោក ដើម្បីលាភ និងប្រយោជន៍ ព្រមទាំងសេចក្តីសុខនៃទេវតា និងមនុស្សទាំងឡាយ។ តើបុគ្គលរូបនោះជានរណា? គឺតថាគត ដែលជាព្រះអរហន្តសម្មាសម្ពុទ្ធ ហ្នឹងឯង។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមួយរូបដែលកើតឡើងក្នុងលោកនេះ គឺជាមនុស្សអស្ចារ្យ អច្ឆរិយមនុស្សៈ។**"

ចូរកត់ចំណាំពាក្យបាលី **មនុស្សៈ** សំដៅយក មនុស្សហ្នឹងឯង។ ពិតណាស់ ព្រះពុទ្ធគឺជាមនុស្ស ប៉ុន្តែមិនមែនត្រឹមជាមនុស្សធម្មតាទេ គឺជាអច្ឆរិយមនុស្ស។

នៅក្នុងគម្ពីរព្រះពុទ្ធសាសនាបានសំដែងថា ព្រះពោធិសត្វ (ដែលគេបានស្គាល់មុនក្លាយជាព្រះពុទ្ធ) បានគង់នៅឋានតុសិត (ទេវលោក ជាន់ទី៤) ប៉ុន្តែបានចុះមកឋានមនុស្ស ដើម្បីបដិសន្ធិជាមនុស្ស (មនុស្សសត្ត)។ ព្រះបិតាព្រះមាតាគឺ ព្រះបាទសុទ្ធោទនៈ និង ព្រះនាងមហាមាយា ក៏ជាមនុស្សសុទ្ធសាធ។

ព្រះពោធិសត្វបានប្រសូតិជាមនុស្ស បានត្រាស់ដឹងក្នុងអត្តភាពជាមនុស្ស ហើយចុងក្រោយបានបរិនិព្វានក្នុងអត្តភាពជាមនុស្ស ។ ទោះបីបន្ទាប់ពីព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញាណ ព្រះអង្គមិនបានហៅខ្លួនព្រះអង្គថាជាអាទិទេព ឬជាព្រហ្ម ឬជា "បុគ្គលដែលហួសវិស័យធម្មជាតិឡើយ (supernatural being)" ប៉ុន្តែព្រះអង្គគឺជាអច្ឆរិយមនុស្ស។

Dr. S. Radhakrishnan ជាសាសនិកហិណ្ឌូ ដែលស្ទាត់ជំនាញក្នុងគម្ពីរវេទៈ និងវេទន្តៈ (Vedas and Vedanta) បាននិយាយថា ពុទ្ធសាសនាជាពន្លកនៃហិណ្ឌូសាសនា ហើយបានឈានដល់ចំណុចមួយដែលហៅព្រះពុទ្ធថា ហិណ្ឌូទៀតផង។ លោកបានសរសេរថា៖

"ព្រះពុទ្ធមិនបានគិតថា ព្រះអង្គកំពុងប្រកាសនូវសាសនាថ្មីឡើយ។ ព្រះអង្គបានប្រសូតិ ចម្រើនវ័យ និងបរិនិព្វាន ជាអ្នកកាន់សាសនាហិណ្ឌូ។ ព្រះអង្គបានសម្តែងឡើងវិញជាមួយវិធីសាស្ត្រថ្មី នូវលទ្ធិបុរាណនៃវប្បធម៌ដ៏រុងរឿងរបស់ឥណ្ឌូ-អារ្យៈ។"

ប៉ុន្តែព្រះពុទ្ធផ្ទាល់ បានប្រកាសសម្តែងថា ការបង្រៀនរបស់ព្រះអង្គគឺជាការបើកបង្ហាញនូវសច្ចធម៌ដែលបានរកឃើញដោយព្រះអង្គឯង មិនត្រូវបានមនុស្សក្នុងសម័យនោះស្គាល់ឡើយ ហើយក៏មិនមែនជាមរតកប្រពៃណីតមកពីបុរាណដែរ។ ហេតុដូច្នេះ នៅក្នុងបឋមទេសនារបស់ព្រះអង្គ ផ្អែកលើអរិយសច្ចៈ៤ ទ្រង់សម្តែងថាៈ "**ម្នាលភិក្ខុទាំងឡាយ ដោយការពិចារណាបែបនេះ "នេះគឺជា ទុក្ខអរិយសច្ចៈ នេះគឺជា ទុក្ខសមុទយអរិយសច្ចៈ នេះគឺជា ទុក្ខនិរោធអរិយសច្ចៈ នេះគឺជា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ**" ពេលនោះចក្ខុបានកើតឡើងហើយ វិជ្ជាបានកើតឡើងហើយ បញ្ញាបានកើតឡើងហើយ ញាណបានកើតឡើងហើយ ពន្លឺភ្លឺស្វាងបានកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានឮពីមុនមក (**បុព្វេសុ អននុស្សុតេសុ ធម្មេសុ**)។"

ជាថ្មីទៀត ព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់ទៅកាន់សាវ័កទាំងឡាយអំពីភាពខុសគ្នារវាងព្រះសម្មាសម្ពុទ្ធ និងព្រះអរហន្ត ទ្រង់សម្តែងថា៖"ម្នាលសាវ័កទាំងឡាយ តថាគត ពេលបានជាព្រះអរហន្តក៏បានជាព្រះសម្មាសម្ពុទ្ធដែរ(ត្រាស់ដឹងដោយបរិបូរណ៍) ។ គឺជាបុគ្គលដែលប្រកាសសម្តែងនូវមគ្គដែលគេមិនធ្លាប់ប្រកាសសម្តែងពីមុនមក ជាអ្នកជ្រាបច្បាស់នូវ

មគ្គ(មគ្គញ្ញូ) ជាអ្នកស្គាល់នូវមគ្គ(មគ្គវិទូ) ជាអ្នកស្ទាត់ក្នុងមគ្គ(មគ្គកោវិទោ)។ ហើយឥឡូវនេះ សាវ័កទាំងឡាយ ជាអ្នកដើរតាមយុគលបាទរបស់ព្រះតថាគតនោះ។”

មាគ៌ាបុរាណដែលព្រះពុទ្ធទ្រង់សំដៅនោះគឺ អរិយអដ្ឋង្គិមគ្គ (ផ្លូវដ៏ប្រសើរប្រកបដោយអង្គ៨) មិនមែនជាលទ្ធិនៃវប្បធម៌ឥណ្ឌូ-អារ្យៈ ដូចលោក Dr. Radha-krishnan បានស្រមើស្រមៃឡើយ។

ទោះបីយ៉ាងណា សំដៅទៅលើព្រះពុទ្ធ **មហាត្មៈគន្ធី ជាស្ថាបត្យករនៃឯករាជ្យភាពឥណ្ឌា** បាននិយាយថា៖ “ដោយការលះបង់ដ៏មហិមារបស់ព្រះពុទ្ធ ដោយអភិនេស្រ្កមណ៍ និងដោយសេចក្តីបរិសុទ្ធនៃជីវិតរបស់ព្រះអង្គ ទ្រង់បានបន្សល់នូវចំណាប់អារម្មណ៍ដែលមិនអាចលុបបានចំពោះហិណ្ឌូសាសនា ហើយហិណ្ឌូសាសនាបានជំពាក់នូវបំណុលអមតៈមួយ គឺកតញ្ញូចំពោះមហាសាស្តាអង្គនោះជារៀងរហូត។”

*(Mahādev Desai, With Gandhiji in Ceylon, Madras, 1928, p.26.)*

# Dependent Arising

For a week, immediately after the enlightenment, the Buddha sat at the foot of the Bodhi Tree, experiencing the supreme bliss of emancipation. At the end of the seven days he emerged from that concentration (samādhi) and in the first watch of the night thought over the dependent arising (paṭiccasamuppāda) as to how things arise (anuloma) thus:

"When this is, that comes to be; with the arising of this, that arises; namely: dependent on ignorance, volitional or kamma formations; dependent on volitional formations, (rebirth or rebecoming) consciousness; dependent on consciousness, mentality-materiality (mental and physical combination); dependent on mentality-materiality, the sixfold base (the five physical sense organs with consciousness as the sixth); dependent on the sixfold base, contact; depend on contact, feeling; dependent on feeling, craving; dependent on craving, clinging; dependent on clinging, the process of becoming; dependent on the process of becoming, there comes to be birth; dependent on birth arise ageing and death, sorrow, lamentation, pain, grief, and despair. Thus does this whole mass of suffering arise."

In the second watch of the night, the Buddha thought over the dependent arising as to how things cease (patiloma) thus: "When this is not, that does not come to be; with the cessation of this, that ceases; namely: with the utter cessation of ignorance, the cessation of volitional formations; with the cessation of formations, the cessation of consciousness…(and so on). Thus does this whole mass of suffering cease."

In the third watch of the night, the Buddha thought over the dependent arising both as to how things arise and cease thus:

"When this is, that comes to be; with the arising of this, that arises; when this is not, that does not come to be; with the cessation of this, that ceases; namely: dependent on ignorance, volitional formations... (and so on). Thus does this whole

mass of suffering arise. With the utter cessation of ignorance, the cessation of volitional formations... (and so on). Thus does this whole mass of suffering cease.

The Buddha now spent six more weeks in lonely retreat at six different spots in the vicinity of the Bodhi Tree. At the end of this period two merchants, Tapussa and Bhallika, who were passing that way, offered rice cake and honey to the Master, and said: “We go for refuge to the Buddha and to the Dhamma. Let the Blessed One receive us as his followers. They became his first lay followers (upāsakas).

# Dhamma Terminology វាក្យសព្ទព្រះធម៌

**Dependent Arising, Dependent Origination, Interdependent Co-arising, The Law of Causation, Conditioned Genesis, Causal Genesis**

**បដិច្ចសមុប្បាទ ធម៌ដែលអាស្រ័យគ្នាកើតឡើង**

ignorance អវិជ្ជា

volitional actions/activities, kamma-formations, fabrications សង្ខារា

consciousness (rebirth, rebecoming) វិញ្ញាណ

mind and matter, mentality and materiality, mental and physical combination នាមរូប

sixfold (sense) base, six faculties, six sense-medias សឡាយតនៈ

contact, sensorial and mental contact ផស្សៈ

feeling, sensation វេទនា

craving, desire, thirst, attachment តណ្ហា

clinging, grasping ឧបាទានៈ

process of becoming ភវៈ

birth ជាតិ

ageing, death, sorrow, lamentation, pain, grief, and despair

ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និង ឧបាយាសៈ

supreme bliss of emancipation វិមុត្តិសុខ

arise កើត; cease រលត់

lay follower (Upāsaka) ឧបាសក, lay devotees, laypeople ឧបាសក ឧបាសិកា

the Blessed One (Bhagavā) ភគវា: ព្រះមានព្រះភាគ ព្រះមានជោគ ព្រះមានបុណ្យ

# បដិច្ចសមុប្បាទ

រយៈពេលមួយសប្តាហ៍ រំពេចនោះ ក្រោយបានត្រាស់ដឹងហើយ ព្រះសម្មាសម្ពុទ្ធ បានគង់នៅទៀបគល់ដើមពោធិព្រឹក្ស ទ្រង់សោយនូវវិមុត្តិសុខ។ នៅថ្ងៃចុងក្រោយនៃសប្តាហ៍ទី១ ព្រះអង្គបានចេញពីសមាធិ ក្នុងបឋមយាមនៃរាត្រី ទ្រង់ពិចារណានូវបដិច្ចសមុប្បាទធម៌ អំពីការកើតឡើងនៃសភាវៈទាំងឡាយ ជាអនុលោមន័យ មានសេចក្តីដូចតទៅ៖

"**នេះមាន នោះមាន។ នេះកើត នោះកើត។** មានដូចជា៖ អវិជ្ជា នាំឱ្យមានសង្ខារ។ សង្ខារ នាំឱ្យមានវិញ្ញាណ ។ វិញ្ញាណ នាំឱ្យមាននាមរូប (នាមនិងរូបផ្សំគ្នា)។ នាមរូប នាំឱ្យមានសឡាយតនៈ (អាយតនៈ៦ = ប្រាសាទរូប៥ និង វិញ្ញាណ១ ដែលជាអាយតនៈទី៦)។ សឡាយតនៈ នាំឱ្យមានផស្សៈ។ ផស្សៈ នាំឱ្យមានវេទនា។ វេទនា នាំឱ្យមានតណ្ហា។ តណ្ហា នាំឱ្យមានឧបាទាន។ ឧបាទាន នាំឱ្យមានភវៈ។ ភវៈ នាំឱ្យមានជាតិ។ ជាតិ នាំឱ្យមានជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និង ឧបាយាសៈ។ តាមរបៀបនេះឯង ដែលកងទុក្ខកើតឡើង។"

នៅក្នុងយាមទី២នៃរាត្រី (មជ្ឈិមយាម) ព្រះពុទ្ធបានពិចារណានូវបដិច្ចសមុប្បាទ តើសភាវធម៌ទាំងឡាយរលត់ទៅដូចម្តេច ជាបដិលោមន័យ ដូចតទៅ៖

"**នេះមិនមាន នោះក៏មិនមាន។ នេះរលត់ នោះក៏រលត់។** មានឈ្មោះដូចតទៅ៖ ដោយការលត់ទៅទាំងស្រុងនៃអវិជ្ជា ក៏ជាការរលត់ទៅនៃសង្ខារទាំងឡាយ។ ដោយការរលត់ទាំងស្រុងនូវសង្ខារទាំងឡាយ ក៏ជាការរលត់ទៅនៃវិញ្ញាណ....(។ល។) តាមរបៀបនេះឯង ដែលកងទុក្ខរលត់សាបសូន្យ។"

នៅក្នុងយាមទី៣នៃរាត្រី (បច្ឆិមយាម) ព្រះពុទ្ធបានពិចារណានូវបដិច្ចសមុប្បាទ ដោយន័យទាំងពីរ ថាតើធម៌ទាំងឡាយកើតនិងរលត់ដោយរបៀបណា ដូចតទៅ៖

"**នេះមាន នោះមាន។ នេះកើត នោះកើត។ នេះមិនមាន នោះមិនមាន។ នេះរលត់ នោះរលត់។** ដូចតទៅ៖ អាស្រ័យដោយអវិជ្ជា សង្ខារទាំងឡាយកើតមាន ។ល។

តាមរបៀបនេះឯងដែលកងទុក្ខទាំងពួងកើតឡើង។ ដោយការរលត់ទៅទាំងស្រុងនៃអវិជ្ជា សង្ខារទាំងឡាយក៏រលត់ ។ល។ តាមរបៀបនេះឯងដែលកងទុក្ខទាំងពួងរលត់ទៅ ។

ព្រះពុទ្ធ ឥឡូវនេះបានចំណាយរយៈពេល ៦ សប្តាហ៍ទៀតក្នុងកម្មដ្ឋាន នៅកន្លែងផ្សេងៗគ្នា មិនឆ្ងាយប៉ុន្មានពីពោធិព្រឹក្សឡើយ។ ក្រោយរយៈពេល ៧ សប្តាហ៍បានបញ្ចប់ទៅ ឈ្មួញពីរនាក់ឈ្មោះ តបុស្សៈ និង ផល្លិកៈ ដែលបានឆ្លងកាត់ទីនោះ បានប្រគេនសាដូវ និងទឹកឃ្មុំដល់ព្រះបរមសាស្តា ហើយបានពោលថា "យើងខ្ញុំព្រះអង្គទាំងឡាយ សូមដល់នូវព្រះពុទ្ធ និងព្រះធម៌ជាទីពឹង។ សូមព្រះដ៏មានបុណ្យទទួលនូវយើងខ្ញុំព្រះអង្គជាឧបាសកផងចុះ។" ពួកគេ បានក្លាយជាឧបាសក ឬសាវ័កដំបូងគេរបស់ព្រះអង្គ (ដែលបានទទួលនូវទ្វេវាចកៈសរណគមន៍)។

## The First Sermon

Now while the Blessed One dwelt in solitude this thought occurred to him: "The Dhamma I have realized is deep, hard to see, hard to understand, peaceful and sublime, beyond mere reasoning, subtle, and intelligible to the wise. But this generation delights, revels, and rejoices in sensual pleasures. It is hard for such a generation to see this conditionality, this dependent arising. Hard too is it to see this calming of all conditioned things, the giving up of all substance of becoming, the extinction of craving, dispassion, cessation, Nibbāna. And if I were to teach the Dhamma and others were notto understand me, that would be a weariness, a vexation for me."

Pondering thus he was first reluctant to teach the Dhamma, but on surveying the world with his mental eye, he saw beings with little dust in their eyes and with much dust in their eyes, with keen faculties and dull faculties, with good qualities and bad qualities, easy to teach and hard to teach, some who are alive to the perils hereafter of present wrongdoings, and some who are not. The Master then declared his readiness to proclaim the Dhamma in this solemn utterance:

*"Apārutā tesaṃ amatassa dvārā*
*Ye sotavanto pamuñcantu saddhaṃ."*
*"Open are the doors of the Deathless.*
*Let those that have ears repose trust."*

When considering to whom he should teach the Dhamma first, he thought of Ālāra Kālāma and Uddaka Rāmaputta, his teachers of old; for he knew that they were wise and discerning. But that was not to be; they had passed away. Then the Blessed One made up his mind to make known the truth to those five ascetics, his former friends, still steeped in the fruitless rigours of extreme asceticism. Knowing that they were living at Benares in the Deer Park at Isipatana, the Resort of Seers (modern Sarnath), the Blessed One left Gay for distant Benares, walking by stages some 150 miles. On the way not far from Gayā the Buddha was met by Upaka, an

ascetic who, struck by the serene appearance of the Master, inquired: “Who is your teacher? Whose teaching do you profess?”

The Buddha replied: “I have no teacher, one like me does not exist in all the world, for I am the Peerless Teacher, the Arahat. I alone am Supremely Enlightened. Quenching all defilements, Nibbāna's calm have I attained. I go to the city of Kāsī (Benares) to set in motion the Wheel of Dhamma. In a world where blindness reigns, I shall beat the Deathless Drum.

“Friend, you then claim you are a universal victor” said Upaka. The Buddha replied: “Those who have attained the cessation of defilements, they are, indeed. victors like me. All evil have I vanquished. Hence I am a victor.”

Upaka shook his head, remarking sarcastically, “It may be so, friend,” and took a bypath. The Buddha continued his journey, and in gradual stages reached the Deer Park at Isipatana. The five ascetics, seeing the Buddha from afar, discussed among themselves: “Friends, here comes the ascetic Gotama who gave up the struggle and turned to a life of abundance and luxury. Let us make no kind of salutation to him.” But when the Buddha approached them, they were struck by his dignified presence and they failed in their resolve. One went to meet him and took his alms-bowl and robe, another prepared a seat, still another brought him water. The Buddha sat on the seat prepared for him, and the five ascetics then addressed him by name and greeted him as an equal, saying, “āvuso” (friend). The Buddha said, “Address not the Tathāgata (Perfect One) by the word ‘āvuso.’ The Tathagata, monks, is a Consummate One (Arahat), a Supremely Enlightened One. Give ear, monks, the Deathless has been attained. I shall instruct you, I shall teach you the Dhamma; following my teaching you will know and realize for yourselves even in this lifetime that supreme goal of purity for the sake of which clansmen retire from home to follow the homeless life.”

Thereupon the five monks said: “Friend Gotama, even with the stern austerities, penances, and self-torture you practised, you failed to attain the superhuman vision and insight. Now that you are living a life of luxury and self-indulgence, and have

given up the struggle, how could you have reached superhuman vision and insight?"

Then replied the Buddha: "The Tathagata has not ceased from effort and reverted to a life of luxury and abundance. The Tathagata is a Supremely Enlightened One. Give ear, monks, the Deathless has been attained. I shall instruct you. I shall teach you the Dhamma.

A second time the monks said the same thing to the Buddha who gave the same answer a second time. A third time they repeated the same question. In spite of the assurance given by the Master, they did not change their attitude. Then the Buddha spoke to them thus: "Confess, O monks, did I ever speak to you in this way before?" Touched by this appeal of the Blessed One, the five ascetics submitted and said: "No, indeed, Lord." Thus did the Supreme Sage, the Tamed One, tame the hearts of the five ascetics with patience and kindness, with wisdom and skill. Overcome and convinced by his utterances, the monks indicated their readiness to listen to him.

## Dhamma Terminology **វាក្យសព្ទព្រះធម៌**

| | |
|---|---|
| The First Sermon | បឋមទេសនា |
| the Peerless Teacher | បរមសាស្តាឥតមានបុគ្គលណាមួយស្មើ (អនុត្តរោ) |
| keen faculties and dull faculties | ឥន្ទ្រិយវាងវៃ និង ឥន្ទ្រិយស្ពឹកស្រពន់ (មិនវាងវៃ) |

fruitless rigours of extreme asceticism ការប្រព្រឹត្តតបៈតឹងរឹងក្រៃពេកដែលឥតប្រយោជន៍

Setting in motion the Wheel of Dhamma ធម្មចក្កប្បវត្តនៈ

| | |
|---|---|
| Supremely Enlightened | ទ្រង់បានត្រាស់ដឹងហើយដោយប្រពៃ |
| quenching all defilements | កម្ចាត់បង់នូវកិលេសទាំងឡាយ |
| homeless life | អនាគរិយជីវិត (ជីវិតអ្នកបួស ដែលមិននៅគ្រប់គ្រងផ្ទះ) |
| substance of becoming | សារធាតុ ឬអង្គធាតុ (បច្ច័យ) ដែលនាំឱ្យកើត |
| weariness, vexation | ការធុញទ្រាន់ ខាតបង់ទទេ (អស់កម្លាំង នឿយហត់) |
| sublime, subtle | ប្រសើរឧត្តម ជ្រាលជ្រៅ ល្អិតសុខុម (បរមត្ថ) |
| delight, revel, rejoice | សប្បាយ រីករាយគឹកកង ត្រេកអរ |
| sensual pleasures | កាមសុខ សេចក្តីសុខដោយការជាប់ជំពាក់ |
| extinction of craving | ការអស់ទៅនៃតណ្ហា |
| wise and discerning | ដែលមានប្រាជ្ញាឈ្លាសវៃ |
| Deathless Drum | ស្គរនៃអមតធម៌ |
| salutation | ការគោរពសំពះ ថ្វាយបង្គំ (អភិវាទនកិច្ច) |
| alms-bowl | បាត្រ |
| the Tamed One | បុគ្គលដែលមានចិត្តបានអប់រំទូន្មានហើយ |

# បឋមទេសនា (ធម្មចក្កប្បវត្តនសូត្រ)

ឥឡូវនេះ ខណៈពេលព្រះដ៏មានព្រះភាគគង់នៅក្នុងកម្មដ្ឋាន គំនិតនេះក៏បានកើតឡើងចំពោះព្រះអង្គ៖ ៉ព្រះធម៌ដែលអាត្មាអញបានចាក់ធ្លុះ ពិបាកឃើញ ពិបាកយល់ ជាធម៌ដ៏ក្សេម និងជ្រាលជ្រៅ ផុតពីវិស័យហេតុផលធម្មតា ល្អិតសុខុម និងអាចឈ្វេងយល់បានសម្រាប់បុគ្គលអ្នកឈ្លាសវៃ (អ្នកប្រាជ្ញ)។ ប៉ុន្តែ ជំនាន់នេះគេសប្បាយ រីករាយគឹកកង និងត្រេកអរនៅក្នុងកាមគុណទៅវិញ។ វាជាការលំបាកសម្រាប់មនុស្សជំនាន់នេះ ដើម្បីយល់នូវច្បាប់នៃបច្ច័យតាក់តែងនេះ ពោលគឺ បដិច្ចសមុប្បាទធម៌។ ជាងនេះទៅទៀតរឹតតែលំបាក ដើម្បីឃើញនូវការស្ងប់រំងាប់នៃសង្ខារធម៌ទាំងឡាយ ការលះបង់នូវបច្ច័យដែលនាំឱ្យមានឧបបត្តិភវៈ (ការកើតឡើង) ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយចាករាគៈ ការរំលត់សេចក្តីទុក្ខ គឺព្រះនិព្វាន។ ហើយប្រសិនបើ តថាគតនឹងបង្រៀនធម៌ ប៉ុន្តែអ្នកដទៃមិនបានយល់តថាគត នោះនឹងទៅជាការធុញទ្រាន់ ខាតបង់ និងនឿយហត់សសម្រាប់តថាគត៉។

ដោយបានព្រះតម្រិះយ៉ាងនេះហើយ ដំបូងព្រះអង្គមានព្រះទ័យស្ទាក់ស្ទើរដើម្បីសំដែងធម៌ ប៉ុន្តែដោយការប្រមើលឧបនិស្ស័យរបស់សត្វក្នុងលោក ដោយបញ្ញាចក្ខុរបស់ព្រះអង្គៗបានឃើញ សត្វខ្លះមានធូលីតិចនៅក្នុងភ្នែក សត្វខ្លះមានធូលីច្រើននៅក្នុងភ្នែក ខ្លះមានឥន្ទ្រីយ៍រហ័សរហួនវាងវៃ ខ្លះមានឥន្ទ្រីយ៍ទន់ទាប ខ្លះមានគុណសម្បត្តិ ខ្លះមានគុណវិបត្តិ ងាយបង្រៀន និងពិបាកបង្រៀន សត្វខ្លះរស់នៅដើម្បីតែរង់ចាំសេចក្តីអន្តរាយនាពេលខាងមុខព្រោះប្រព្រឹត្តអាក្រក់ក្នុងបច្ចុប្បន្ន ហើយសត្វខ្លះមិនបានប្រព្រឹត្តដូច្នោះឡើយ។ ព្រះបរមសាស្តា បន្ទាប់មកទ្រង់ប្រកាសនូវកាលសមគួរដើម្បីសំដែងព្រះធម៌ដោយបន្លឺនូវឧទានវាចាដ៏មុឹងម៉ាត់ថា៖

"អបារុតា តេសំ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ"

"ទ្វារនៃអមតធម៌ ពោលគឺព្រះនិព្វានបានបើកហើយ សត្វទាំងឡាយណា
មានសោតប្បសាទ ចូរបញ្ចេញនូវសទ្ធាចុះ"។

នៅពេលពិចារណា ថាតើបុគ្គលណាគួរដល់ព្រះអង្គសំដែងធម៌ប្រាប់មុនគេ។ ព្រះអង្គបានគិតឃើញដល់ តាបស អាឡារៈ កាឡាមៈ និងតាបស ឧទ្ទកៈ រាមបុត្តៈ ដែលជាគ្រូដើម ដោយព្រះអង្គជ្រាបថាតាបសទាំងពីរជាអ្នកប្រាជ្ញអាចឆាប់យល់បាន។ ប៉ុន្តែមិនបានដូចព្រះទ័យឡើយដោយតាបសទាំងពីរបានចែកឋានទៅហើយ។ ដូច្នេះព្រះមានព្រះភាគ បានសម្រេចព្រះទ័យប្រកាសសច្ចធម៌ដល់តាបសទាំងប្រាំរូបវិញ ដែលជាសហធម្មិកៈ (សំឡាញ់)ពីមុន ហើយពួកគេកំពុងនៅជាប់ក្នុងការបដិបត្តិដ៏តឹងរឹងក្រៃលែងទាំងមិនបានផលអ្វីសោះ។ ដោយទ្រង់ជ្រាបថាតាបសទាំងប្រាំកំពុងស្ថិតនៅទីក្រុងពារាណសី ក្នុងឥសិបតនមិគទាយវ័ន (modern Sarnath) ព្រះភគវាបានយាងចេញពីគយាឆ្ពោះទៅកាន់ក្រុងពារាណសីដ៏ឆ្ងាយ ដោយថ្មើព្រះបាទក្នុងចម្ងាយផ្លូវប្រមាណ ១៥០ ម៉ាលស៍ (150 miles)។ នៅតាមផ្លូវមិនឆ្ងាយប៉ុន្មានពីគយា ព្រះសម្មាសម្ពុទ្ធបានជួប ឧបកៈ ជាតាបស១រូប ដែលជ្រះថ្លានឹងឥន្ទ្រីយ៍ដ៏ស្រគត់ស្រគំរបស់ព្រះសាស្តា ហើយទូលសួរព្រះអង្គថា "នរណាជាគ្រូរបស់អ្នក? តើមេរៀនរបស់គ្រូអាចារ្យណាមួយដែលអ្នកប្រកាន់យក?" ។

ព្រះពុទ្ធបានមានបន្ទូលតបថាៈ "តថាគតឥតមានគ្រូទេ បុគ្គលដូចតថាគតមិនមាននៅក្នុងលោកទាំងអស់ តថាគតជាសាស្តាចារ្យ ជាព្រះអរហន្ត។ តថាគតបានត្រាស់ដឹងពេញបរិបូណ៌ដោយខ្លួនឯង។ កម្ចាត់បង់នូវកិលេសគ្រប់យ៉ាង សេចក្តីស្ងប់ពោលគឺព្រះនិព្វានតថាគតបានសម្រេចហើយ។ តថាគតទៅកាន់ទីក្រុងកាសី(Benares) ដើម្បីបង្វិលនូវកង់នៃធម៌ឱ្យប្រព្រឹត្តទៅ (ធម្មចក្កប្បវត្តនៈ)។ នៅក្នុងលោកដែលគ្រប់គ្រងដោយអវិជ្ជាគឺសេចក្តីងងឹត តថាគតគប្បីទូងនូវស្គរនៃអមតធម៌" ។

"ម្នាលសម្លាញ់ អ្នកអះអាងថា ខ្លួនអ្នកជាអ្នកឈ្នះលោក" ឧបកៈតាបសបានលើកឡើង។ ព្រះពុទ្ធបានឆ្លើយតបថាៈ **"បុគ្គលទាំងឡាយណាដែលបានសម្រេចនូវការសូន្យទៅ អស់ទៅនៃកិលេស អ្នកទាំងនោះ ប្រាកដណាស់ ជាអ្នកឈ្នះលោក ដូចតថាគតដែរ។ អកុសលធម៌ទាំងឡាយ តថាគតបានយកឈ្នះអស់ហើយ។ ហេតុនេះ តថាគតគឺជាអ្នកឈ្នះលោក។"**

ឧបកៈតាបស បានងក់ក្បាល បែបចំអកថាៈ "ប្រហែលអ៊ីចឹងមែនហើយសំឡាញ់" ហើយក៏បែកផ្លូវចេញទៅ។ ព្រះពុទ្ធបានបន្តដំណើរជាបន្តបន្ទាប់ រហូតបានដល់ឥសិបតនមិគទាយវ័ន។ តាបសទាំងប្រាំរូប ពេលបានឃើញព្រះពុទ្ធពីចម្ងាយ ក៏ពិភាក្សា

គ្នាថា៖ "ម្នាលសហធម្មិកៈ ព្រះសមណគោតមយាងមកហើយ ទ្រង់បានបោះបង់នូវទុក្ករកិរិយា ហើយត្រឡប់ទៅកាន់ជីវិតដ៏សម្បូរបែបនិងប្រណីតភាពវិញ។
ចូរយើង កុំធ្វើការរាក់ទាក់រកព្រះអង្គអី" ។ ប៉ុន្តែ ពេលព្រះពុទ្ធយាងចូលទៅរកពួកគេ តាបសទាំងនោះ បានទាក់ចិត្តដោយសារព្រះវត្តមានប្រកបដោយកិត្យានុភាពរបស់ព្រះអង្គ ហើយការតាំងចិត្តមុននោះក៏បរាជ័យ។ តាបសម្នាក់បានរត់ទៅទទួលបាត្រ និងចីវរពីព្រះអង្គ។ តាបសម្នាក់ទៀតបានរៀបចំអាសនៈ ឯតាបសម្នាក់ទៀតបានយកទឹកមកថ្វាយព្រះអង្គ។ ព្រះពុទ្ធបានគង់លើអាសនៈដែលបានរៀបចំសម្រាប់ព្រះអង្គ ហើយតាបសទាំង៥បានហៅព្រះនាម និងរាក់ទាក់ព្រះអង្គ ដោយស្មើភាពគ្នា ពោលហៅព្រះអង្គថា: **"អាវុសោ"** (មិត្តសម្លាញ់)។

ព្រះសម្មាសម្ពុទ្ធបានមានពុទ្ធដីការថា"ចូរកុំហៅតថាគតដោយពាក្យថា "អាវុសោ" ។ ម្នាលតាបសទាំងឡាយ តថាគតគឺជាព្រះអរហន្ត ជាព្រះសម្មាសម្ពុទ្ធ (បុគ្គលដែលបានត្រាស់ដឹងដោយបរិបូណ៌)។ ម្នាលអ្នកទាំងឡាយ ចូរស្តាប់ អមតធម៌គឺតថាគតបានសម្រេចហើយ។ តថាគតនឹងបង្រៀនអ្នក តថាគតនឹងសម្តែងនូវធម៌ បដិបត្តិតាមការបង្រៀនរបស់តថាគត អ្នកនឹងបានដឹង បានចាក់ធ្លុះដោយខ្លួនអ្នក សូម្បីនៅក្នុងជាតិនេះគឺថា សេចក្តីបរិសុទ្ធដ៏កំពូលគឺជាផលរបស់អ្នកចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួស។ គ្រានោះ ឥសីទាំង៥ បានពោលថា: "បពិត្រសម្លាញ់គោតម សូម្បីការបតិបត្តិដ៏តឹងរឹង ការធ្វើទុក្ករកិរិយា និងការបៀតបៀនខ្លួនដែលព្រះអង្គបានបដិបត្តិហើយ ព្រះអង្គបរាជ័យមិនបាននូវបញ្ញាញាណដ៏អស្ចារ្យនោះផង។ ឥឡូវនេះ ព្រះអង្គបែរជារស់នៅក្នុងជីវិតដ៏ប្រណិត និងសោយសុខក្នុងកាមគុណ ហើយបានលះបង់នូវទុក្ករកិរិយា ថាតើព្រះអង្គអាចបានសម្រេចនូវបញ្ញាញាណដ៏មហស្ចារ្យនោះយ៉ាងដូចម្តេច?"។

ព្រះពុទ្ធបានមានពុទ្ធដីកាតបវិញថា៖ "តថាគតមិនបានលះបង់នូវសេចក្តីព្យាយាម ហើយត្រឡប់ទៅកាន់ជីវិតដ៏សម្បូរបែប និងប្រណីតភាពនោះឡើយ។ តថាគតគឺជាសម្មាសម្ពុទ្ធ។ ម្នាលតាបសទាំងឡាយ ចូរស្តាប់ អមតៈធម៌ គឺតថាគតបានសម្រេចហើយ។ តថាគតនឹងបង្រៀនអ្នក តថាគតនឹងសម្តែងធម៌ដល់អ្នកទាំងឡាយ" ។

ជាលើកទី២ តាបសទាំងនោះបាននិយាយពាក្យដដែលទៅកាន់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គក៏បានផ្តល់នូវចម្លើយដដែលជាគំរប់២ដង។ ជាលើកទី៣ តាបសទាំង៥

ក៏នៅតែសួរសំណួរដដែលៗ។ ទោះបីមានការបញ្ជាក់អះអាងពីព្រះសាស្តាយ៉ាងណាក៏ដោយ ក៏តាបសទាំងនោះមិនព្រមផ្លាស់ប្តូរអាកប្បកិរិយាឡើយ។ ពេលនោះ ព្រះសាស្តាបានពុទ្ធដីកាទៅកាន់ពួកគេថាៈ "ម្នាលអ្នកទាំងឡាយ ចូរសារភាពមកមើល តើតថាគតធ្លាប់និយាយរបៀបនេះទៅកាន់អ្នកទាំងឡាយពីមុនមកទេ?" ពុទ្ធដីកានេះបានចាក់ចំចំណុច តាបសទាំង៥ ក៏បានទទួលព្រម ហើយនិយាយថាៈ "ឥតទេ តាមពិត ព្រះអង្គពុំដែលបានពោលដូច្នេះទេ"។ ហេតុនេះហើយ ព្រះសាក្យមុនី ជាអរហន្តបានទូន្មានចិត្តនៃតាបសទាំង៥ប្រកបដោយខន្តី និងមេត្តា ដោយបញ្ញា និងជំនាញ។ បានយកឈ្នះចិត្ត និងញ៉ាំងពួកគេឱ្យជឿជាក់ដោយព្រះពុទ្ធដីកាបែបនោះហើយ តាបសទាំង៥ រូប ក៏បានបង្អោនចិត្តរួចរាល់ដើម្បីស្តាប់នូវព្រះធម៌។

## The Middle Path

Now on a full moon day of July, 589 years before Christ, in the evening, at the moment the sun was setting and the full moon simultaneously rising, in the shady Deer Park at Isipatana, the Buddha addressed them:

"Monks, these two extremes ought not to be cultivated by the recluse. What two? Sensual indulgence which is low, vulgar, worldly, ignoble, and conducive to harm; and self-mortification, which is painful, ignoble, and conducive to harm. The middle path, monks, understood by the Tathagata, avoiding the extremes, gives vision and knowledge and leads to calm, realization, enlightenment, and Nibbana. And what, monks, is that middle path? It is this Noble Eightfold Path, namely: right understanding,
right thought, right speech, right action, right livelihood, right effort, right mindfulness, right concentration.

Then the Buddha explained to them the Four Noble Truths: the noble truth of suffering, the noble truth of the arising of suffering, the noble truth of the cessation of suffering, and the noble truth of the way leading to the cessation of suffering. Thus did the Supreme Buddha proclaim the truth and set in motion the Wheel of the Dhamma (dhamma-cakka-pavattana). This first discourse, this message of the Deer Park, is the core of the Buddha's Teaching. As the footprint of every creature that walks the earth could be included in the elephant's footprint, which is pre-eminent for size, so does the doctrine of the Four Noble Truths embrace the entire teaching of the Buddha. Explaining each of the Four Noble Truths, the Master said: "Such, monks, was the vision, the knowledge, the wisdom, the insight, the light that arose in me, that I gained about things not heard before. As long as, monks, my intuitive knowledge, my vision in regard to these Four Noble Truths was not absolutely clear to me, I did not claim that I had gained the incomparable Supreme Enlightenment. But when, monks, my intuitive knowledge, my vision, in regard to these Four Noble Truths was absolutely clear to me, then

only did I claim that I had gained the incomparable Supreme Enlightenment. And there arose in me insight and vision: unshakeable is the deliverance of my mind (akuppa me cetovimutti), this is my last birth, there is no more becoming (rebirth). Thus spoke the Buddha, and the five monks, glad at heart, applauded the words of the Blessed One.

On December 2, 1933, at the royal dinner at the King's Palace, Sweden, when it was his turn t speak, Sir C. Venkata Raman, the Nobel Prize winning physicist, left aside science and, to the surprise of the renowned guests, delivered a most powerful address on the Buddha and India's past glories.

“In the vicinity of Benares,” said Sir Venkata Raman, “there exists a path which is for me the most sacred place in India. This path was one day travelled over by the Prince Siddhartha, after he had gotten rid of all his worldly possessions in order to go through the world and proclaim the annunciation of love.

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

The Two Extremes (Anta-dhamma): អន្តធម៌ ២ ធម៌ជាផ្លូវប្រតិបត្តិអមខាង ដ៏លាមកអាក្រក់

1.Sensual-indulgence (Kāmasukhallikānuyoga)ធម៌ដែលប្រកបខ្លួនឱ្យជាប់ជំពាក់ (កាមសុខល្លិកានុយោគ)

2.Self-mortification (Attakilamathānuyoga) ធម៌ដែលប្រកបសេចក្តីលំបាកដល់ខ្លួន (អត្តកិលមថានុយោគ)

the Middle Path/Way (Majjhimāpaṭipadā) មជ្ឈិមាបដិបទា ផ្លូវកណ្តាល

The Noble Eightfold Path (Ariya-Aṭṭhaṅgika-Magga) អរិយអដ្ឋង្គិកមគ្គ

Right Understanding, View (Sammā Diṭṭhi) សម្មាទិដ្ឋិ

Right Thought, Intention, Resolve, Aspiration (Sammā Saṅkappa) សម្មាសង្កប្ប

Right Speech (Sammā Vācā) សម្មាវាចា

Right Action (Sammā Kammanta) សម្មាកម្មន្ត

Right Livelihood, Vocation (Sammā Ājīva) សម្មាអាជីវ

Right Effort, Endeavor, Exertion, Energy, (Sammā Vāyāma) សម្មាវាយាម

Right Mindfulness, Awareness (Sammā Sati) សម្មាសតិ

Right Concentration, Meditation (Sammā Samādhi) សម្មាសមាធិ

*Three Training factors ( Trai-Sikkhā )* ***ត្រៃសិក្ខា***

1. Ethical Conduct, Virtue, Morality, Precept (Sīla) សីល
2. Mental Discipline, Concentration, Meditation (Samādhi) សមាធិ
3. Wisdom, Insight (Paññā) បញ្ញា

the core of the Buddha's teaching ស្នូល ឬចំណុចសំខាន់នៃពុទ្ធវចនៈ

incomparable supreme enlightenment អនុត្តរសម្មាសម្ពោធិញាណ

worldly possessions សម្បត្តិក្នុងលោក (លោកិយសម្បត្តិ)

# មជ្ឈិមាបដិបទា

នាថ្ងៃពេញបូណ៌មី ខែកក្កដា ៥៨៩ ឆ្នាំមុនគ្រឹស្តសករាជ នាវេលាល្ងាច គ្រាព្រះទិន្នករ បររាជរថ អស្តង្គតរតល់ទៅហើយ ព្រះចន្ទពេញវង់ក៏បានរះឡើងបន្ទាប់គ្នា នៅក្នុងឥសិបតនមិគទាយវ័នដ៏ប្រកបដោយម្លប់ ព្រះសម្មាសម្ពុទ្ធបានទ្រង់សម្តែងថា៖

"ម្នាលភិក្ខុទាំងឡាយ អន្តធម៌ ២ (ធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់) បព្វជិតមិនគួរបដិបត្តិឡើយ។ តើពីរយ៉ាងនោះគឺអ្វី?

**១.កាមសុខល្លិកានុយោគ** ជាធម៌ដែលប្រកបខ្លួនឱ្យជាប់ជំពាក់ ជាធម៌ថោកទាប ជាធម៌របស់បុថុជ្ជន មិនមែនជាធម៌របស់អរិយបុគ្គល និងនាំឱ្យមានទុក្ខទោស។

**២.អត្តកិលមថានុយោគ** ជាធម៌ដែលប្រកបសេចក្តីលំបាកដល់ខ្លួន ដែលឈឺចាប់ដល់រាងកាយ មិនមែនជាធម៌របស់អរិយបុគ្គល និងនាំឱ្យមានទុក្ខទោស។

ម្នាលភិក្ខុទាំងឡាយ **មជ្ឈិមាបដិបទា** ជាផ្លូវកណ្តាល តថាគតបានចាក់ធ្លុះហើយ ដោយលះបង់នូវអន្តធម៌២យ៉ាងនោះ នឹងបាននូវចក្ខុ និងវិជ្ជា ដែលនាំទៅកាន់សេចក្តីស្ងប់ ការចាក់ធ្លុះនូវសច្ចៈធម៌ ការត្រាស់ដឹង និងព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ អ្វីទៅជា **មជ្ឈិមាបដិបទា**? នោះគឺជាអរិយអដ្ឋង្គិកមគ្គ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ៨ប្រការ មានឈ្មោះដូចតទៅ៖ ១.សម្មាទិដ្ឋិ ការយល់ត្រូវ ២.សម្មាសង្កប្ប ការត្រិះរិះត្រូវ ៣.សម្មាវាចា សម្តីត្រូវ ៤.សម្មាកម្មន្ត ការងារត្រូវ ៥.សម្មាអាជីវ ការចិញ្ចឹមជីវិតត្រូវ ៦.សម្មាវាយាម ការព្យាយាមត្រូវ ៧.សម្មាសតិ ការរឭកត្រូវ ៨.សម្មាសមាធិ ការតម្កល់ចិត្តឱ្យនឹងត្រូវ"។

បន្ទាប់មក ព្រះសម្មាសម្ពុទ្ធបានពន្យល់ដល់ភិក្ខុទាំងឡាយអំពី **អរិយសច្ចៈ៤៖** **១.ទុក្ខអរិយសច្ចៈ ២.ទុក្ខសមុទយអរិយសច្ចៈ ៣.ទុក្ខនិរោធអរិយសច្ចៈ ៤.ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ (មគ្គសច្ចៈ)។**

តាមរបៀបនេះឯង ព្រះសម្មាសម្ពុទ្ធបានប្រកាសនូវសច្ចធម៌ និងបានញ៉ាំងកង់នៃព្រះធម៌ឱ្យប្រព្រឹត្តទៅ (ធម្មចក្កប្បវត្តនៈ)។ បឋមទេសនានេះ សារដែលព្រះអង្គបានសំដែងនៅឧទ្យានឱ្យអភ័យដល់សត្វម្រឹគនេះ (មិគទាយវ័ន) ជាស្នូល ឬខ្លឹមសំខាន់នៃពុទ្ធវចនៈ។ ស្នាមជើងនៃសត្វទាំងឡាយដែលដើរលើដី អាចរាប់បានថា ដានជើងដំរីមានទំហំធំជាងគេយ៉ាងណាមិញទ្រឹស្តីអរិយសច្ចៈ៤ ក្តោបក្រសោបទាំងស្រុងនូវការបង្រៀនរបស់ព្រះពុទ្ធ។

ដោយពន្យល់នូវអរិយសច្ចៈនីមួយៗ ព្រះសាស្តាបានមានពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ នេះជាចក្ខុ នេះជាវិជ្ជា បញ្ញា ញាណ ពន្លឺ ដែលកើតឡើងហើយដល់តថាគតក្នុងធម៌ដែលតថាគតមិនធ្លាប់បានឮពីមុនមក។ ម្នាលភិក្ខុទាំងឡាយ ដរាបណា ញាណ និងវិជ្ជារបស់តថាគតនៅក្នុងអរិយសច្ចៈ៤ មិនទាន់កើតឡើងច្បាស់ប្រាកដទេ តថាគតមិនប្រកាសថា តថាគតបានសម្រេចនូវអភិសម្មាសម្ពោធិញ្ញាណឡើយ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ នៅពេលដែលញាណរបស់តថាគត វិជ្ជារបស់តថាគត នៅក្នុងអរិសច្ចៈ៤ កើតប្រាកដពេញបរិបូណ៌ហើយ ពេលនោះទើបតថាគតប្រកាសថា តថាគតបានសម្រេចនូវអភិសម្មាសម្ពោធិញ្ញាណ។ ហើយញាណ និងចក្ខុរបស់បានកើតឡើងហើយដល់តថាគតៈ **មិនញាប់ញ័រ គឺចិត្តរបស់តថាគតដែលបានរួចរដោះ** (**អកុប្បា មេ ចេតោវិមុត្តិ**) នេះជាជាតិចុងក្រោយរបស់តថាគត មិនមានការកើតទៀតឡើយ"។ ព្រះសម្មាសម្ពុទ្ធទ្រង់មានសម្ដែងដូច្នេះហើយ បញ្ចវគ្គិយភិក្ខុ មានចិត្តជ្រះថ្លា សាទរចំពោះពាក្យនៃព្រះដ៏មានព្រះភាគ ។

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៣៣ នៅក្នុងព្រះរាជពិធីជប់លៀងអាហារពេលល្ងាចក្នុងព្រះរាជវាំងរបស់ស្ដេចស៊ុយអែត (Sweden) នៅពេលដល់វេនថ្លែងការណ៍ Sir C. Venkata Raman ជារូបវិទូពានរង្វាន់ណូបែល បានផាត់ទុកវិទ្យាសាស្ត្រដោយឡែកជាការភ្ញាក់ផ្អើលដល់ភ្ញៀវកិត្តិយស លោកបានធ្វើសុន្ទរកថានូវសារដ៏មានឥទ្ធិពលបំផុតមួយ អំពីព្រះសម្មាសម្ពុទ្ធ និងភាពរុងរឿងនៅក្នុងអតីតកាលនៃប្រទេសឥណ្ឌា។ "នៅទីជិតនៃក្រុងពារាណសី" លោក Sir C. Venkata Raman បានលើកឡើងថា "មានមាគ៌ាបដិបត្តិមួយដែលសម្រាប់ខ្ញុំ គឺជាទីសក្ការៈបូជាដ៏ល្អបំផុតក្នុងប្រទេសឥណ្ឌា ។ មាគ៌ានេះធ្លាប់ត្រូវបានធ្វើដំណើរដោយព្រះរាជបុត្រសិទ្ធត្ថៈ ហើយក្រោយពីព្រះអង្គបានលះបង់នូវសម្បត្តិក្នុងលោកដើម្បីចេញសាងផ្នួស ទ្រង់បានប្រកាសនូវមេត្តាធម៌ គឺសេចក្តីស្រឡាញ់ឥតលក្ខខណ្ឌ។

# The Siṃsapā Grove

The supremacy of the Four Noble Truths in the teaching of the Buddha is abundantly clear from the message of the Sinsapā Grove as from the message of the Deer Park. Once the Blessed One was living at Kosambī (near Allahabad) in the Sinsapā Grove. Then, gathering a few sinsapā leaves in his hand, the Blessed One addressed the monks:

"What do you think, monks, which is greater in quantity, the handful of sinsapā leaves gathered by me or what is in the forest overhead?"

"Not many, trifling, venerable sir, are the leaves in the handful gathered by the Blessed One; many are the leaves in the forest overhead."

"Even so, monks, many are those things I have fully realized but not declared to you; few are the things I have declared to you. And why, monks, have I not declared them? They, monks, are not useful are not essential to the life of purity, they do not lead to disgust, to dispassion, to cessation, to tranquility, to full understanding, to full enlightenment, to Nibbāna. That is why, monks, they are not declared by me.

"And what is it, monks, that I have declared? This is suffering- this have I declared. This is the arising of suffering-this have I declared. This is the cessation of suffering-this have I declared. This is the path leading to the cessation of suffering-this have I declared.

"And why, monks, have I declared these truths?

"They are, indeed, useful, are essential to the life of purity, they lead to disgust, to dispassion, to cessation, to tranquillity, to full understanding, to enlightenment, to Nibbāna. That is why, monks, they are declared by me. Therefore, monks, an effort should be made to realize: "This is suffering, this is the arising of suffering, this is the cessation of suffering, this is the way leading to the cessation of suffering.

The Buddha has emphatically said: "One thing do I make known: suffering, and the cessation of suffering (dukkhaṃ ceva paññāpemi, dukkhassa ca nirodhaṃ). To understand this unequivocal saying is to understand Buddhism; for

the entire teaching of the Buddha is nothing else than the application of this one principle. What can be called the discovery of a Buddha is just these Four Noble Truths. This is the typical teaching of the Buddhas of all ages.

# Dhamma Terminology វាក្យសព្ទព្រះធម៌

Siṃsapā Grove ឧទ្យានធ្នង់ *(Siṃsapāvana : a grove of murraya exotica)

Siṃsapā leaves ស្លឹកធ្នង់ (បិដកខ្មែរ : សីសបាបណ្ណវគ្គ ភាគ ៣៩ ទំព័រ ២៧៣)

Supremacy ភាពឧត្តមបំផុត ឬ បរមានុភាព

trifling ដែលបន្តិចបន្តួច ស្តួចស្តើង

the Blessed One addressed the monks ព្រះមានព្រះភាគត្រាស់ទៅកាន់ភិក្ខុទាំងឡាយ

venerable sir បពិត្រព្រះអង្គដ៏ចម្រើន, បពិតលោកម្ចាស់ដ៏ចម្រើន (ភន្តេ)

essential to the life of purity ដែលចាំបាច់សម្រាប់ជីវិតនៃសេចក្តីបរិសុទ្ធ (ព្រហ្មចរិយធម៌)

disgust, dispassion សេចក្តីខ្ពើមរអើម ការរលត់នៃរាគៈ

tranquility សេចក្តីស្ងប់ស្ងាត់ (សមថ)

emphatically យ៉ាងដាច់អហង្ការ យ៉ាងដាច់ខាត ឬយ៉ាងម៉ឺងម៉ាត់

unequivocal ដែលជាក់លាក់ ដែលច្បាស់លាស់

the discovery of the Buddha របកគំហើញរបស់ព្រះពុទ្ធ

This is suffering នេះគឺជាទុក្ខ (ទុក្ខ)

This is the arising of suffering នេះគឺជាការកើតឡើងនៃទុក្ខ (ទុក្ខសមុទយ)

This is the cessation of suffering នេះគឺជាការរលត់ទៅនៃទុក្ខ (ទុក្ខនិរោធ)

This is the path leading to the cessation of suffering
នេះគឺជាមាគ៌ានាំទៅរកការរំលត់ទុក្ខ (ទុក្ខនិរោធគាមិនីបដិបទា ឬមគ្គ)

# សីសបាវ័ន (ព្រៃធ្លង់)

អធិបតីភាពនៃចតុរារិយសច្ចៈក្នុងការបង្រៀនរបស់ព្រះពុទ្ធគឺ បរិបូណ៌ ច្បាស់លាស់ណាស់ត្រង់ខ្លឹមសារដែលបានសម្តែងនៅ សីសបាវ័ន ឬព្រៃធ្លង់ ដូចគ្នានឹងការបង្រៀននៅឯមិគទាយវ័ន។

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្រុងកោសម្ពី (ជិតអល្លាហាបាដ) ក្នុងព្រៃធ្លង់ ។ ពេលនោះ ព្រះអង្គបានចាប់យកស្លឹកធ្លង់មួយចំនួននៅក្នុងព្រះហស្ថព្រះអង្គ ហើយបានត្រាស់សួរទៅកាន់ភិក្ខុទាំងឡាយថាៈ

"ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយគិតដូចម្តេច តើចំនួនណាមួយច្រើនជាងស្លឹកធ្លង់ក្នុងដៃតថាគត ឬក៏ស្លឹកធ្លង់នៅក្នុងព្រៃខាងលើក្បាល?"។

"បពិត្រព្រះអង្គដ៏ចម្រើន មិនច្រើនទេ គឺតិចតួចណាស់ ស្លឹកឈើដែលព្រះដ៏មានព្រះភាគបានកាន់នៅក្នុងព្រះហស្ថ។ ស្លឹកឈើដែលមានច្រើន គឺនៅក្នុងព្រៃខាងលើក្បាលឯណោះ" ។

"ដូចគ្នានេះដែរ ម្នាលភិក្ខុទាំងឡាយ ចំនួនច្រើនគឺធម៌ដែលតថាគតបានត្រាស់ដឹងហើយ ប៉ុន្តែតថាគតមិនបានប្រកាសម្តែងគ្រប់យ៉ាងដល់អ្នកទាំងឡាយឡើយ។ មានចំនួនតិចតួចណាស់ ធម៌ដែលតថាគតបានប្រកាសសម្តែងដល់អ្នកទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ ហេតុអ្វីបានជាតថាគតមិនបានសម្តែងធម៌ទាំងនោះ? ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនោះមិនមានប្រយោជន៍ មិនមានការចាំបាច់ដល់ការប្រព្រឹត្តព្រហ្មចរិយធម៌ទេ ធម៌ទាំងនោះមិននាំទៅរកសេចក្តីនឿយណាយ មិននាំទៅរកការប្រាសចាកតម្រេក(វិរាគៈ) មិននាំទៅរកការរំលត់ទុក្ខ មិននាំទៅរកសេចក្តីស្ងប់ មិននាំទៅរកសេចក្តីដឹងច្បាស់ មិននាំទៅរកការត្រាស់ដឹងដោយបរិបូណ៌ ពោលគឺព្រះនិព្វានទេ។ ហេតុនេះហើយ ភិក្ខុទាំងឡាយ ធម៌ទាំងនោះតថាគតមិនបានប្រកាសសម្តែងឡើយ។

"ម្នាលភិក្ខុទាំងឡាយ ធម៌អ្វីទៅ ដែលតថាគតបានប្រកាសសម្តែង?
នេះគឺជាទុក្ខ -នេះដែលតថាគតបានប្រកាសសម្តែង។ នេះគឺការកើតឡើងនៃទុក្ខ -នេះដែលតថាគតបានប្រកាសសម្តែង។ នេះគឺការរំលត់ទុក្ខ -នេះដែលតថាគតបានប្រកាសសម្តែង។ នេះគឺជាផ្លូវនាំទៅរកការរំលត់ទុក្ខ -នេះដែលតថាគតបានប្រកាសសម្តែង។

"ម្នាលភិក្ខុទាំងឡាយ តើហេតុអ្វី តថាគតប្រកាសសម្តែងនូវសច្ចៈធម៌ទាំងនេះ ?

"ម្នាលភិក្ខុទាំងឡាយ ចតុរារិយសច្ចៈនេះ ពិតណាស់ មានប្រយោជន៍ ហើយចាំបាច់សម្រាប់ការប្រព្រឹត្តនូវព្រហ្មចរិយធម៌ អរិយសច្ចៈនាំទៅរកសេចក្តីនឿយណាយ នាំទៅរកការប្រាសចាកតម្រេក នាំទៅរកការរំលត់ទុក្ខ នាំទៅរកសេចក្តីស្ងប់ នាំទៅរកសេចក្តីដឹងច្បាស់ នាំទៅរកការត្រាស់ដឹងដោយបរិបូណ៌ ពោលគឺព្រះនិព្វាន។ ហេតុនេះហើយភិក្ខុទាំងឡាយ ទើបតថាគតប្រកាសសម្តែងនូវចតុរារិយសច្ចៈ។ ហេតុនេះហើយ ភិក្ខុទាំងឡាយ សេចក្តីព្យាយាមគួរគប្បីតម្កល់មាំដើម្បីធ្វើឱ្យជាក់ច្បាស់៖ "នេះគឺជាទុក្ខ នេះគឺជាការកើតឡើងនៃទុក្ខ នេះគឺជាការរំលត់ទុក្ខ នេះគឺជាមាគ៌ានាំទៅរកការរំលត់ទុក្ខ"។

ព្រះពុទ្ធបានប្រកាសសម្តែងយ៉ាងម៉ឺងម៉ាត់(ដាច់អហង្ការ)ថា៖ "ធម៌មួយ ដែលតថាគតបានធ្វើឱ្យជាក់ច្បាស់៖ **សេចក្តីទុក្ខ និងការរលត់ទៅនៃសេចក្តីទុក្ខ**"។

**( ទុក្ខំ ចេវ បញ្ញាបេមិ ទុក្ខស្ស ច និរោធំ។ )**

បើអាចយល់នូវពាក្យខាងលើនេះ គេអាចយល់អ្វីទៅជាព្រះពុទ្ធសាសនាបានហើយ ព្រោះថា ការបង្រៀនទាំងស្រុងរបស់ព្រះពុទ្ធ គឺគ្មានអ្វីដទៃជាជាងការបដិបត្តិនូវគោលធម៌មួយនេះទេ។ អ្វីដែលគេអាចហៅបានថាជា របកគំហើញរបស់ព្រះពុទ្ធ គឺជាអរិយសច្ចៈទាំងបួននេះឯង។ នេះគឺជាការបង្រៀនទូទៅនៃព្រះពុទ្ធទាំងឡាយគ្រប់សម័យកាលទាំងអស់។

## The Peerless Physician

The Buddha is also known as the peerless physician (bhisakko), the supreme surgeon (sallakatto anutaro). He indeed, is an unrivalled healer.

The Buddha's method of exposition of the Four Noble Truths is comparable to that of a physician. As a physician, he first diagnosed the illness, next he discovered the cause for the arising of the illness, then he considered its removal, and lastly applied the remedy.

Suffering (dukkha) is the illness; craving (taṇhā) is the arising or the root cause of the illness (samudaya); through the removal of craving, the illness is removed, and that is the cure (nirodha-nibbāna); the Noble Eightfold Path (magga) is the remedy.

The Buddha's reply to a brahmin who wished to know why the Master is called a Buddha clearly indicates that it was for no other reason than a perfect knowledge of the Four Noble Truths. Here is the Buddha's reply:

> “knew what should be known,
> What should be cultivated I have cultivated.
> What should be abandoned that have I let go.
> Hence, O brahmin, I am Buddha -The Awakened One.”

With the proclamation of the Dhamma for the first time, with the setting in motion of the Wheel of the Dhamma, and with the conversion of the five ascetics, the Deer Park at Isipatana became the birthplace of the Buddha's Dispensation (sāsana) and of his Community of Monks (sangha).

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

| | |
|---|---|
| The Peerless Physician (Bhisakko) | ភិសក្កោ : គ្រូពេទ្យគ្មានគូប្រៀប |
| the supreme surgeon (Sallakatto anuttaro) | សល្លកត្តោ អនុត្តរោ : ជាពេទ្យវះកាត់ដ៏កំពូល |
| an unrivalled healer | ជាអ្នកព្យាបាលដែលគ្មានគូប្រៀប |
| method of exposition | វិធីសាស្ត្រនៃការអធិប្បាយ ពន្យល់ ឬបង្រៀន |
| diagnose the illness | ធ្វើរោគវិនិច្ឆ័យ |
| discover the cause | ស្វែងរកមូលហេតុ ឬប្រភពដើម |
| consider its removal | ពិចារណានូវវិធីកម្ចាត់បង់ ឬព្យាបាលនូវជំងឺនោះ |
| apply the remedy | ប្រើនូវថ្នាំកែរោគ ឬ អនុវត្តនូវវិធីព្យាបាល |
| the cure (Nirodha-Nibbāna) | សភាពជាសះស្បើយអំពីជំងឺ (និរោធ និព្វាន) |
| proclamation of the Dhamma | ការប្រកាសសម្តែងនូវព្រះធម៌ |

# គ្រូពេទ្យគ្មានគូប្រៀប

ព្រះសម្មាសម្ពុទ្ធ ត្រូវបានគេស្គាល់ថាជាមហាពេទ្យដែលគ្មាននរណាអាចប្រៀបស្មើបាន (ភិសក្កោ) ទ្រង់ជាគ្រូពេទ្យវះកាត់ដ៏កំពូល (សល្លកត្តោ អនុត្តរោ) ។ ជាការពិតណាស់ ព្រះពុទ្ធ គឺជាអ្នកព្យាបាលជំងឺដែលគ្មានគូរប្រដែង។

វិធីសាស្ត្រនៃការពន្យល់អរិយសច្ចៈ៤ របស់ព្រះពុទ្ធ អាចប្រៀបធៀបទៅនឹងវិធីសាស្ត្រព្យាបាលរបស់វេជ្ជបណ្ឌិត។ ក្នុងនាមជាវេជ្ជបណ្ឌិតម្នាក់ មុនដំបូងគេធ្វើរោគវិនិច្ឆ័យ បន្ទាប់មកស្វែងរកមូលហេតុ ឬប្រភពនៃជំងឺ ក្រោយមកពិចារណារកវិធីព្យាបាល ហើយចុងក្រោយអនុវត្តនូវវិធីព្យាបាលនោះ (លេបថ្នាំតាមវេជ្ជបញ្ជា Prescription)។

*សេចក្តីទុក្ខ(ទុក្ខៈ) គឺជាជំងឺ ។ ការជាប់ជំពាក់(តណ្ហា) គឺជាឫសគល់នៃទុក្ខ (ទុក្ខសមុទយៈ) ។ តាមរយៈការផ្តាច់បង់នូវតណ្ហា ជំងឺក៏ត្រូវបានផ្តាច់បង់ដែរ នេះហើយគឺជាការជាសះស្បើយ(និរោធ-និព្វាន) ។ អរិយអដ្ឋង្គិមគ្គ(មគ្គៈ) គឺជាវិធីសាស្ត្រព្យាបាល។*

ការឆ្លើយតបរបស់ព្រះសម្មាសម្ពុទ្ធទៅកាន់ព្រាហ្មណ៍ម្នាក់ ដែលចង់ដឹងថាតើហេតុអ្វីបានជាព្រះសាស្តាត្រូវបានហៅថា ព្រះពុទ្ធ ត្រង់នេះបញ្ជាក់យ៉ាងច្បាស់ថាគ្មានហេតុផលណាផ្សេងក្រៅពី ប្រាជ្ញាដឹងច្បាស់ក្នុងអរិយសច្ចៈ៤ នេះទេ។ នេះគឺជាការឆ្លើយតបរបស់ព្រះសម្មាសម្ពុទ្ធ៖

**"តថាគតបានកំណត់ដឹង នូវអ្វីដែលគួរកំណត់ដឹង**
**តថាគតបានចម្រើនហើយ នូវអ្វីដែលគួរចម្រើន**
**តថាគតបានលះបង់ហើយ នូវអ្វីដែលគួរលះបង់**
**ព្រោះហេតុដូច្នេះ ម្នាលព្រាហ្មណ៍ តថាគត គឺជាព្រះពុទ្ធ**
**បុគ្គលដែលបានភ្ញាក់ពីអវិជ្ជា"។**

ដោយការប្រកាសសម្តែងនូវព្រះធម៌ជាលើកដំបូង គឺធម្មចក្កប្បវត្តនសុត្ត និងដោយការផ្លាស់ប្តូរនូវ(ទិដ្ឋិ)នៃតាបសទាំង៥ នៅឥសិបតនមិគទាយវ័ន បានក្លាយជាទីកំណើតនៃពុទ្ធសាសនា(សាសនៈ) និងទីកំណើតនៃព្រះសង្ឃ(សង្ឃៈ)។

## The Spread of the Dhamma

Thereafter the Buddha spent the vassā at the Deer Park at Isipatana, sacred this day to over 600 million of the human race. During these three months of "rains" fifty others headed by Yasa, a young man of wealth, joined the Order. Now the Buddha had sixty disciples, all arahats who had realized the Dhamma and were fully competent to teach others. When the rainy season ended, the Master addressed his immediate disciples in these words:

**"Released am I, monks, from all ties whether human or divine. You also are delivered from all fetters whether human or divine. Go now and wander for the welfare and happiness of many, out of compassion for the world, for the gain, welfare, and happiness of gods and men. Let not two of you proceed in the same direction. Proclaim the Dhamma that is excellent in the beginning, excellent in the middle, and excellent in the end, possessed of meaning and the letter and utterly perfect. Proclaim the life of purity, the holy life consummate and pure. There are beings with little dust in their eyes who will be lost through not hearing the Dhamma, there are beings who will understand the Dhamma. I also shall go to Uruvela, to Senānigama, to teach the Dhamma."**

Thus did the Buddha commence his sublime mission, which lasted to the end of his life. With his disciples he walked the highways and byways of India enfolding all within the aura of his boundless compassion and wisdom. Though the Order of Monks began its career with sixty bhikkhus, it expanded soon into thousands, and, as a result of the increasing number of monks, many monasteries came into being. In later times monastic Indian universities like Nālandā, Vikramasīlā, Jagaddalā, Vikramapuri, and Odantapuri, became cultural centres which gradually influenced the whole of Asia and through it the mental life of humankind.

After a successful ministry of forty-five years the Buddha passed away at the age of eighty at the twin Sāla Trees of the Mallas at Kusiṇārā (in modern Uttara Pradesh about 120 miles northeast of Benāres).

# Dhamma Terminology វាក្យសព្ទព្រះធម៌

the spread of the Dhamma ការផ្សព្វផ្សាយព្រះធម៌

the Buddha's Dispensation (Sāsana) សាសនៈនៃព្រះពុទ្ធ (ពុទ្ធសាសនា)

the community of monks, the Order (Saṅgha) សហគមន៍សង្ឃ គណសង្ឃ

Vassā : the rains/rains-retreat/rainy season វស្សា រដូវភ្លៀង

delivered from all fetters បានរួចចាកពីសំយោជនៈទាំងឡាយ (គ្រឿងសៅហ្មងដែលចងសត្វទុកក្នុងភព)

for the welfare of many ដើម្បីជាប្រយោជន៍ (សុខុមាលភាព) នៃជនច្រើនគ្នា : ពហុជនហិតាយ

for the happiness of many ដើម្បីជាសេចក្តីសុខនៃជនច្រើនគ្នា : ពហុជនសុខាយ

for the happiness of gods and men ដើម្បីជាសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ

out of compassion for the world ដោយសេចក្តីអនុគ្រោះ (ករុណា) ចំពោះសព្វសត្វ : លោកានុកម្បាយ

excellent in the beginning, middle, and in the end លម្អបទដើម បទកណ្តាល និងបទចុង

beings with little dust in their eyes សត្វទាំងឡាយដែលមានធុលី (រាគៈ) តិចក្នុងភ្នែក

commence his sublime mission ចាប់ផ្តើមនូវ(ធម្ម)បេសកកម្មដ៏វិសេសរបស់ព្រះអង្គ

monastery វត្ត ; monastic monk បព្វជិត ឬអ្នកបួស (ភិក្ខុ សាមណេរ)

a successful ministry of forty-five years ពុទ្ធកិច្ចប្រកបដោយជោគជ័យអស់រយៈពេល ៤៥ ព្រះវស្សា

twin Sāla Trees ដើមសាលព្រឹក្ស (ដើមរាំង) ទាំងគូ

# ការផ្សព្វផ្សាយព្រះធម៌

បន្តបន្ទាប់មក ព្រះសម្មាសម្ពុទ្ធទ្រង់គង់ចាំព្រះវស្សានៅព្រៃឥសិបតនៈមិគទាយវ័ន ដែលបច្ចុប្បន្ននេះ ជាទីសក្ការៈបូជា ចំពោះមនុស្សជាតិជាង ៦០០ លាននាក់។ ក្នុងអំឡុង ៣ខែនៃរដូវវស្សា មាណព ៥០ នាក់ដទៃទៀតដឹកនាំដោយ យសៈ ជាកម្លោះវ័យក្មេង នៃត្រកូលកុដុម្ពីមានទ្រព្យច្រើនម្នាក់ បានចូលបព្វជ្ជា។ ឥលូវនេះ ព្រះពុទ្ធបានសាវ័ក ចំនួន៦០ អង្គគត់ ដែលសុទ្ធតែជាព្រះអរហន្តទាំងអស់ បានសម្រេចធម៌ និងមានសមត្ថភាពពេញលេញដើម្បីបង្រៀនអ្នកដទៃបាន។ ពេលរដូវវស្សាបានបញ្ចប់ទៅ ព្រះសាស្តាទ្រង់ត្រាស់ទៅកាន់សាវ័កទាំងឡាយថ្មីថ្មោងរបស់ព្រះអង្គ ដោយពាក្យដូចនេះ៖

"ម្នាលភិក្ខុទាំងឡាយ តថាគតបានរួចរដោះចាកចំណងទាំងឡាយហើយ ទោះមនុស្ស ឬទេព្តា ។ អ្នកទាំងឡាយក៏ដូចគ្នា បានរួចរដោះហើយចាកសំយោជនៈទាំងឡាយ (គ្រឿងសៅហ្មងដែលចងសត្វទុកក្នុងភព) មិនថាមនុស្ស ឬទេព្តា។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក (គឺស្រុក និគម និងរាជធានីហើយសម្តែងធម៌) ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនច្រើនគ្នា ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវមួយជាមួយគ្នាឡើយ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ឱ្យពីរោះ បទដើម បទកណ្តាល និងបទខាងចុង អ្នកទាំងឡាយ ចូរប្រកាសនូវ ព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់។ សត្វទាំងឡាយដែលមានធូលីគឺកិលេសស្តើងនៅក្នុងកែវភ្នែកនៅមាន ព្រោះតែមិនបានស្តាប់ធម៌ក៏បាត់អស់ អ្នកដែលអាចស្តាប់ធម៌ហើយយល់ដឹងក៏នៅមាន ម្នាលភិក្ខុទាំងឡាយ ចំណែកយើងតថាគតក៏នឹងទៅកាន់តំបន់ឧរុវេលាសេនានិគម ដើម្បីសម្តែងព្រះធម៌ដែរ។"

ហេតុនោះហើយ ព្រះសម្មាសម្ពុទ្ធបានចាប់ផ្តើមនូវធម្មបេសកកម្មដ៏ប្រសើររបស់ព្រះអង្គ រហូតដល់ទីបញ្ចប់នៃជីវិត។ ជាមួយសាវ័កទាំងឡាយ ព្រះអង្គបានត្រាច់ទៅ តាមផ្លូវតូច ផ្លូវធំ ក្នុងប្រទេសឥណ្ឌា ពោរពេញដោយព្រះទ័យករុណា និងបញ្ញាឥត

ព្រំដែនកំណត់ ។ ទោះបីជា គណៈសង្ឃបានចាប់ផ្ដើមកិច្ចការដំបូងមានត្រឹមតែ៦០អង្គក្តី សហគមន៍នេះបានរីកធំឆាប់រហ័សរហូតដល់ចំនួនរាប់ពាន់ ហើយជាលទ្ធផលនៃការកើនឡើងនូវចំនួនព្រះសង្ឃ វត្តអារាមជាច្រើនក៏បានកកើតឡើងជាលំដាប់។
សម័យក្រោយមកទៀត សាកលវិទ្យាល័យឥណ្ឌាផ្នែកសាសនា(ពុទ្ធចក្រ) ដូចជាសាកលវិទ្យាល័យ **នាលន្ទា វិក្រមៈសីលា ជគទ្ទលា វិក្រមៈបុរី និង ឱទន្តបុរី** ជាដើមបានក្លាយទៅជាមជ្ឈមណ្ឌលវប្បធម៌ ហើយបានបន្តជះឥទ្ធិពលជាលំដាប់ទៅកាន់ទ្វីបអាស៊ីទាំងមូល និងតាមរយៈផ្លូវចិត្តនៃមនុស្សជាតិ។

បន្ទាប់ពីពុទ្ធកិច្ច ៤៥ ព្រះវស្សា ប្រកបដោយជោគជ័យហើយ ព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វានក្នុងព្រះជន្ម ៨០ ព្រះវស្សា នៅចន្លោះសាលព្រឹក្សទាំងគូ នៃដែនមល្លៈ ក្នុងក្រុងកុសិណារា (សព្វថ្ងៃនេះហៅថា **ឧត្តរៈប្រទេស** ចម្ងាយប្រហែល ១២០ម៉ាលស៍ ទិសឥសាន្ត នៃក្រុងពារាណសី ។

## The Buddha's Ministry

During his long ministry of forty-five years the Buddha walked widely throughout the northern districts of India. But during the rains retreat (vassā), he generally stayed in one place. Here follows a brief sketch of his retreats gathered from the texts:

1st year: Vāranasī. After the first proclamation of the Dhamma on the full moon day of July, the Buddha spent the first vassā at Isipatana, Vārānasī.

The 2nd, 3rd, and 4th years: Rājagaha (in the Bamboo Grove, Veḷuvana). It was during the third year that Sudatta, a householder of Sāvatthī known for his bounty as Anāthapiṇḍika, "the feeder of the forlorn," having heard that a Buddha had come into being, went in search of him, listened to him, and having gained confidence (saddhā) in the Teacher, the Teaching, and the Taught (the Buddha, Dhamma, and Sangha), attained the first stage of sainthood (sotāpatti). He was renowned as the chief supporter (dāyaka) of the Master. Anāthapiṇḍika had built the famous Jetavana monastery at Sāvatthī, known today as Sahet-mahet, and offered it to the Buddha and his disciples. The ruins of this monastery are still to be seen.

5th year: Vesālī. The Buddha kept retreat in the Pinnacled Hall (kuṭāgārasālā). It was at this time that King Suddhodana fell ill. The Master visited him and preached the Dhamma, hearing which the king attained perfect sanctity (arahatta), and after enjoying the bliss of emancipation for seven days, passed away. The Order of Nuns was also founded during this time.

6th year: Mankula Hill. Here the Buddha performed the "Twin Wonder" (yamaka pāṭihāriya). He did the same for the first time at Kapilavatthu to overcome the pride of the Sakyas, his relatives.

7th year: Tāvatiṃsa (the Heaven of the Thirty-three). Here the Buddha preached the Abhidhamma or the Higher Doctrine to the deities (devas) headed by his mother Mahāmāya, who had passed away seven days after the birth of Prince Siddhattha, and was reborn as a deva in the Tāvatiṃsa.

8th year: Bhesakalā Forest (near Sumsumāragiri). It was here that Nakulapita and his wife, a genial couple, came to see the Buddha, told him about their very happy married life, and expressed the wish that they might continue to live together both here and hereafter. These two were placed by the Buddha as chiefs of those that win confidence.

9th year: Kosambī -at the Ghosita Monastery.

10th year: Pālileyyakka Forest. It was in the tenth year that, at Kosambī, a dispute arose between two parties of monks owing to a trivial offence committed by a monk. As they could not be reconciled, and as they did not pay heed to his exhortation, the Buddha retired to the forest. At the end of the vassā, their dispute settled, the monks came to Sāvatthi and begged pardon of the Buddha.

11th year: Village of Ekanāla (in the Magadha country). It was here that the Buddha met the brahmin farmer Kasibhāradvāja who spoke to theBuddha somewhat discourteously. The Buddha, however, answered his questions with his characteristic sobriety. Bhāradvāja became an ardent follower of the Buddha. It was on this occasion that the very interesting discourse, Kasibharadvaja Sutta (Suttanipāta), was delivered. (Read The Book of Protection by this author (BPS).)

12th year: Verañja. The introduction of the Vinaya is attributed to the twelfth year. It was also during this retreat that the brahmin Verañja came to see the Buddha, asked a series of questions on Buddhist practices, and being satisfied with the answers, became a follower of the Blessed One. He invited the Master and the Sangha to spend the rainy season (vassā) at his village Verañja. At that time there was a famine. The Buddha and his disciples had to be satisfied with very coarse food supplied by horse merchants. As it was the custom of the Buddha to take leave of the inviter before setting out on his journeying, he saw the brahmin at the end of the vassā. The latter admitted that though he had invited the Buddha and his disciples to spend the retreat at Verañja, he had failed in his duties towards them during the entire season owing to his being taxed with household duties. However, the next day he offered food and gifts of robes to the Buddha and the Sangha.

13th year: Cāliya Rock (near the city of Cālika). During this time the elder Meghiya was his personal attendant. The elder being attracted by a beautiful mango grove near a river asked the Buddha for permission to go there for meditation. Though the Buddha asked him to wait till another monk came, he repeated the request. The Buddha granted him permission. The elder went, but to his great surprise he was oppressed by thoughts of sense pleasures, ill will, and harm, and returned disappointed. Thereupon the Buddha said: “Meghiya, for the deliverance of the mind of the immature, five things are conducive to their maturing: (1) a good friend; (2) virtuous behaviour guided by the essential precepts for training; (3) good counsel tending to dispassion, calm, cessation, enlightenment and Nibbana; (4) the effort to abandon evil thoughts, and (5) acquiring of wisdom that discerns the rise and fall of things.”

14th year: Jetavana monastery, Sāvatthī. During this time the Venerable Rāhula, who was still a novice (sāmaṇera), received higher ordination (upasampadā). According to the Vinaya, higher ordination is not conferred before the age of twenty; Venerable Rāhula had then reached that age.

15th year: Kapilavatthu (the birthplace of Prince Siddhattha). It was in this year that the death occurred of King Suppabuddha, the father of Yasodharā.

16th year: City of Ālavi: During this year Ālavaka, the demon who devoured human flesh, was tamed by the Buddha. He became a follower of the Buddha. For Ālavaka's questions and the Master's answers read the Ālavaka Sutta, in the Sutta-nipata. (See The Book of Protection, p.81 by this author (BPS).)

17th year: Rājagaha, at Veḷuvana Monastery. During this time a well-known courtesan, Sirīmā, sister of Jīvaka the physician, died. The Buddha attended the funeral, and asked the king to inform the people to buy the dead body-the body that attracted so many when she was alive. No one cared to have it even without paying a price. On that occasion, addressing the crowd, the Buddha said in verse:

> “Behold this painted image, a body full of wounds,
> heaped up (with bones), diseased,
> the object of thought of many, in which

there is neither permanence nor stability.”

Dhammapada, 147

18th year: Cāliya Rock. During this time a young weaver's daughter met the Buddha and listened to his discourse on mindfulness of death (maraṇānussati). On another occasion she answered correctly all the four questions put to her by the Master, because she often pondered over the words of the Buddha. Her answers were philosophical, and the congregations who had not given a thought to the Buddha word, could not grasp the meaning of her answers. The Buddha, however, praised her and addressed them in verse thus:

“Blind is this world;
few here clearly see.
Like a bird that escapes from the net,
only a few go to a good state of existence."

Dhammapada, 174

She heard the Dhamma and attained the first stage of sanctity (sotāpatti). But unfortunately she died an untimely death. (For a detailed account of this interesting story, and the questions and answers, see the Commentary on the Dhammapada, Vol. III, p.170, or Burlingame, Buddhist Legends, Part 3, p.14.)

19th year: Cāliya Rock.

20th year: Rājagaha, at Veḷuvana Monastery.

From the 21st year till the 43rd year: Sāvatthī. Of these twenty-four vassās, eighteen were spent at Jetavana Monastery, the rest at Pubbārāma. Anāthapiṇḍika and Visākhā were the chief supporters.

44th year: Veluva (a small village, probably situated near Vesālī), where the Buddha suppressed, by force of will, a grave illness.

In the 45th year of his Enlightenment, the Buddha passed away at Kusiṇārā in the month of May (vesākha) before the commencement of the rains.

During the first twenty years of the Buddha's life, the bhikkhus Nāgasamāla, Nāgita, Upavāna, Sunakkhatta, Sāgata, Rādha, and Meghiya, and the novice (samanera) Cunda attended upon him, though not regularly. However,

after the twentieth year, the Buddha wished to have a regular attendant. Thereon all the great eighty arahats, like Sārīputta and Moggallāna, expressed their willingness to attend upon their Master. But this did not meet with his approval. Perhaps the Buddha thought that these arahats could be of greater service to humanity. Then the elders requested Ānanda Thera, who had kept silent all this while, to beg of the Master to be his attendant. Ānanda Thera's answer is interesting. He said, “If the Master is willing to have me as his attendant, he will speak.” Then the Buddha said:

“Ānanda, let not others persuade you. You on your own may attend upon me.”

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| The Buddha's Ministry | ពុទ្ធកិច្ច |
| Bamboo Grove (Veḷuvana) | វេឡុវ័នឧទ្យាន |
| householder | គហបតី (សេដ្ឋី) |
| deity (Devatā) | ទេវតា |
| confidence (Saddhā) | សទ្ធា |
| the chief supporter (Dāyaka) | អគ្គទាយក ជាកំពូលនៃឧបាសកទាំងឡាយផ្នែកឱ្យទាន |
| preach the Dhamma | សម្ដែងធម្មទេសនា |
| attained perfect sanctity (Arahatta) | បានសម្រេចនូវព្រះអរហត្ត |
| enjoying the bliss of emancipation | សោយវិមុត្តិសុខ |
| attained the first stage of sainthood (Sotāpatti) | បានសម្រេចនូវអរិយមគ្គថ្នាក់ដំបូង (សោតាបត្តិ) |
| "the feeder of the forlorn" (Anāthapiṇḍika) | អនាថបិណ្ឌិក អ្នកផ្គត់ផ្គង់ដល់ទុគ៌តជនកំសត់អត់ទីពឹង |
| Twin Wonder, Twin Miracle" (Yamaka Pāṭihāriya) | យមកបាដិហារិយ |
| to overcome the pride of the Sakyas | ដើម្បីផ្ចាញ់នូវមានះនៃសក្យវង្ស |
| the Heaven of the Thirty-three (Tāvatiṃsa) | ឋានតាវតឹស (តាវតិង្ស) ទីកើតនៃជន ៣៣ រូប |
| the Higher Doctrine (Abhidhamma) | ព្រះអភិធម្ម ធម៌ដ៏ខ្ពង់ខ្ពស់ ល្អិតសុខុមក្រៃលែង |
| both here and hereafter | ទាំងក្នុងជាតិនេះ និងជាតិខាងមុខ (បរលោក) |
| trivial offence | អាបត្តិ ឬទោសកំហុសតិចតួច |
| did not pay heed to his exhortation | មិនបានយកចិត្តទុកដាក់នឹងពាក្យទូន្មាន |
| beg pardon of the Buddha | សូមខមាទោសចំពោះព្រះពុទ្ធ |
| famine | គ្រោះទុរ្ភិក្ស (គ្រោះអត់អាហារ) |
| personal attendant | ឧបដ្ឋាកៈ (អ្នកគាល់បម្រើ) |
| oppressed by the thoughts of sense pleasures | សង្កត់សង្កិនដោយកាមវិតក្កៈ |
| sobriety | ដោយសេចក្ដីរម្យទម ឬប្រាកដប្រជា |

| | |
|---|---|
| virtuous behaviour | អាកប្បកិរិយាប្រកបដោយគុណធម៌ (សីល) |

The Order of Nuns ភិក្ខុនីឧបសម្បទា ឬ ភិក្ខុនីសង្ឃ (គណសង្ឃនៃសាមណេរី និងភិក្ខុនី)

| | |
|---|---|
| good counsel tending to dispassion | ពាក្យទូន្មានល្អប្រព្រឹត្តទៅដើម្បីវិរាគៈ (ការអស់ទៅនៃតម្រេក) |
| the effort to abandon evil thoughts | សេចក្ដីព្យាយាមដើម្បីកម្ចាត់បង់នូវអកុសលវិតក្កៈ |
| the mind of the immature | ចិត្តរបស់បុគ្គលដែលនៅទន់ខ្ចី |
| higher ordination (Upasampadā) | ឧបសម្បទា បួសជាភិក្ខុ |
| a novice monk (Sāmaṇera) | សាមណេរ |
| Āḷavaka, the demon | អាឡវកយក្ស |
| courtesan, Sirimā | ស្ត្រីផ្កាមាស សិរិមា |
| funeral បុណ្យសព ; | dead body សាកសព |
| praise សរសើរ ; | blame និន្ទា |
| commentary on the Dhammapada | ធម្មបទអដ្ឋកថា |
| commencement of the rains | ចេញវស្សា |
| tame | ទូន្មាន ហាត់ពត់ ផ្សាំង |
| weaver | អ្នកតម្បាញ |

Mindfulness of death (Maraṇānussati) មរណានុស្សតិកម្មដ្ឋាន

| | |
|---|---|
| ponder over | សញ្ជឹងគិត |
| congregation | ក្រុមមនុស្សដែលជួបជុំគ្នាធ្វើសក្ការៈបូជា |
| untimely death (Akālamaraṇa) | អកាលមរណៈ សេចក្ដីស្លាប់មុនកាលកំណត់ |
| a grave illness | អាពាធ ឬប្រឈួនធ្ងន់ |
| great eighty Arahats | អសីតិមហាសាវ័ក (អគ្គសាវ័កកំពូល ៨0 អង្គ) |

acquiring of wisdom that discerns the rise and fall of things
ចម្រើននូវបញ្ញាដែលពិចារណាឃើញនូវការកើត និងការលត់នៃធម៌ទាំងឡាយ(ឧទយព្វយញ្ញាណ)

# ពុទ្ធកិច្ច

ក្នុងអំឡុងពេលដ៏វែងនៃពុទ្ធកិច្ចរបស់ព្រះអង្គចំនួន ៤៥ ព្រះវស្សា ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅទូទាំងស្រុកនិគមភាគខាងជើងនៃប្រទេសឥណ្ឌា។ ប៉ុន្តែក្នុងពេលចូលព្រះវស្សា ជាទូទៅ ព្រះអង្គទ្រង់គង់មួយកន្លែង។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃការគង់ចាំវស្សារបស់ព្រះអង្គ ដែលបានដកស្រង់ចេញពីគម្ពីរផ្សេងៗ។

***វស្សាទី១***: ក្រុងពារាណសី ។ បន្ទាប់ពីប្រកាសសម្តែងបឋមទេសនានៅថ្ងៃពេញបូរណ៌មី ខែកក្កដា (អាសាឍ)ហើយ ព្រះសម្មាសម្ពុទ្ធបានគង់ចាំវស្សាដំបូងនៅព្រៃឥសិបតនៈ ក្រុងពារាណសី។

***វស្សាទី២ ទី៣ និងទី៤***: ក្រុងរាជគ្រឹះ ឬ រាជគហៈ (នៅក្នុងព្រៃឫស្សី វេឡុវ័ន)។ គឺក្នុងវស្សាទី៣ **សុទត្តៈ** ដែលជាគហបតីនៃក្រុងសាវត្ថី ត្រូវបានគេស្គាល់ថាជា **អនាថបិណ្ឌិក "អ្នកផ្គត់ផ្គង់ដល់ទុរគតជន"** ពេលបានឮថាព្រះពុទ្ធយាងមក ក៏បានចូលទៅរកព្រះអង្គ បានស្តាប់ធម៌ ហើយក៏មានសទ្ធាជ្រះថ្លាក្នុងព្រះសាស្តា ក្នុងការបង្រៀន និងក្នុងបុគ្គលដែលត្រូវបានព្រះអង្គបង្រៀន (ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ) ហើយក៏បានសម្រេចនូវអរិយមគ្គថ្នាក់ដំបូង (សោតាបត្តិ)។ គាត់ត្រូវបានគេស្គាល់ថាជា **អគ្គទាយក** របស់ព្រះសាស្តា កំពូលលើឧបាសកទាំងឡាយផ្នែកឲ្យទាន។ អនាថបិណ្ឌិក បានកសាងវត្តជេតពន ដ៏ល្បីល្បាញនៅក្រុងសាវត្ថី ដែលសព្វថ្ងៃគេស្គាល់ថាជា **សាហេត មាហេត** (Sahet-mahet) ហើយបានវេរថ្វាយដល់ព្រះសម្មាសម្ពុទ្ធ និងសាវ័ករបស់ព្រះអង្គ។ សំណល់បាក់បែកនៃវត្តនេះឃើញមានរហូតដល់សព្វថ្ងៃ។

***វស្សាទី៥***: វេសាលី ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំវស្សាក្នុង កូដាគារសាលា នាព្រៃមហាវ័ន។ គ្រានោះឯង ដែលព្រះបាទសុទ្ធោទនៈទ្រង់ប្រឈួន ។
ព្រះសាស្តាទ្រង់យាងទៅរកព្រះបិតា ហើយបានសម្តែងធម៌ ព្រះរាជាទ្រង់បានស្តាប់ហើយក៏បានសម្រេចអរហត្តផល ក្រោយពីបានសោយវិមុត្តិសុខអស់រយៈពេល៧ថ្ងៃ ក៏បានបរិនិព្វានទៅ។ ភិក្ខុនីឧបសម្បទា ក៏ត្រូវបានបង្កើតឡើងក្នុងអំឡុងពេលនោះឯង ។

***វស្សាទី៦***: ភ្នំមង្កុលៈ ឬ មកុលបព៌ត។ នៅទីនេះព្រះសម្មាសម្ពុទ្ធបានសម្តែងយមកប្បាដិហារ្យ។ ព្រះអង្គបានសម្តែងដូចគ្នា លើកទី១នៅនគរកបិលវត្ថុ ដើម្បីផ្ចាញ់នូវមានៈនៃសក្យវង្ស ដែលជាព្រះញាតិព្រះអង្គ។

***វស្សាទី៧***: ឋានតាវតិង្ស (ទីកើតនៃជន៣៣រូប)។ នៅទីនេះ ព្រះអង្គទ្រង់សម្តែងព្រះអភិធម្ម ឬព្រះធម៌ដ៏ល្អិតសុខុមដល់ពួកទេព្តា ក្រោមអធិបតីភាពនៃព្រះពុទ្ធមាតា មហាមាយាទេវី ដែលបានសោយទីវង្គត់៧ថ្ងៃបន្ទាប់ពីប្រសូតិព្រះរាជបុត្រសិទ្ធត្ថ ហើយបានទៅបដិសន្ធិជាទេពធីតាក្នុងឋានតាវតឹង្សនេះ។

***វស្សាទី៨***: ភេសកលាវ៉ន (ក្បែរក្រុងសុំសុមារគិរី ដេនភគ្គៈ) ។ គឺនៅទីនោះហើយដែល នកុលបិតា និង នកុលមាតា ដែលជាប្តីប្រពន្ធចិត្តបុណ្យ បានចូលគាល់ព្រះសម្មា សម្ពុទ្ធ ហើយទូលព្រះអង្គអំពីជីវិតអាពាហ៍ពិពាហ៍ដ៏មានសុភមង្គលរបស់ពួកគេ ហើយថាពួកគេនឹងបន្តរស់នៅជាគូព្រេងនឹងគ្នាក្នុងជាតិនេះ និងជាតិខាងមុខ។ គូស្វាមីភរិយាទាំងពីរនេះ ត្រូវបានតែងតាំងដោយព្រះសម្មាសម្ពុទ្ធ ជាកំពូលលើឧបាសកឧបាសិកាទាំងឡាយផ្នែកមានសទ្ធា។

***វស្សាទី៩***: ក្រុងកោសម្ពី -- នៅវត្តឃោសិតារាម។

***វស្សាទី១០***: ព្រៃបាលិលេយ្យកៈ។ គឺនៅវស្សាទី១០ នាក្រុងកោសម្ពីនេះឯងមានជម្លោះមួយបានកើតឡើងរវាងភិក្ខុពីរបក្សដោយសារតែទោសកំហុសតិចតួចត្រូវបានប្រព្រឹត្តដោយភិក្ខុ១អង្គ។ ដោយសារភិក្ខុទាំងនោះមិនអាចផ្សះផ្សារគ្នាបានផង មិនបានយកចិត្តទុកដាក់ស្តាប់ពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធផង ព្រះអង្គក៏បានយាងចេញទៅសម្រាក (ចាំព្រះវស្សា)នៅក្នុងព្រៃ។ ពេលចេញព្រះវស្សា ជម្លោះនៃភិក្ខុទាំងនោះក៏បានដោះស្រាយហើយ ភិក្ខុទាំងពីរអង្គបានទៅកាន់ក្រុងសាវត្ថី និងបានសុំខមាទោសចំពោះព្រះដ៏មានព្រះភាគ។

***វស្សាទី១១***: នៅភូមិឯកនាលា (ក្នុងនគរមគធៈ)។ គឺនៅទីនោះហើយដែលព្រះសម្មាសម្ពុទ្ធបានជួបព្រាហ្មណ៍អ្នកស្រែម្នាក់ឈ្មោះ កសិភារៈទ្វាជៈ ដែលបានពោលទៅកាន់ព្រះពុទ្ធដោយពាក្យជេរប្រមាថ។ ព្រះសម្មាសម្ពុទ្ធ ទោះបីយ៉ាងណា ទ្រង់ឆ្លើយតបនូវសំណួររបស់ព្រាហ្មណ៍ដោយសេចក្តីទន់ភ្លន់រម្យទម ប្រាកដប្រជា។ ភារទ្វាជៈ បានក្លាយជាសាវ័កដ៏ក្លៀវក្លារបស់ព្រះសម្មាសម្ពុទ្ធ។ គឺក្នុងពេលនោះហើយដែលព្រះសូត្រគួរឱ្យចាប់

អារម្មណ៍មួយឈ្មោះថា កសិភារទ្វាជសូត្រ (សុត្តនិបាត) ត្រូវបានលើកមកសម្តែង។ *(សូមអាន សៀវភៅបរិត្ត ដោយអ្នកនិពន្ធអង្គនេះផ្ទាល់ (BPS) Read the Book of Protection by this author (BPS).) ។*

***វស្សាទី១២***: វេរញ្ជៈគ្រាម។ ការចាប់ផ្តើមនៃការបញ្ញត្តព្រះវិន័យ គឺបានកើតឡើងនៅវស្សាទី១២នេះឯង។ គឺនៅក្នុងវស្សានេះដែរ ដែលវេរញ្ជព្រាហ្មណ៍បានមកគាល់ព្រះសម្មាសម្ពុទ្ធ សាកសួរនូវសំណួរជាច្រើនអំពីកិច្ចបដិបត្តិក្នុងពុទ្ធសាសនា ហើយបានពេញចិត្តជាមួយនឹងការសម្តែងព្រះធម៌របស់ព្រះអង្គ ក៏បានក្លាយជាសាវ័កមួយរូបនៃព្រះដ៏មានព្រះភាគ។ ព្រាហ្មណ៍បាននិមន្តព្រះសាស្តា មួយអន្លើដោយភិក្ខុសង្ឃទាំងឡាយដើម្បីគង់ចាំវស្សានៅក្នុងវេរញ្ជៈគ្រាម ដែលជាភូមិរបស់ខ្លួន។ គ្រានោះ មានគ្រោះទុរ្ភិក្សមួយបានកើតឡើង។ ព្រះសម្មាសម្ពុទ្ធ និងសាវ័កទាំងឡាយរបស់ព្រះអង្គ ត្រូវឆាន់អាហារក្រៀមក្រោះដែលប្រគេនដោយឈ្មួញសេះ។ ជាប្រពៃណីនៃព្រះសម្មាសម្ពុទ្ធត្រូវចម្រើនពរលាដល់ម្ចាស់ទានដែលបាននិមន្ត មុននឹងយាងចេញដំណើរ ព្រះអង្គបានជួបនឹងព្រាហ្មណ៍នាថ្ងៃចេញព្រះវស្សា។ ព្រាហ្មណ៍បានសារភាពរៀបរាប់ ទោះបីគាត់បាននិមន្តព្រះសម្មាសម្ពុទ្ធ និងសាវ័កទាំងឡាយរបស់ព្រះអង្គ គង់ចាំវស្សានៅក្នុងវេរញ្ជៈគ្រាម ប៉ុន្តែគាត់មិនបានបំពេញកាតព្វកិច្ចគាល់បម្រើភិក្ខុសង្ឃសោះពេញមួយរដូវវស្សានេះ ដោយអាស្រ័យធុរៈកិច្ចគ្រួសារផ្ទាល់ខ្លួន។ ថ្វីបើដូច្នេះ ថ្ងៃបន្ទាប់មក គាត់បានថ្វាយចង្ហាន់និងស្បង់ចីវរដល់ព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃទាំងឡាយ។

***វស្សាទី១៣***: ចាលិយៈសិលា ឬចាលិយៈបព៌ត (ជិតក្រុងចាលិកៈ)។ កំឡុងកាលនោះ ព្រះមេឃិយៈមហាថេរ ជាឧបដ្ឋាកៈផ្ទាល់របស់ព្រះអង្គ។ ព្រៃស្វាយដ៏ស្រស់ស្អាតមួយនៅជិតស្ទឹងបានទាក់ទាញចិត្តរបស់ព្រះថេរៈ លោកក៏បានទូលសុំការអនុញ្ញាតពីព្រះសម្មាសម្ពុទ្ធដើម្បីទៅចម្រើនកម្មដ្ឋាននៅទីនោះ។ ទោះបីព្រះសម្មាសម្ពុទ្ធបានប្រាប់ឲ្យរង់ចាំភិក្ខុមួយអង្គទៀតមកដល់សិន ព្រះថេរៈនៅតែទទូចសុំដដែលៗ។ ព្រះសម្មាសម្ពុទ្ធក៏ទ្រង់អនុញ្ញាត។ ព្រះថេរៈបានចេញទៅ ប៉ុន្តែការភ្ញាក់ផ្អើលយ៉ាងខ្លាំងរបស់លោក គឺថាចិត្តរបស់លោកត្រូវបានគ្របសង្កត់ដោយ កាមច្ឆន្ទៈវិតក្កៈ ព្យាបាទៈវិតក្កៈ និង វិហឹសាវិតក្កៈ ហើយបានត្រឡប់មកវិញដោយខកចិត្ត។ ពេលនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ពុទ្ធដីកាថា "ម្នាលមេឃិយៈ ដើម្បីការរួចរដោះនៃចិត្តដែលនៅទន់ខ្សោយ មានធម៌៥ ដែលជាឧបការៈធ្វើឲ្យ

ចម្រើនបរិបូណ៌៖ (១) កល្យាណមិត្ត (២) ឥរិយាបថសមរម្យប្រកបដោយសីលសិក្ខា (៣) ពាក្យទូន្មានល្អប្រព្រឹត្តទៅដើម្បីវិរាគៈ សេចក្តីស្ងប់ សេចក្តីរំលត់ ការត្រាស់ដឹង និងព្រះនិព្វាន (៤) សេចក្តីព្យាយាមកម្ចាត់បង់នូវអកុសលវិតក្កៈ និង (៥) ការចម្រើនបញ្ញាដែលឃើញច្បាស់នូវការកើតឡើង និងការរលត់ទៅនៃធម៌ទាំងឡាយ"។

**វស្សាទី១៤**: វត្តជេតពន ក្រុងសាវត្ថី។ កំឡុងពេលនោះ ព្រះរាហ៊ុល ដែលជាសាមណេរនៅឡើយ បានទទួលឧបសម្បទាជាភិក្ខុភាវៈ។ យោងតាមព្រះវិន័យ ការបួសជាភិក្ខុ មិនត្រូវបានអនុញ្ញាតឡើយក្រោមអាយុ២០ឆ្នាំ។ ព្រះរាហ៊ុល នាពេលនោះ បានព្រះជន្មគ្រប់ល្មមដើម្បីឧបសម្បទា។

**វស្សាទី១៥**: និគ្រោធារាម កបិលវត្ថុ (នគរកំណើតនៃព្រះសិទ្ធត្ថរាជកុមារ)។ គឺនៅក្នុងឆ្នាំនេះឯង ដែលព្រះបាទសុប្បពុទ្ធ ជាព្រះបិតារបស់ព្រះនាងយសោធរា បានចូលទីវង្គត។

**វស្សាទី១៦**: ទីក្រុងអាឡវី។ ក្នុងវស្សានេះ អាឡវកៈ ជាយក្សដែលស៊ីសាច់មនុស្ស ត្រូវបានប្រោស(ទូន្មាន)ដោយព្រះសម្មាសម្ពុទ្ធ។ យក្សនោះបានក្លាយជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ។ សម្រាប់សំណួររបស់អាឡវកៈ និងចម្លើយរបស់ព្រះសាស្តា សូមអាន អាឡវកៈសូត្រ ក្នុងសុត្តនិបាត។ *(សូមមើលសៀវភៅ The Book of Protection, P.81 by this author (BPS).។*

**វស្សាទី១៧**: ក្រុងរាជគ្រឹះ នៅវត្តវេឡុវន។ អំឡុងកាលនោះ ស្ត្រីផ្កាមាសឈ្មោះសិរិមា ដ៏ល្បីល្បាញ ជាប្អូនស្រីរបស់គ្រូពេទ្យឈ្មោះជីវកៈ បានធ្វើមរណកាល។ ព្រះសម្មាសម្ពុទ្ធបាននិមន្តទៅពិធីបុណ្យសព ហើយទ្រង់បានស្នើព្រះរាជាប្រកាសឱ្យមហាជន មកទិញសាកសព កាយដែលធ្លាប់ជាទីចាប់អារម្មណ៍នៃមនុស្សជាច្រើនកាលដែលនាងនៅរស់។ គ្មានរណាម្នាក់អើពើចង់បានឡើយ ទោះបីមិនយកប្រាក់ក៏ដោយ។ ក្នុងឱកាសនោះ ព្រះសម្មាសម្ពុទ្ធត្រាស់ទៅកាន់មហាជនដោយគាថាយ៉ាងនេះ៖

"ចូរពិនិត្យមើលនូវរូប(អត្តភាព)នេះចុះ ជាកាយពោរពេញដោយដំបៅ
ផ្គុំឡើងដោយឆ្អឹង (៣០០កំណាត់) ជាសម្បុកនៃរោគ
ជាទីទាក់ទាញនៃជនទាំងឡាយ ក្នុងនោះ
មានសភាពមិនទៀង មិនឋិតថេរអមតៈឡើយ។" ធម្មបទ ១៤៧

**វស្សាទី១៨ និងទី១៩**: ចាលិយៈសិលា ឬចាលិយៈបព៌ត។ ក្នុងវស្សានោះ ធីតានៃជាងតម្បាញ បានជួបព្រះសម្មាសម្ពុទ្ធ និងបានស្តាប់ធម្មទេសនាអំពីមរណានុស្សតិកម្មដ្ឋាន។ ក្នុងសម័យមួយទៀត នាងបានឆ្លើយយ៉ាងត្រឹមត្រូវនូវសំណួរទាំង៤ ដែលសួរទៅនាងដោយព្រះបរមសាស្តា ពីព្រោះនាងធ្លាប់បានសញ្ជឹងគិតជារឿយៗទៅលើព្រះពុទ្ធដីកា។ ចម្លើយរបស់នាងគឺប្រកបដោយទស្សនវិជ្ជ តែមហាជនដែលមិនបានយកចិត្តទុកដាក់នឹងព្រះពុទ្ធដីកា មិនអាចចាប់សេចក្តីយល់នូវអត្ថន័យនៃចម្លើយរបស់នាងឡើយ។ ព្រះសម្មាសម្ពុទ្ធ យ៉ាងណាក្តី បានសរសើរនាង ហើយទ្រង់សម្តែងនូវគាថាដូចនេះ៖

"លោកនេះពោរពេញដោយភាពងងឹត(អវិជ្ជា)
មានជនតិចណាស់ដែលឃើញច្បាស់
ដូចជាបក្សីដែលរួចពីសំណាញ់
តិចណាស់ដែលបានទៅកាន់សុគតិភព"។ ធម្មបទ ១៧៤

នាងបានស្តាប់ព្រះធម៌ហើយក៏បានសម្រេចនូវសោតាបត្តិផល។ តែជាអកុសល នាងបានស្លាប់មុនកាលកំណត់ (អកាលមរណៈ) ។ (សំរាប់សេចក្តីពិស្តារនៃរឿងដ៏គួរចាប់អារម្មណ៍នេះ សំណួរនិងចម្លើយ សូមអានធម្មបទអដ្ឋកថា លេខ៣ ទំព័រ១៧០ ឬ Burlingame, Buddhist Legends, Parts 3, P14)។

**វស្សាទី២០**: ក្រុងរាជគ្រឹះ នៅវត្តវេឡុវន។

**វស្សាទី២១ ដល់ វស្សាទី៤៣**: ក្រុងសាវត្ថី ។ ក្នុងរយៈពេល ២៤ វស្សានេះ ១៨ វស្សាគង់នៅវត្តជេតពន នៅសល់គឺគង់នៅ វត្តបុព្វារាម ។ អនាថបិណ្ឌិកសេដ្ឋី និង នាងវិសាខា ជាអគ្គពុទ្ធសាសនូបត្ថម្ភក៍។

***បញ្ជាក់៖** តាមឯកសារខ្មែរ៖ "វស្សាទី២១ ដល់ វស្សាទី៤៥ ទ្រង់គង់ផ្លាស់ប្តូរគ្នារវាង វត្តជេតពន និងវត្តបុព្វារាម ទីក្រុងសាវត្ថី រួមទាំងមុនទាំងក្រោយអដ្ឋកថា ពោលថា ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅវត្តជេតពន ១៩ ព្រះវស្សា និងវត្តបុព្វារាម ៦ ព្រះវស្សា។"*

***វស្សាទី៤៤***: ពេឡុវៈ ឬវេឡុវៈគ្រាម (ជាភូមិតូចមួយ ប្រហែលស្ថិតនៅជិតក្រុងវេសាលី) នៅទីនោះព្រះសម្មាសម្ពុទ្ធទ្រង់សង្កត់នូវទុក្ខវេទនាដោយអធិវាសនខន្តី ព្រោះអាស្រ័យការមានប្រឈួនជាទម្ងន់។

***វស្សាទី៤៥***: នៃការត្រាស់ដឹងរបស់ព្រះអង្គ ព្រះសម្មាសម្ពុទ្ធទ្រង់ចូលបរិនិព្វាននៅកុសិនារា ក្នុងខែវិសាខ (ឧសភា) មុនដើមរដូវស្សា។

កំឡុងពេល ២០ វស្សាដំបូងនៃជីវិតរបស់ព្រះពុទ្ធ ភិក្ខុ នាគសមាលៈ នាគិតៈ ឧបវានៈ សុនក្ខត្តៈ សាគតៈ រាធៈ និង មេឃិយៈ ព្រមទាំងសាមណេរ ចុន្ទៈ បាននៅគាល់បម្រើដល់ព្រះដ៏មានព្រះភាគ ទោះបីមិនបានជាប្រចាំក្តី។ ទោះបីយ៉ាងណាក៏ដោយ ក្រោយពីវស្សាទី២០ ព្រះសម្មាសម្ពុទ្ធប្រាថ្នាចង់បានឧបដ្ឋាកៈ គាល់បម្រើជាប្រចាំមួយរូប។ ពេលនោះ អសីតិមហាសាវ័ក (អគ្គសាវ័កកំពូល៨0អង្គ) ដូចជា ព្រះសារីបុត្ត និងព្រះមោគ្គល្លានជាដើម បានសំដែងនូវឆន្ទៈចង់គាល់បម្រើនព្រះបរមសាស្តា។ ប៉ុន្តែរឿងនេះ ព្រះអង្គមិនទ្រង់អនុញ្ញាតឡើយ។ ប្រហែលជាព្រះសម្មាសម្ពុទ្ធទ្រង់ឈ្វេងយល់ថា ព្រះអរហន្តសាវ័កទាំងឡាយនេះ អាចធ្វើនូវប្រយោជន៍ផ្សេងៗជាច្រើនដល់មនុស្សជាតិ។

បន្ទាប់មក ព្រះមហាថេរទាំងនោះបានស្នើសុំ ព្រះអានន្ទត្ថេរ ដែលនៅស្ងៀមឈឹងមួយរយៈពេលនោះ ឱ្យសុំអង្វរព្រះសាស្តាយកខ្លួនធ្វើជាឧបដ្ឋាកៈរបស់ព្រះអង្គ។ ចម្លើយរបស់ព្រះអានន្ទ គួរឲ្យចាប់អារម្មណ៍ណាស់។ លោកពោលថា *"បើព្រះបរមសាស្តាចង់បានខ្ញុំព្រះអង្គជាឧបដ្ឋាកៈរបស់ទ្រង់មែន ព្រះអង្គនឹងមានពុទ្ធដីកាហើយ"*។ បន្ទាប់មក ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីកាថា "ម្នាលអានន្ទ ចូរកុំឲ្យអ្នកដទៃបញ្ចុះបញ្ចូលអ្នកឡើយ។ អ្នកខ្លួនឯងផ្ទាល់ អាចចូលមកបម្រើតថាគតបាន"។

## Buddhahood and Arahatship

Perfect Enlightenment, the discovery and realization of the Four Noble Truths (Buddhahood), is not the prerogative of a single being chosen by divine providence, nor is it a unique and unrepeatable event in human history. It is an achievement open to anyone who earnestly strives for perfect purity and wisdom, and with inflexible will cultivates the pāramī, the perfections which are the requisites of Buddhahood, and the Noble Eightfold Path. There have been Buddhas in the dim past and there will be Buddhas in the future when necessity arises and conditions are favourable. But we need not think of that distant future; now, in our present days, the “doors to the Deathless” are still wide open. Those who enter through them, reaching perfect sanctity or arahatship, the final liberation from suffering (Nibbāna), have been solemnly declared by the Buddha to be his equals as far as the emancipation from defilements and ultimate deliverance is concerned:

“Victors like me are they, indeed
They who have won defilements' end.”

The Buddha, however, also made clear to his disciples the difference between a Fully Enlightened One and the arahats," the accomplished saints:

“The Tathagata, O disciples, while being an arahat, is Fully Enlightened. It is he who proclaims a path not proclaimed before; he is the knower of a path, who understands a path, who is skilled in a path. And now his disciples are wayfarers who follow in his footsteps. That, disciples, is the distinction, the specific feature which distinguishes the Tathāgata, who being an arahat, is Fully Enlightened, from the disciple who is freed by insight.”

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

**Buddhahood and Arahatship ពុទ្ធភាវៈ និង អរហត្តភាវៈ/អរហត្តផល**
**(ភាពជាព្រះពុទ្ធ និង ព្រះអរហន្ត)**

perfection : Pāramī បារមី គុណជាតិដ៏ល្អដែលបុគ្គលគួរបំពេញ ឬគុណជាតិដែលនាំដល់ត្រើយនៃព្រះនិព្វាន

final liberation from suffering (Nibbāna) ការរួចរំដោះពីសេចក្តីទុក្ខដល់ទីបំផុត (និព្វាន)

emancipation from defilements, ultimate deliverance ការរំដោះពីកិលេសទាំងស្រុង

a Fully Enlightened One ព្រះសម្មាសម្ពុទ្ធ (បុគ្គលដែលត្រាស់ដឹងដោយបរិបូណ៌)

# ពុទ្ធភាវៈ និងអរហត្តភាវៈ

ការត្រាស់ដឹងដ៏ពេញបរិបូណ៌ ការរកឃើញ និងការចាក់ធ្លុះនូវអរិយសច្ចៈ៤ (ពុទ្ធភាវៈ) មិនមែនជាកម្មសិទ្ធិផ្តាច់មុខនៃជនណាម្នាក់ ដែលត្រូវបានជ្រើសរើសដោយអាទិទេពណាមួយនោះឡើយ ហើយក៏មិនមែនជាព្រឹត្តិការណ៍ដែលកើតឡើងញឹកញាប់ក្នុងប្រវត្តិមនុស្សជាតិនោះទេ។ នោះគឺជាសមិទ្ធផលដែលបើកចំហរដល់ជនណាដែលមានសេចក្តីព្យាយាមប្រឹងប្រែងខ្នះខ្នែងអស់ពីកម្លាំងកាយចិត្ត ដើម្បីសេចក្តីបរិសុទ្ធដ៏វិសេស និងបញ្ញាដ៏បរិបូរណ៌ ហើយដោយមិនមានការប្រែប្រួលផ្លាស់ប្តូរក្នុងការបំពេញនូវបារមី ជាគុណជាតិចាំបាច់ដើម្បីត្រាស់ដឹងជាព្រះពុទ្ធ និងអរិយអដ្ឋង្គិមគ្គ៨។ នៅក្នុងអតីតកាល ក៏ធ្លាប់មានព្រះពុទ្ធជាច្រើនព្រះអង្គ ហើយនឹងមានព្រះពុទ្ធជាច្រើនព្រះអង្គទៀតនៅក្នុងអនាគតកាលពេលភាពចាំបាច់កើតឡើង ហើយហេតុបច្ច័យដល់ព្រម។ ប៉ុន្តែ យើងមិនចាំបាច់គិតទៅដល់អនាគតដ៏វែងឆ្ងាយនោះទេ ឥឡូវនេះ ក្នុងបច្ចុប្បន្ននេះ "ទ្វារទៅកាន់អមតៈធម៌" នៅតែបើកចំហរយ៉ាងទូលំទូលាយ។ ជនទាំងឡាយណាដែលបានចូលតាមទ្វារទាំងនោះរមែងបានសំរេចនូវអរហត្តផល ការរួចរដោះដល់ទីបំផុតនៃទុក្ខ (និព្វាន) ដែលបានប្រកាសយ៉ាងច្បាស់ដោយព្រះសម្មាសម្ពុទ្ធថា អ្នកដទៃអាចស្មើព្រះអង្គដែរ ដរាបណា ការរួចរដោះចាកកិលេសទាំងឡាយ និង វិមុត្តិដ៏កំពូល បានកើតឡើង៖

"ជនជាអ្នកមានជ័យជម្នះទាំងឡាយ ដូចតថាគតជាដើម ជាការពិតណាស់
គឺជាបុគ្គលដែលបានយកឈ្នះ ហើយធ្វើនូវទីបំផុត នៃកិលេសទាំងឡាយ"។

ព្រះសម្មាសម្ពុទ្ធ ទោះបីយ៉ាងណាក្តី ក៏បានបញ្ជាក់យ៉ាងជាក់ច្បាស់ដល់សាវ័ករបស់ព្រះអង្គ នូវភាពខុសគ្នារវាងព្រះសម្មាសម្ពុទ្ធ (បុគ្គលដែលត្រាស់ដឹងដោយបរិបូណ៌) និង ព្រះអរហន្ត (បុគ្គលដែលបាននូវសេចក្តីបរិសុទ្ធ)៖

"ម្នាលសាវ័កទាំងឡាយ តថាគត ខណៈបានសម្រេចជាព្រះអរហន្តក៏បានសម្រេចជាព្រះសម្មាសម្ពុទ្ធដែរ។ គឺព្រះសម្មាសម្ពុទ្ធអង្គនោះ ដែលជាអ្នកប្រកាស

សំដែងនូវមគ្គ ដែលមិនធ្លាប់បានប្រកាសសម្ដែងពីមុនមក។ ព្រះអង្គជាបុគ្គលដែលបាន ស្គាល់ច្បាស់នូវមគ្គ បានចាក់ធ្លុះនូវមគ្គ និងជាបុគ្គលស្ទាត់ជំនាញក្នុងមគ្គ។ ឥឡូវនេះ សាវ័កទាំងឡាយជាអ្នកដំណើរ ដើរតាមយុគលបាទរបស់ព្រះអង្គ ។ ម្នាលសាវ័ក ទាំងឡាយ នេះហើយជាភាពដាច់ដោយឡែកពីគ្នា ទៅលើលក្ខណៈពិសេសដែលញែក តថាគត ដែលជាព្រះអរហន្តផង និងជាព្រះសម្មាសម្ពុទ្ធផង (អរហន្តសម្មាសម្ពុទ្ធ) ខុសអំពី សាវ័កទាំងឡាយ ជាបុគ្គលបានរួចចាកទុក្ខដោយបញ្ញា។

## Salient Features of the Dhamma

There are no dark corners of ignorance, no cobwebs of mystery, no smoky chambers of secrecy; there are no “secret doctrines,” no hidden dogmas in the teaching of the Buddha, which is open as daylight and as clear as crystal.

“The doctrine and discipline proclaimed by the Buddha shine when open and not when covered, even as the sun and moon shine when open and not when covered” (A.I,283).

The Master disapproved of those who professed to have “secret doctrines,” saying, “Secrecy is the hallmark of false doctrines.” Addressing the disciple Ānanda, the Master said: “I have taught the Dhamma, Ānanda, without making any distinction between exoteric and esoteric doctrine: for in respect of the truths, “Ānanda, the Tathāgata has no such thing as the closed fist of a teacher who hides some essential knowledge from the pupil.

A Buddha is an extreme rarity, but is no freak in human history. He would not preserve his supreme knowledge for himself alone. Such an idea would be completely ridiculous and abhorrent from the Buddhist point of view, and to the Buddha such a wish is utterly inconceivable. Driven by universal love and compassion, the Buddha expounded his teaching without keeping back anything that was essential for man's deliverance from the shackles of samsara, repeated wandering. The Buddha's teaching from beginning to end is open to all those who have eyes to see and a mind to understand. Buddhism was never forced upon anyone at the point of the gun or the bayonet. Conversion by compulsion was unknown among Buddhists and repugnant to the Buddha.

Of the Buddha's creed of compassion, H. Fielding Hall writes in The Soul of a People: “There can never be a war of Buddhism. No ravished country has ever borne witness to the prowess of the

followers of the Buddha; no murdered men have poured out their blood on their hearth-stones, killed in his name; no ruined women have cursed his name to high

heaven. He and his faith are clean of the stain of blood. He was the preacher of the Great Peace, of love of charity, of compassion, and so clear is his teaching that it can never be misunderstood.”

When communicating the Dhamma to his disciples, the Master made no distinctions whatsoever among them; for there were no specially chosen favourite disciples. Among his disciples, all those who were arhats, who were passion-free and had shed the fetters binding to renewed existence, had equally perfected themselves in purity. But there were some outstanding ones who were skilled in different branches of knowledge and practice, and because of their mental endowments, they gained positions of distinction; but special favours were never granted to anyone by the Master. Upāli, for instance, who came from a barber's family, was made the chief in matters of discipline (vinaya) in preference to many arhats who belonged to the class of the nobles and warriors (kshatriya). Sāriputta and Moggallāna, brahmins by birth, because of their longstanding aspirations in former lives, became the chief disciples of the Buddha. The former excelled in wisdom (paññā) and the latter in supernormal powers (iddhi).

The Buddha never wished to extract from his disciples blind and submissive faith in him or his teachings. He always insisted on discriminative examination and intelligent inquiry. In no uncertain terms he urged critical investigation when he addressed the inquiring Kalamas in a discourse that has been rightly called the first charter of free thought:

“Come, Kālāmas. Do not go by oral tradition, by lineage of teaching, by hearsay, by a collection of scriptures, by logical reasoning, by inferential reasoning, by reflection on reasons, by the acceptance of a view after pondering it, by the seeming competence of a speaker, or because you think, The ascetic is our teacher. But when you know for yourselves, “These things are unwholesome, these things are blamable; these things are censured by the wise; these things, if undertaken and practised, lead to harm and suffering,” then you should abandon them. And when you know for yourselves, “These things are wholesome, these things are blameless; these things are praised by the wise; these things, if

undertaken and practised, lead to welfare and happiness, then you should engage in them.”

To take anything on trust is not in the spirit of Buddhism, so we find this dialogue between the Master and the disciples: “If now, knowing this and preserving this, would you say: ‘We honour our Master and through respect for him we respect what he teaches?” “No, Lord.” “That which you affirm, O disciples, is it not only that which you yourselves have recognized, seen, and grasped?” “Yes, Lord.”

The Buddha faced facts and refused to acknowledge or yield to anything that did not accord with truth. He does not want us to recognize anything indiscriminately and without reason. He wants us to comprehend things as they really are, to put forth the necessary effort and work out our own deliverance with mindfulness.

> “You should make the effort
> The Tathāgatas point out the way?
> “Bestir yourselves, rise up,
> And yield your hearts unto the Buddha's teaching.
> Shake off the armies of the king of death,
> As does the elephant a reed-thatched shed”

The Buddha, for the first time in the world's history, taught that deliverance should be sought independent of a saviour, be he human or divine. The idea that another raises a man from lower to higher levels of life, and ultimately rescues him, tends to make man indolent and weak, supine and foolish. This kind of belief degrades a man and smothers every spark of dignity from his moral being. The Enlightened One exhorts his followers to acquire self-reliance. Others may lend us a helping hand indirectly, but deliverance from suffering must be wrought out and fashioned by each one for himself upon the anvil of his own actions.

# Dhamma Terminology វាក្យសព្ទព្រះធម៌

**Salient Features of the Dhamma លក្ខណៈលេចធ្លោ ឬចំណុចគួរកត់សម្គាល់នៃព្រះធម៌**

exoteric doctrine ទ្រឹស្តី ឬព្រះធម៌ដែលទូទៅសម្រាប់មហាជន (អាចយល់បានទូទៅគ្រប់គ្នា)

esoteric doctrine ទ្រឹស្តី ឬព្រះធម៌ដែលសម្រាប់តែមនុស្សមួយពួកតូចជាពិសេស

closed fist of a teacher (Ācariyamuṭṭhi) អាចរិយមុដ្ឋិ វិជ្ជាពិសេសរបស់គ្រូ (សម្រាប់ទុកឱ្យតែអ្នកបន្តវេន)

A Buddha is an extreme rarity ការកើតឡើងឬអត្តភាពជាព្រះពុទ្ធ គឺជាការក្រក្រៃលែង (ពុទ្ធុប្បាទោ ច ទុល្លភោ)

requisites of Buddhahood បច្ច័យ ឬលក្ខខណ្ឌចាំបាច់ដែលនាំឱ្យបានត្រាស់ដឹងជាព្រះពុទ្ធ

shackles of Saṃsāra, repeated wandering ច្រវាក់ ឬខ្នោះនៃសំសារៈ ត្រាច់ទៅមកដដែលៗ

the preacher of the Great Peace ជាសាស្តានៃមហាសន្តិ (អ្នកទេសនាទូន្មាននាំមកនូវសន្តិភាព)

universal love and compassion មេត្តា និងករុណាទូទៅឥតដែនកំណត់ (ចក្រវាឡ)

the Buddha expounds his teaching ព្រះពុទ្ធទ្រង់ត្រាស់សម្តែង ឬបង្រៀនព្រះធម៌

dogma លទ្ធិសាសនា (ប្រព័ន្ធនៃមាត្រាដែលគេជឿ ហើយយកមកគោរពតាម)

conversion by compulsion ការផ្លាស់ប្តូរ (សាសនា) ដោយការបង្ខិតបង្ខំ

Buddha's creed of compassion ពុទ្ធានុសាសនីប្រកបដោយករុណា

Prowess ភាពក្លាហាន ជំនាញ

passion-free វិរាគៈ ឬ រួចផុតចាកតម្រេក

"doors to the Deathless" ទ្វារទៅកាន់អមតធម៌ (សេចក្តីមិនស្លាប់)

Buddhist point of view ទស្សនៈ ឬការយល់ឃើញរបស់ពុទ្ធសាសនា

mental endowments សមត្ថភាពពិសេសខាងផ្លូវចិត្ត

chief disciple of the Buddha អគ្គសាវ័ករបស់ព្រះពុទ្ធបរមគ្រូ

position of distinction ឋានៈជាឯតទគ្គៈ

the chief in matters of discipline (Vinaya)
អគ្គសាវ័កក្នុងបញ្ហាព្រះវិន័យ (ឯតទគ្គៈផ្នែកខាងវិន័យ)

the class of the nobles and warriors (Kshatriya) វណ្ណៈអភិជន និងអ្នកចម្បាំង (ក្សត្រិយៈ)

| | |
|---|---|
| longstanding aspirations in former lives | សេចក្តីប្រាថ្នាជាយូរណាស់មកហើយ ក្នុងអតីតជាតិដ៏ច្រើន |
| supernormal powers (Iddhi) | ឥទ្ធិ ឫទ្ធិពិសេសលើសពីមនុស្សធម្មតា |
| do not go by oral tradition | កុំជឿគ្រាន់តែតាមទំនៀមទម្លាប់ប្រពៃណីដែលគេនិយាយតៗគ្នា |
| hearsay | ពាក្យចចាមអារ៉ាម លេចឮនិយាយពីមាត់មួយទៅមាត់មួយ |
| a collection of scriptures | តាមគម្ពីរ ក្បួនតម្រា |
| logical reasoning | តាមការត្រិះរិះ |
| inferential reasoning | តាមការសន្មត់ ឫសន្និដ្ឋាន |
| reflection on reasons | ការត្រិះរិះនូវហេតុ |
| seeming competence of a speaker | ស្តែងចេញតាមសមត្ថភាពរបស់អ្នកនិយាយ |
| unwholesome and blamable | អកុសល និង មានទោស (ដែលគួរឱ្យស្តីបន្ទោស) |
| wholesome and blameless | កុសល និង មិនមានទោស |
| censured by the wise | តិះដៀលដោយបណ្ឌិត |
| # praised by the wise | ពោលសរសើរដោយបណ្ឌិត |
| bestir yourselves | ប្រឹងប្រែងខ្នះខ្នែងដោយខ្លួនឯង (អស់ពីកម្លាំងកាយចិត្ត) |
| to degrade a man | ធ្វើឱ្យធ្លាក់គុណតម្លៃមនុស្ស បន្ទាបបន្ថោក |
| self-reliance | ការទីពឹងលើខ្លួនឯង |

the Enlightened One exhorts his followers
ព្រះពុទ្ធទ្រង់ទូន្មាន ឫដាស់តឿនសាវ័ករបស់ព្រះអង្គ

# លក្ខណៈពិសេសនៃព្រះធម៌

មិនមានជ្រុងងងឹតណាមួយនៃអវិជ្ជា មិនមានសំណាញ់ណាមួយនៃអាថ៌កំបាំង មិនមានបន្ទប់ផ្សេងណាមួយនៃអាថ៌កំបាំង មិនមានព្រះធម៌ណាមួយដែលអាថ៌កំបាំង មិនមានទ្រឹស្តីលាក់បាំងណាមួយក្នុងការបង្រៀនរបស់ព្រះពុទ្ធឡើយ មានតែការបើកចំហដូចពន្លឺថ្ងៃ ចែងចាំងច្បាស់ដូចជាកញ្ចក់។ "ធម៌ និងវិន័យដែលសម្តែងដោយព្រះពុទ្ធជាម្ចាស់មានពន្លឺចែងចាំងពេលបើកបង្ហាញ មិនមែនពេលលាក់បាំងទេ ប្រៀបដូចព្រះអាទិត្យ និងព្រះចន្ទមានពន្លឺចែងចាំងពេលរះបង្ហាញខ្លួនឡើង មិនមែនពេលបិទបាំងទេ"។

ព្រះសាស្តាមិនមានព្រះទ័យឯកភាពចំពោះអ្នកដែលយកមេរៀន ទៅធ្វើជា "ទ្រឹស្តីអាថ៌កំបាំង" ពោលគឺថា "អាថ៌កំបាំងគឺជាសញ្ញាសំគាល់នៃទ្រឹស្តីក្លែងក្លាយ"។ ព្រះសាស្តាទ្រង់មានពុទ្ធដីកាទៅកាន់ព្រះអានន្ទថា "ម្នាលអានន្ទ តថាគតបានបង្រៀនធម៌ដោយមិនមានការបែងចែកសម្រាប់មនុស្សទូទៅ និងមនុស្សតែមួយក្រុមឡើយ (លាក់ក្នុងលាក់ក្រៅ)។ ម្នាលអានន្ទ ដោយយោងតាមសច្ចធម៌ តថាគតមិនមាន **អាចរិយមុដ្ឋិ** គឺការលាក់នូវចំណេះវិជ្ជាពិសេសពីសិស្សឡើយ"។

អត្តភាពជាព្រះពុទ្ធគឺជាការក្រក្រៃលែង ប៉ុន្តែមិនចម្លែកក្នុងប្រវត្តិសាស្ត្ររបស់មនុស្សឡើយ។ ព្រះពុទ្ធមិនបានឱបទុកនូវវិជ្ជាពិសេសអស្ចារ្យសំរាប់ខ្លួនព្រះអង្គឡើយ។ គំនិតបែបនេះ ស្តាប់ទៅគួរអស់សំណើច និងគួរឆ្ងើម តាមទស្សនៈពុទ្ធសាសនា ហើយសំរាប់ព្រះពុទ្ធ បំណងប្រាថ្នាបែបនេះគឺពិបាកជឿ។ ប្រកបដោយព្រះទ័យមេត្តាករុណាចំពោះសព្វសត្វ ព្រះពុទ្ធទ្រង់សម្តែងនូវព្រះធម៌ ដោយគ្មានការលាក់បាំងនៅពីក្រោយ គឺបានបង្ហាញនូវធម៌ ប្រព្រឹត្តទៅដើម្បីការរួចរដោះរបស់មនុស្ស ចេញពីច្រវាក់ខ្នោះឃ្នាងនៃសង្សារវដ្ត ដែលជាដំណើរច្រំដែលអន្ទោលទៅវិញទៅមក។

ការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ តាំងពីដើមដល់ចប់ គឺបើកបង្ហាញដល់ជនទាំងឡាយដែលមានចក្ខុសម្រាប់មើល និងមានចិត្តសម្រាប់គិតយល់។ ព្រះពុទ្ធសាសនាមិនដែលបានបង្ខិតបង្ខំជនណាដោយអាវុធ ឬកាំភ្លើងឡើយ។ ការផ្លាស់ប្តូរសាសនាដោយ

ការបង្ខិតបង្ខំ គឺគ្មានទេនៅក្នុងចំណោមពុទ្ធសាសនិកទាំងឡាយ ហើយព្រះពុទ្ធក៏មិនបាន សព្វព្រះទ័យក្នុងរឿងនេះដែរ។ ។

នៅក្នុងទ្រឹស្តីរបស់ព្រះពុទ្ធស្តីអំពីសេចក្តីករុណា លោក H. Fielding Hall បាន សរសេរក្នុងសៀវភៅរបស់លោក *The Soul of a People*: "វានឹងមិនអាចមានសង្គ្រាម នៅក្នុងព្រះពុទ្ធសាសនាឡើយ។ មិនមានប្រទេសណាដែលត្រូវបានឈ្លានពាន ដោយ សាវ័កដែលដើរតាមព្រះពុទ្ធឡើយ។ មិនមានមនុស្សត្រូវគេធ្វើឃាត បង្ហូរឈាមស្រោចលើ ថ្ម ត្រូវបានសម្លាប់ក្នុងនាមព្រះសម្មាសម្ពុទ្ធឡើយ។ មិនមានស្ត្រីរងគ្រោះណា បានជេរ ដាក់បណ្តាសាក្នុងនាមព្រះអង្គឡើយ។ ព្រះពុទ្ធ និងសាសនារបស់ព្រះអង្គ គឺទទេស្អាត គ្មានស្នាមប្រឡាក់ឈាមឡើយ។ ព្រះអង្គគឺជាគ្រូបង្រៀននៃ **មហាសន្តិភាព សប្បុរសធម៌និយម** និង **ករុណាធម៌** ហើយច្បាស់លាស់ណាស់ គឺការបង្រៀនរបស់ព្រះអង្គ មិនអាចត្រូវបានគេច្រឡំឡើយ"។

នៅពេលបង្រៀនធម៌ដល់សាវ័ករបស់ព្រះអង្គ ព្រះសាស្តាមិនបានធ្វើការបែងចែក ណាមួយក្នុងចំណោមសាវ័កទាំងឡាយឡើយ ព្រោះមិនមានសាវ័កដែលព្រះអង្គសព្វ ព្រះទ័យជ្រើសរើសជាពិសេសអ្វីនោះទេ។ ក្នុងចំណោមសាវ័កទាំងឡាយ ដែលជាព្រះ អរហន្ត សុទ្ធជាបុគ្គលមិនមានរាគៈ និងបានកាត់ផ្តាច់នូវសញ្ញោជនៈដែលជាគ្រឿងបន្តភព ហើយសាវ័កទាំងនោះ បានធ្វើខ្លួនលោកឱ្យបរិសុទ្ធស្មើៗគ្នា។ ប៉ុន្តែមានសាវ័កមួយចំនួន ដែលជាអ្នកស្ទាត់ជំនាញនៅក្នុងវិជ្ជា និងចរណៈផ្សេងៗ ហើយដោយសារតែគុណវិសេស នៃការអប់រំចិត្តរៀងៗខ្លួន អរហន្តសាវ័កទាំងនោះបានទទួលនូវឯតទគ្គៈដោយឡែកៗ តាម ជំនាញរបស់ខ្លួន ប៉ុន្តែការសព្វព្រះទ័យពិសេសចំពោះសាវ័កណាមួយមិនមានទេ។

ជាឧទាហរណ៍ជាក់ស្តែង ព្រះឧបាលី ដែលបានចេញចាកត្រកូលជាខ្មាន់ព្រះកេស ត្រូវបាន តែងតាំងជាឯតទគ្គៈផ្នែកព្រះវិន័យ ជាជាងព្រះអរហន្តជាច្រើនអង្គផ្សេងទៀតដែលមក ពីវណ្ណៈអភិជន និង ខត្តិយវង្ស។ ព្រះសារីបុត្ត និង ព្រះមោគ្គល្លាន ដែលមានដើមកំណើត ចេញពីត្រកូលព្រាហ្មណ៍ ដោយសារតែសេចក្តីប្រាថ្នាជាយូរលង់ណាស់មកហើយពីអតីត ជាតិដ៏ច្រើន បានក្លាយជាអគ្គសាវ័កនៃព្រះពុទ្ធបរមគ្រូ។ អគ្គសាវ័កដំបូង គឺព្រះសារីបុត្ត ប្រសើរលើសគេខាងបញ្ញា ហើយអគ្គសាវ័កក្រោយ គឺព្រះមោគ្គល្លាន ប្រសើរលើសគេខាង ឫទ្ធានុភាព។

ព្រះសម្មាសម្ពុទ្ធ មិនដែលមានបំណងដើម្បីទទួលយកនូវសាវ័កទាំងឡាយ ដោយជំនឿងងឹតងងល់ និងងប់ជ្រប់ក្នុងព្រះអង្គ ឬក្នុងការបង្រៀនរបស់ព្រះអង្គឡើយ។ ព្រះអង្គតែងតែទទូចលើកទឹកចិត្តឱ្យមានការពិនិត្យច្បាស់លាស់ និងមានការសាកសួរប្រកបដោយបញ្ញា ។ ដោយគ្មានមន្ទិលសង្ស័យ ព្រះអង្គបានជំរុញឱ្យមានការពិនិត្យអង្កេតដោយហ្មត់ចត់ នៅពេលព្រះអង្គបានសំដែងទៅកាន់អ្នកដែនកាលាមៈ នៅក្នុងព្រះសូត្រមួយដែលហៅថា ***បុព្វសិទ្ធិនៃសេរីគំនិត*** (The First Charter of free thought)៖

"ចូរមក ម្នាលកាលាមៈទាំងឡាយ កុំប្រកាន់ជឿតាមទំនៀមទំលាប់ប្រពៃណីដែលគេនិយាយតៗគ្នា កុំប្រកាន់ជឿតាមការបង្រៀនតៗតាមសែស្រឡាយនៃត្រកូល កុំប្រកាន់ជឿតាមពាក្យចចាមអារាម កុំប្រកាន់ជឿតាមគម្ពីរក្បួនតម្រា កុំប្រកាន់ជឿដោយគ្រាន់តែតាមហេតុសមទំនង កុំប្រកាន់ជឿតាមហេតុដោយសន្និដ្ឋាន កុំប្រកាន់ជឿតាមការត្រិះរិះនូវហេតុផលទាំងឡាយ កុំប្រកាន់ជឿដោយទទួលយកនូវគំនិតក្រោយការពិចារណា កុំប្រកាន់ជឿដោយសំអាងលើបំនិនរបស់អ្នកនិយាយ ឬដោយសារអ្នកគិតថា "សមណៈនេះ គឺជាគ្រូរបស់យើង" ។ ប៉ុន្តែនៅពេលអ្នកយល់ដោយខ្លួនឯង "ធម៌ទាំងឡាយនោះជាអកុសល ធម៌ទាំងឡាយនោះនាំមកនូវទោស ធម៌ទាំងឡាយនោះបណ្ឌិតរមែងតិះដៀល ធម៌ទាំងឡាយនោះបើកាន់យក និងបដិបត្តិតាម នឹងនាំមកនូវទុក្ខទោស ដូច្នេះអ្នកទាំងឡាយ គួរលះបង់ចោល។ ហើយពេលអ្នកទាំងឡាយដឹងដោយខ្លួនឯងថា "ធម៌ទាំងឡាយនោះជាកុសល ធម៌ទាំងឡាយនោះមិនមានទោស ធម៌ទាំងឡាយនោះបណ្ឌិតទាំងឡាយតែងសរសើរ ធម៌ទាំងឡាយនោះបើកាន់យក និងបដិបត្តិតាម នឹងដឹកនាំទៅរកសេចក្តីចម្រើន និងសេចក្តីសុខ" ដូច្នេះ ចូរអ្នកទាំងឡាយបដិបត្តិតាមចុះ"។

ការទទួលយកអ្វីមួយដោយទុកចិត្ត មិនមែនជាស្មារតីរបស់ពុទ្ធសាសនាឡើយ ដូច្នេះយើងសិក្សាស្វែងយល់អំពីការសន្ទនានេះរវាងព្រះបរមសាស្តា និងសាវ័កទាំងឡាយៈ "ប្រសិនបើឥឡូវនេះ ដោយដឹងរឿងនេះ ហើយរក្សារឿងនេះ តើអ្នកនឹងនិយាយថា "យើងបូជាចំពោះព្រះសាស្តារបស់ពួកយើង ហើយដោយការគោរពចំពោះព្រះអង្គ យើងគោរពនូវអ្វីដែលព្រះអង្គបានបង្រៀនមែនទេ?" – "មិនមែនទេ បពិត្រព្រះបរមសាស្តាដ៏ចម្រើន" – "ម្នាលសាវ័កទាំងឡាយ អ្វីដែលអ្នកបានបញ្ជាក់អះអាង តើមិនមែនគឺជាអ្វី

ដែលអ្នកទាំងឡាយបានដឹង បានឃើញ និងបានយល់ទេឬ?″ – "ករុណា ពិតមែន បពិត្រព្រះអង្គដ៏ចម្រើន″។

ព្រះពុទ្ធបានជួបប្រទះនូវបញ្ហា និងសេចក្តីពិតមួយចំនួន ហើយបដិសេធមិនទទួលយកនូវអ្វីដែលមិនស្របនឹងសច្ចធម៌នោះទេ។ ព្រះអង្គមិនចង់ឱ្យយើងទទួលយកនូវអ្វីដោយមិនពិសមុខ ដោយប្រាសចាកហេតុផលឡើយ។ ព្រះអង្គចង់ឱ្យយើងជាក់ច្បាស់នូវធម៌តាមសភាពពិត ហើយបង្កើននូវសេចក្តីព្យាយាមដែលចាំបាច់ ដើម្បីរដោះខ្លួនប្រកបដោយសតិស្មារតី។

"អ្នកទាំងឡាយចូរញ៉ាំងសេចក្តីព្យាយាមឱ្យដល់ព្រម
តថាគតគ្រាន់តែបង្ហាញផ្លូវប៉ុណ្ណោះ
ចូរប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយកម្លាំងចិត្តដោយខ្លួនឯង ក្រោកឡើង
បង្អោនចិត្តទៅក្នុងពុទ្ធវចនៈ ការបង្រៀនរបស់ព្រះពុទ្ធ
ចូរកម្ចាត់នូវសេនានៃមច្ចុរាជ
ដូចដំរីកម្ទេចនូវផ្ទះបបុស (ដំបូលប្រក់ស្បូវ) យ៉ាងនោះដែរ″។

ព្រះសម្មាសម្ពុទ្ធ ជាលើកទីមួយក្នុងប្រវត្តិសាស្ត្រពិភពលោក បានបង្រៀនថា **វិមុត្តិ ការរួចរដោះ គួរស្វែងរកដោយខ្លួនឯង ទោះបីបុគ្គលនោះជាមនុស្ស ឬទេវតាក៏ដោយ។**

ទស្សនៈដែលគេលើកមនុស្សម្នាក់ពីទីទាបទៅខ្ពស់ ហើយទីបំផុតឱ្យបុគ្គលនោះជួយសង្គ្រោះខ្លួន ការនេះធ្វើឱ្យមនុស្សខ្ជិលច្រអូស និងទន់ខ្សោយ ទោរទន់ និងល្ងង់។ ជំនឿបែបនេះបន្ទាបបន្ថោកមនុស្ស គ្របដណ្តប់បិទបាំងនូវសេចក្តីថ្លៃថ្នូរដ៏ភ្លឺថែងចាំងក្នុងភាពជាមនុស្សដែលមានវិចារណញាណ។

ព្រះសម្មាសម្ពុទ្ធ បានទូន្មានដាស់តឿនសាវ័កទាំងឡាយរបស់ព្រះអង្គឱ្យយកខ្លួនឯងជាទីពឹង។ អ្នកដទៃអាចឱ្យជួយបានដោយប្រយោល ប៉ុន្តែការរួចរដោះចាកទុក្ខ ត្រូវតែធ្វើ និងវិចិត្ររៀងៗខ្លួន សំរាប់ខ្លួនឯងផ្ទាល់ អាស្រ័យពុម្ពនៃកម្មរបស់ខ្លួន។

# True Purification

In the understanding of things, neither belief nor fear plays any role in Buddhist thought. The truth of the Dhamma can be grasped only through insight, never through blind faith, or through fear of some known or unknown being.

Not only did the Buddha discourage blind **belief** and fear of an omnipotent God as unsuitable approaches for understanding the truth, but he also denounced adherence to unprofitable rites and rituals, because the mere abandoning of outward things, such as fasting, bathing in rivers, animal sacrifice, and similar acts, does not tend to purify a man or make a man holy and noble.

We find this dialogue between the Buddha and the Brahmin Sundarika Bhāradvāja: Once the Buddha, addressing the monks, explained in detail how a seeker of deliverance should train himself. and further added that a person whose mind is free from taints, whose life of purity is perfected, and the task done, could be called one who bathes inwardly.

Then Bhāradvāja, seated near the Buddha, heard these words and asked him:

“Does the Venerable Gotama go to bathe in the
river Bāhuka?”

“Brahmin, what good is the river Bāhuka? What can the river Bāhuka do?”

“Indeed, Venerable Gotama, the river Bāhuka is believed by many to be holy. Many people have their evil deeds (pāpa) washed away in the river Bahuka."

Then the Buddha made him understand that bathing in rivers would not cleanse a man of his dirt of evil, and instructed him thus:

"Bathe just here (in this Doctrine and Discipline, Dhamma-vinaya), brahmin, give security to all beings. If you do not speak falsehood, or kill or steal, if you are confident, and are not mean, what does it avail you to go to Gayā (the name of a river in India during the time of the Buddha)? Your well at home is also a Gayā.”

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| True Purification | វិសុទ្ធិ ឬសេចក្តីបរិសុទ្ធិពិតប្រាកដ |
| insight/wisdom | ញាណ ឬបញ្ញា |
| blind faith | ជំនឿដោយងងឹតងងល់ |
| discourage | មិនលើកទឹកចិត្ត |
| outward things | របស់ខាងក្រៅ |
| omnipotent God or almighty God | អាទិទេពដែលប្រកបដោយឫទ្ធិខ្លាំងក្លា |
| denounce adherence | ទ្រង់តិះដៀល ឬថ្កោលទោស ចំពោះសាវ័ក |
| unprofitable rites and rituals | ពិធីកម្មដែលមិនមានប្រយោជន៍ |
| fasting | ការតមមិនបរិភោគអាហារ (ពិធីពាហិរសាសនា) |
| bathing in rivers | ងូតទឹកទន្លេ (លាងបាប) |
| animal sacrifice | ការបូជាយញ្ញដោយសត្វពាហនៈ |
| to purify or to cleanse one's mind | សម្អាតចិត្តរបស់ខ្លួនឱ្យផូរផង់ |
| a seeker of deliverance | បុគ្គលដែលស្វែងរកនូវវិមោក្ខ |
| taint/defilement/canker | គ្រឿងសៅហ្មងគឺកិលេស |
| bathe inwardly | ងូតទឹកខាងក្នុង |
| Gayā River | ទន្លេឈ្មោះ គយា នៅប្រទេសឥណ្ឌាក្នុងសម័យពុទ្ធកាល |
| evil deeds (Pāpa) wash away | លាងបាបកម្ម |
| do not speak falsehood | មិននិយាយពាក្យមិនពិត |
| confident, and not mean | មានសទ្ធា និងមិនកំណាញ់ |

Doctrine and Discipline (Dhamma-Vinaya) ធម្មវិន័យ

# សេចក្តីបរិសុទ្ធពិតប្រាកដ

នៅក្នុងការយល់ធម៌ ជំនឿ និងសេចក្តីភ័យខ្លាច មិនមែនជារឿងសំខាន់នៅក្នុងទស្សនៈពុទ្ធសាសនាឡើយ។ សេចក្តីពិតនៃធម៌ អាចចាប់យកបានតាមរយៈនៃបញ្ញាតែប៉ុណ្ណោះ មិនមែនតាមការជឿទាំងងឹតងងល់ ឬដោយការភ័យខ្លាចអំពីបុគ្គលណាមួយ ឬព្រះអាថ៌កំបាំងណានោះទេ។

ព្រះពុទ្ធ មិនត្រឹមតែមិនលើកទឹកចិត្តជំនឿងងឹតងងល់ និងការភ័យខ្លាចចំពោះព្រះអាទិទេពដែលមានឬទ្ធិខ្លាំងក្លា ថាជាវិធីសាស្ត្រមិនត្រឹមត្រូវដើម្បីចាក់ធ្លុះនូវសច្ចធម៌ប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គក៏បានថ្កោលទោសចំពោះសាវ័កទាំងឡាយណាដែលធ្វើនូវពិធីកម្មដែលមិនមានប្រយោជន៍ផងដែរ ព្រោះដោយគ្រាន់តែលះបង់នូវវត្ថុខាងក្រៅ ដូចជា៖ ការតមមិនបរិភោគអាហារ ការងូតទឹកលាងបាបក្នុងទន្លេ ការបូជាយញ្ញដោយសត្វពាហនៈ និងសកម្មភាពស្រដៀងគ្នាដទៃទៀត មិនអាចធ្វើឲ្យមនុស្សបរិសុទ្ធ និងក្លាយជាអរិយបុគ្គលបានឡើយ។

យើងឃើញនូវការសន្ទនានេះរវាងព្រះសម្មាសម្ពុទ្ធ និងព្រាហ្មណ៍ឈ្មោះ សុន្ទរិកភារទ្វាជៈ។ សម័យមួយ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទៅកាន់ភិក្ខុទាំងឡាយ ដោយពន្យល់យ៉ាងពិស្តារនូវវិធីសាស្ត្រនៃបុគ្គលដែលស្វែងរកនូវវិមោក្ខត្រូវទូន្មានហ្វឹកហាត់ដោយរបៀបណា ហើយព្រះអង្គបានបន្ថែមថា បុគ្គលដែលមានចិត្តរួចស្រឡះហើយចាកកិលេសទាំងឡាយ មានព្រហ្មចរិយធម៌នៅរួចហើយ មានកិច្ចដែលត្រូវធ្វើបានធ្វើរួចហើយ បុគ្គលបែប នេះអាចហៅបានថា **ជាអ្នកបានងូតទឹកសម្អាតខាងក្នុង។**

ពេលនោះ ភារទ្វាជៈដែលអង្គុយជិតព្រះសម្មាសម្ពុទ្ធ បានស្តាប់នូវពាក្យនោះ ហើយទូលសួរព្រះអង្គថា៖

"តើព្រះសមណគោតម និមន្តទៅងូតទឹកលាងបាបក្នុងទន្លេពាហុកៈឬទេ?"

"ម្នាលព្រាហ្មណ៍ តើទន្លេពាហុកៈ មានអ្វីល្អ? តើទន្លេពាហុកៈអាចជួយអ្វីបាន?"

"ពិតណាស់ បពិត្រព្រះសមណគោតមដ៏ចម្រើន ទន្លេពាហុកៈត្រូវបានមនុស្សជាច្រើនជឿថា ជាទន្លេបរិសុទ្ធ។ មនុស្សជាច្រើនបានលាងជម្រះបាបកម្មរបស់ពួកគេ នៅក្នុងទន្លេពាហុកៈ។"

បន្ទាប់មក ព្រះសម្មាសម្ពុទ្ធបានធ្វើឲ្យព្រាហ្មណ៍យល់ថា ការងូតទឹកនៅក្នុងទន្លេមិនអាចលាងជម្រះមនុស្សឱ្យអស់គ្រឿងសៅហ្មងដែលជាបាបកម្មបានឡើយ ហើយទ្រង់ទូន្មានព្រាហ្មណ៍ដូចតទៅ៖

"ម្នាលព្រាហ្មណ៍ ចូរងូតទឹកនៅទីនេះ (ក្នុងធម្មវិន័យរបស់តថាគត) អាចផ្តល់នូវសេចក្តីសុខក្សេមដល់សព្វសត្វបាន។ បើអ្នកមិននិយាយកុហក់ ឬមិនសម្លាប់ ឬមិនលួច បើអ្នកមានសទ្ធា ហើយមិនកំណាញ់ តើមានប្រយោជន៍អ្វីដែលអ្នកត្រូវទៅកាន់ស្ទឹងគយា (ឈ្មោះស្ទឹងគយានៅប្រទេសឥណ្ឌាក្នុងសម័យពុទ្ធកាល) អណ្តូងនៅផ្ទះអ្នក ក៏ជាស្ទឹងគយាដែរ។"

## Caste Problem

Caste, which was a matter of vital importance to the brahmins of India, was one of utter indifference to the Buddha, who strongly condemned the debasing caste system. In his Order of Monks all castes unite as do the rivers in the sea. They lose their former names, castes, and clans, and become known as members of one community-the Sangha.

Speaking of the equal recognition of all members of the Sangha the Buddha says:

“Just as, O monks, the great rivers Gaṅgā, Yamunā, Aciravatī, Sarabhū, and Mahi, on reaching the ocean, lose their earlier name and identity and come to be reckoned as the great ocean, similarly, O monks, people of the four castes (vannas)..who leave the household and become homeless recluses under the Doctrine and Discipline declared by the Tathāgata, lose their previous names and identities and are reckoned as recluses who are sons of sākya” (Udāna 55).

The Buddhist position regarding racism and racial discrimination made explicit at such an early age is one reflected in the moral and scientific standpoint adopted by UNESCO in the present century (Declaration on Race and Racial Prejudice, UNESCO 1978).

To Sundarika Bhāradvāja, the brahmin who inquired about his lineage, the Buddha answered:

“No Brahmin I, no prince,
No farmer, or aught else.
All worldly ranks I know,
But knowing go my way
as simply nobody:
Homeless, in pilgrim garb,
With shaven crown, I go
my way alone, serene.
To ask my birth is vain”

On one occasion a caste-ridden brahmin insulted the Buddha saying, “Stop, thou shaveling! Stop, thou outcast!”

The Master, without any feeling of indignation, gently replied:

“Birth makes not a man an outcast,
Birth makes not a man a brahmin;
Action makes a man an outcast,
Action makes a man a brahmin.

(Sutta-nipāta, 142)

He then delivered a whole sermon, the Vasala Sutta, explaining to the brahmin in detail the characteristics of one who is really an outcast (vasala). Convinced, the haughty brahmin took refuge in the Buddha. (See The Book of Protection, p.91.)

The Buddha freely admitted into the Order people from all castes and classes when he knew that they were fit to live the holy life, and some of them later distinguished themselves in the Order. The Buddha was the only contemporary teacher who endeavoured to blend in mutual tolerance and concord those who hitherto had been rent asunder by differences of caste and class.

Upāli, who was the chief authority on the Vinaya-the disciplinary rules of the Order-was a barber, regarded as one of the basest occupations of the lower classes. Sunita, who later won arahatship, was a scavenger, another base occupation. In the Order of Nuns were Punna and Punnika, both slave girls. According to Mrs. C.A.F Rhys Davids, 8.5% of the number of those nuns who were able to realize the fruits of their training were drawn from the despised castes, which were mostly illiterate.

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

| | |
|---|---|
| Caste Problem | បញ្ហាវណ្ណៈ |
| Caste | វណ្ណៈ (ដែលជាប្រពៃណីតំណពូជសាសន៍) |
| Class | វណ្ណៈ (ដែលសង្គមកំណត់) |
| Cast system | ប្រព័ន្ធវណ្ណៈ |
| Clan | បក្សពួក ក្រុម ឬ ត្រកូល |
| Lineage | ពូជអំបូរ វង្សត្រកូល |
| Outcast | វណ្ណៈថោកទាប ឬវណ្ណៈដែលគេបន្សាត់ចោល |
| condemn | ស្តីបន្ទោស ថ្កោលទោស |
| equal recognition | ការទទួលស្គាល់ដោយស្មើភាពគ្នា |
| homeless recluse | សមណៈដែលចេញចាកផ្ទះ ឬលះបង់ផ្ទះ |
| pilgrim | អ្នកស្វែងរកធម៌ (ធម្មយាត្រា) |
| caste-ridden brahmin | ព្រាហ្មណ៍ដែលជិះជាន់នូវវណ្ណៈ |
| feeling of indignation | អារម្មណ៍តូចចិត្ត |
| take refuge in the Buddha | យកព្រះពុទ្ធជាទីពឹង |
| endeavour | ប្រឹងប្រែង ឬព្យាយាម |
| concord | សេចក្តីស្រុះស្រួលគ្នា |
| illiterate | ដែលមិនចេះអក្សរ |
| racism and racial discrimination | ពូជសាសន៍និយម និង ការរើសអើងពូជសាសន៍ |
| to blend in mutual tolerance | ដើម្បីលាយបញ្ចូលគ្នាក្នុងការចេះអត់ឱនទៅវិញទៅមក |

# បញ្ហាវណ្ណៈ

រឿងវណ្ណៈ ដែលជាបញ្ហាសំខាន់ចាំបាច់ចំពោះពួកព្រាហណ៍នៅប្រទេសឥណ្ឌា ប៉ុន្តែជារឿងដែលព្រះពុទ្ធមិនសូវយកព្រះទ័យទុកដាក់ទេ ផ្ទុយមកវិញព្រះអង្គបានតិះដៀល ចំពោះការបន្ទាបបន្ថោកគ្នានៃប្រព័ន្ធវណ្ណៈ។ នៅក្នុងសហគមន៍សង្ឃ គ្រប់វណ្ណៈទាំងអស់រួមគ្នាតែមួយ ដូចស្ទឹងទន្លេទាំងឡាយផ្សេងៗគ្នា ហូរចូលទៅក្នុងសមុទ្រតែមួយ។ ដូចគ្នានេះ ព្រះសង្ឃសាវ័កទាំងឡាយ បាត់បង់ឈ្មោះដើម វណ្ណៈដើម និង ពូជពង្សវង្សត្រកូលដើម ហើយត្រូវបានចាត់ចូលជាសមាជិកនៃសហគមន៍តែមួយ ហៅថា **សង្ឃ**។

និយាយអំពីការទទួលស្គាល់ដោយស្មើភាពគ្នានៃសមាជិកសង្ឃវិញ ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីកាថា៖

"ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាទន្លេធំៗទាំងឡាយមាន៖ ទន្លេគង្គា យមុនា អចិរវតី សរភូ និង មហិ នៅពេលធ្លាក់ចុះទៅដល់សមុទ្រ បានបាត់នូវឈ្មោះ និងអត្តសញ្ញាណដើមរបស់ខ្លួន ហើយត្រូវបានចាត់ទុកជាមហាសមុទ្រ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះយ៉ាងណា មនុស្សចេញពីវណ្ណៈទាំងបួន ដែលបានចេញចាកផ្ទះ ហើយបួសជាសមណៈនៅក្រោមធម្មវិន័យដែលប្រកាសដោយព្រះតថាគត បានបាត់នូវឈ្មោះ និងអត្តសញ្ញាណដើមរបស់ពួកគេ ហើយត្រូវបានចាត់ទុកជា សាក្យបុត្ត" (ឧទាន ៥៥)។

គោលជំហរពុទ្ធសាសនាទាក់ទងនឹងពូជសាសន៍និយម និងការរើសអើងពូជសាសន៍ បានធ្វើឱ្យជាក់ច្បាស់តាំងពីសម័យកាលនោះមកម្ល៉េះ ដែលគេអាចពិចារណានៅក្នុងបទដ្ឋានវិទ្យាសាស្ត្រ និងសីលធម៌ បានអនុម័តដោយអង្គការយូនេស្កូ នាសតវត្សរ៍បច្ចុប្បន្ននេះ (សេចក្តីប្រកាសទាក់ទងពូជសាសន៍ និងការរើសអើងពូជសាសន៍ UNESCO 1978)។

ចំពោះសុន្ទរិកភារទ្វាជៈព្រាហ្មណ៍ ដែលបានសួរអំពីវង្សត្រកូល ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីកាថា៖

"ទេ ព្រាហ្មណ៍ តថាគត មិនមែនជារាជបុត្រទេ

មិនមែនជាកសិករ ឬ នរណាដទៃឡើយ។

តថាគតស្គាល់ច្បាស់នូវឋានៈទាំងឡាយក្នុងលោកទាំងអស់
ប៉ុន្តែ តថាគត ដឹងផ្លូវរបស់តថាគត
យ៉ាងសាមញ្ញ មិនមែនជាបុគ្គលណាឡើយៈ
តថាគតជាអ្នកចេញចាកផ្ទះ អាស្រ័យនឹងស្បង់ចីវរ
មានសក់កោរហើយ តថាគតត្រាច់ទៅ
តាមផ្លូវតែឯង ដោយសេចក្តីស្ងប់ស្ងាត់
សួររឿងជាតិកំណើតរបស់តថាគត គឺជាការឥតប្រយោជន៍។

ក្នុងសម័យមួយ ព្រាហ្មណ៍ម្នាក់ដែលជិះជាន់វណ្ណៈ បានជេរប្រមាថព្រះសម្មាសម្ពុទ្ធដោយពាក្យថាៈ "ឈប់ សមណៈត្រងោល! ឈប់ អ្នកវណ្ណៈថោកទាប!"

ព្រះបរមសាស្តា ដោយមិនមានព្រះទ័យអាក់អន់ខឹងសម្បារ បានឆ្លើយតបវិញដោយទន់ភ្លន់ថាៈ

"ជាតិកំណើតមិនបានធ្វើឲ្យមនុស្សថោកទាប
ជាតិកំណើតមិនបានធ្វើឲ្យមនុស្សជាព្រាហ្មណ៍
ទង្វើ ទើបធ្វើមនុស្សឲ្យថោកទាប
ទង្វើ ទើបធ្វើមនុស្សឲ្យជាព្រាហ្មណ៍។" (សុត្តនិបាត ១៤២)

ព្រះអង្គទ្រង់ប្រទានធម្មទេសនាទាំងស្រុងអំពី **វសលសូត្រ** ពន្យល់ទៅព្រាហ្មណ៍យ៉ាងពិស្តារអំពីលក្ខណៈនៃបុគ្គលថោកទាបពិតប្រាកដ។ ធ្វើឱ្យមានសទ្ធាជឿជាក់ហើយព្រាហ្មណ៍ដែលព្រហើនកោងកាច បានដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក។ (អានសៀវភៅ *The Book of Protection* P91)។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានអនុញ្ញាតឱ្យចូលបួស ដោយផ្តល់សេរីភាពដល់មនុស្សគ្រប់វណ្ណៈ គ្រប់ថ្នាក់ទាំងអស់ ពេលព្រះអង្គជ្រាបថាពួកគេមានឧបនិស្ស័យក្នុងការប្រព្រឹត្តនូវព្រហ្មចរិយធម៌ ហើយសាវ័កមួយចំនួន ក្រោយមក បានធ្វើខ្លួនលោកឲ្យប្រសើរខ្ពង់ខ្ពស់នៅក្នុងព្រះផ្នួសនេះ។ ព្រះសម្មាសម្ពុទ្ធ ជាគ្រូតែមួយគត់ នៅក្នុងបច្ចុប្បន្នសម័យនេះ ដែលបានព្យាយាមច្របាច់បញ្ចូលគ្នានូវពពួកជនឱ្យមានសេចក្តីអត់ឱន និងភាពស្រុះ

ស្រួលចំពោះគ្នាទៅវិញទៅមក រហូតដល់ឥឡូវនេះ បានផ្សះផ្សារជនទាំងឡាយនោះដែលពីមុនបានបែកបាក់គ្នា ដោយសារភាពផ្សេងគ្នាដោយវណ្ណៈ និងឋានៈនៃសង្គម។

**ព្រះឧបាលី** ដែលជា **ឯតទគ្គៈផ្នែកព្រះវិន័យ** គឺអនាគារិយវិន័យ ឬវិន័យរបស់អ្នកបួស ពីមុនធ្លាប់ជាខ្មាន់ព្រះកេស ដែលត្រូវបានគេចាត់ទុកថាជាមុខរបរទាបបំផុតនៃវណ្ណៈជាន់ទាប។ សុនិតៈភិក្ខុ ដែលក្រោយមកបានសំរេចអរហត្តផល ពីមុនធ្លាប់ជាអ្នករើសសំរាមអេតចាយ ដែលនេះគឺជាការងារចិញ្ចឹមជីវិតដ៏ទាបមួយទៀត។ នៅក្នុងចំណោមភិក្ខុនីសង្ឃ មានព្រះនាងបុណ្ណា និង ព្រះនាងបុណ្ណិកា ទាំង២រូប ធ្លាប់ជាទាសីស្រីបម្រើ។ យោងតាម Mrs. C.A.F. Rhys Davids, ៨.៥ ភាគរយ នៃចំនួនភិក្ខុនីសង្ឃដែលអាចសម្រេចនូវផលនៃការបដិបត្តិ សុទ្ធតែចេញពីវណ្ណៈជាន់ទាប ភាគច្រើនមិនចេះអក្សរ។

# Chief Disciples

Rājagaha, the capital of the kingdom of Magadha, was one of the first places visited by the Buddha soon after his enlightenment. As a wandering ascetic in the early days of his renunciation, he had promised King Seniya Bimbisāra that he would visit Rājagaha when he achieved the object of his search. King Bimbisāra was overjoyed at the sight of the Buddha, and having listened to his teaching, became a lay follower. His devotion to the Buddha became so ardent that within a few days he offered him his pleasure park, Veḷuvana, for residence.

Rājagaha during that time was a centre of great learning where many schools of philosophy flourished. One such school of thought had as its head Sañjaya; and among his retinue of two hundred and fifty followers were Upatissa and Kolita, who were later to become Sarīputta and Mahā Moggallāna, the two chief disciples of the Buddha.

One day when Upatissa was walking through the streets of Rājagaha, he was greatly struck by the serene countenance and the quiet, dignified deportment of one of the first disciples of the Buddha, the arahat Assaji, who was on his alms round.

All the strenuous endeavours to achieve perfection that Upatissa had made through many a birth were now on the verge of being rewarded. Without going back to his teacher, he followed the arahat Assaji to his resting place, eager to know whom he followed and what teaching he had accepted.

“Friend,” said Upatissa, “serene is your countenance, clear and radiant is your glance. Who persuaded you to renounce the world? Who is your teacher? What Dhamma (teaching) do you follow?” The Venerable Assaji, rather reluctant to speak much, humbly said: “I cannot expound the Doctrine and Discipline at length, but I can tell you the meaning briefly.”

Upatissa's reply is interesting: “Well, friend, tell little or much; what I want is just the meaning. Why speak many words?” Then the arahat Assaji uttered a single verse which embraces the Buddha's entire doctrine of causality:

“Ye dhammā hetuppabhavā
Tesaṃ hetuṃ tathāgato āha
Tesaṃ ca yo nirodho
Evaṃ vādī mahā samaṇo.”

“Whatever from a cause proceeds, thereof
The Tathāgata has explained the cause,
Its cessation too he has explained.
This is the teaching of the Supreme Sage.”

(Vinaya Mahāvagga)

Upatissa instantly grasped the meaning and attained the first stage of realization, comprehending “whatever is of the nature of arising, all that is of the nature of ceasing” (yaṃ kiñci samudayadhammaṃ sabbantaṃ nirodhadhammaṃ).

With a heart full of joy, he quickly went back to his friend Kolita and told him of his meeting with the arhat and of the teaching he had received Kolita, too, like Upatissa, instantly gained the first stage of realization, having heard the Dhamma from his friend. Thereon both of them approached Sañjaya and asked him to follow the Buddha. But afraid of losing his reputation as a religious teacher, he refused to do so. Upatissa and Kolita then left Sañjaya-much against his protestations-for the Veḷuvana monastery and expressed their wish to become followers of the Buddha. The Buddha gladly welcomed them saying, “Come, monks, well proclaimed is the Dhamma. Live the holy life for the complete ending of suffering. “He admitted them into the Order. They attained deliverance and became the two chief disciples.

Another great one who joined the Order during the Buddha's stay at Veḷuvana was the brahmin sage Mahā Kassapa, who had renounced great wealth to find the way to deliverance. It was the Venerable Mahā Kassapa, three months after the Buddha's passing away (parinibbāna), who called up the convocation of

arhats (the First Council), at the Sattapanni Cave near Rājagaha under the patronage of King Ajātasattu, to collect and codify the Dhamma and Vinaya.

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| Chief Disciple | អគ្គសាវ័ក |
| renunciation | នេក្ខម្ម (ការចេញបួស) |
| lay follower | ឧបាសក, ឧបាសិកា |
| devotion to the Buddha | សទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធ |
| retinue | បរិវារ |
| serene countenance | ទឹកមុខស្ងប់ស្ងៀម |
| deportment | លក្ខណៈឫកពារ ឬឥរិយាបថ |
| strenuous endeavour | សេចក្តីព្យាយាមដោយស្វាហាប់ |
| clear and radiant | ថ្លា និង ស្រស់ប្រិមប្រិយ |
| doctrine of causality | ទ្រឹស្តីហេតុ និងផល (ហេតុធម៌) |
| Supreme Sage (Mahā Samaṇa) | មហាសមណៈ |
| reputation | កេរ្តិ៍ឈ្មោះ ឬ កិត្តិសព្ទ |
| alms round | បិណ្ឌបាត |
| convocation of Arahants | ការកោះប្រជុំនៃអរហន្ត ឬអរហន្តសន្និបាត |
| The First Council | បឋមសង្គាយនា (ការប្រជុំសង្ឃផ្ទៀងផ្ទាត់ធម៌វិន័យ) |
| under the patronage of King Ajātasattu | ក្រោមរាជូបត្ថម្ភនៃព្រះបាទអជាតសត្តុ |
| to collect and codify the Dhamma & Vinaya | ដើម្បីប្រមូល និងចងក្រងនូវធម្មវិន័យ |
| Buddha's passing away (Parinibbāna) | ការបរិនិព្វានរបស់ព្រះពុទ្ធ |
| well-proclaimed is the Dhamma | ស្វាក្ខាតោ ភគវតា ធម្មោ<br>ធម៌ដែលព្រះពុទ្ធទ្រង់សម្តែងហើយដោយល្អ |

# អគ្គសាវ័ក

រាជគ្រឹះ គឺជារាជធានីនៃនគរមគធៈ ជាកន្លែងមួយក្នុងចំណោមកន្លែងដំបូង ដែលព្រះសម្មាសម្ពុទ្ធបានយាងទៅ បន្ទាប់ពីព្រះអង្គបានត្រាស់ដឹងភ្លាម។ ជាតាបសពនេចរក្នុងគ្រាដំបូងនៃការចេញសាងផ្នួសរបស់ព្រះអង្គ ទ្រង់បានសន្យាជាមួយ **ព្រះបាទសេនិយៈ ពិម្ពិសារ** ថានឹងយាងមកក្រុងរាជគ្រឹះ ពេលព្រះអង្គបានសម្រេចនូវដំណើរស្វែងរកសច្ចធម៌។ ព្រះបាទពិម្ពិសារ មានសេចក្តីរីករាយយ៉ាងក្រៃលែងពេលបានជួបព្រះសម្មាសម្ពុទ្ធ ហើយបានស្តាប់នូវព្រះធម៌ ក៏បានក្លាយជាឧបាសកមួយរូបក្នុងពុទ្ធសាសនា។ សទ្ធារបស់ព្រះរាជាចំពោះព្រះសម្មាសម្ពុទ្ធ មានកម្លាំងខ្លាំងក្លាដែលក្នុងរយៈពេលតែពីរបីថ្ងៃ ព្រះរាជាបានថ្វាយនូវ **ឧទ្យានវេឡុវ័ន** ជាអារាមគង់នៅរបស់ព្រះសម្មាសម្ពុទ្ធ។

ក្រុងរាជគ្រឹះក្នុងសម័យនោះ ជាមជ្ឈមណ្ឌលនៃការសិក្សាដ៏អស្ចារ្យមួយ ដែលមានសាលាទស្សនវិជ្ជាជាច្រើនបានរីកដុះដាល។ សាលាមួយ ក្នុងចំណោមសាលាទស្សនវិជ្ជាទាំងនោះ មានអាចារ្យជាអ្នកដឹកនាំ ឈ្មោះថា **សញ្ជ័យ** ហើយក្នុងចំណោមសិស្សជាបរិវាររបស់គាត់ទាំង២៥០នាក់ មាន៖ **ឧបតិស្សៈ** និង **កោលិតៈ** ដែលក្រោយមកបានក្លាយជា **ព្រះសារីបុត្ត** និង **ព្រះមោគ្គល្លាន** ជាអគ្គសាវ័កទាំងពីររបស់ព្រះសម្មាសម្ពុទ្ធ។

សម័យថ្ងៃមួយ ពេលដែលឧបតិស្សៈកំពុងដើរតាមដងផ្លូវនៅទីក្រុងរាជគ្រឹះ គាត់បានមានការទាក់ទាញអារម្មណ៍យ៉ាងខ្លាំងមួយ ដោយឃើញទឹកព្រះភ័ក្ត្រស្ងប់ស្ងៀមនិងសង្រួម ប្រកបដោយឥរិយាបថថ្លៃថ្នូរ នៃសាវ័ក១អង្គក្នុងចំណោមសាវ័កដំបូងរបស់ព្រះសម្មាសម្ពុទ្ធ គឺព្រះអរហន្ត **អស្សជិ** ដែលលោកកំពុងនិមន្តបិណ្ឌបាត្រ។

សេចក្តីព្យាយាមដ៏ស្វាហាប់គ្រប់យ៉ាង ដើម្បីសម្រេចនូវបារមីដែលឧបតិស្សៈបានសន្សំហើយអស់ជាតិជាច្រើន ឥឡូវនេះកៀកនឹងទទួលផលហើយ។ ដោយមិនត្រឡប់ទៅគ្រូដើមវិញ ឧបតិស្សៈបានដើរតាមព្រះអស្សជិ ទៅកាន់កន្លែងលោកសម្រាក អន្ទះសារចង់ដឹងថា តើលោកបដិបត្តិតាមគ្រូអាចារ្យណា ហើយការបង្រៀននោះដូចម្តេច ដែលលោកទទួលយក?

ឧបតិស្សៈ បានពោលថា "ម្នាលលោកដ៏មានអាយុ" "អ្នកមានទឹកមុខស្ងប់ស្ងាត់ មានចក្ខុភ្លឺថ្លាថៃងចាំអ្វីម៉្លេះ!។ តើនរណាជាអ្នកបញ្ចុះបញ្ចូលអ្នកឲ្យចេញសាងផ្នួស? តើនរណាជាសាស្តាចារ្យរបស់អ្នក? តើធម៌ (ការបង្រៀន) ដូចម្តេចដែលអ្នកបដិបត្តិ?" ព្រះអស្សជិ ស្ទាក់ស្ទើរមិនចង់និយាយច្រើន បានពោលតបដោយសុភាពរាបសារថា៖ **"អាត្មាមិនអាចសម្តែងនូវធម៌ និងវិន័យដោយពិស្តារបានទេ តែអាត្មាអាចប្រាប់នូវខ្លឹមសារសង្ខេបបាន"។** ចម្លើយរបស់ឧបតិស្សៈត្រង់នេះគួរឱ្យចាប់អារម្មណ៍ណាស់៖ **"ប្រពៃណាស់ លោកដ៏មានអាយុ ប្រាប់តិច ឬ ច្រើនមិនថ្វី អ្វីដែលខ្ញុំចង់បានគឺ ខ្លឹមសារ ចាំបាច់អ្វីត្រូវនិយាយច្រើនពាក្យ?"** បន្ទាប់មក **ព្រះអស្សជិ** បានពោលតែមួយគាថាគត់ ដែលក្តោប អត្ថន័យរួមនៃពុទ្ធវចនៈអំពីទ្រឹស្តីហេតុផល (ហេតុប្បច្ចយធម៌ ឬបដិច្ចសមុប្បាទធម៌)៖

**"យេ ធម្មា ហេតុប្បភវា**

**តេសំ ហេតុំ តថាគតោ (អាហ)**

**តេសំ ច យោ និរោធោ**

**ឯវំ វាទី មហាសមណោ"២ (វិនយមហាវគ្គ)**

**"ធម៌ទាំងឡាយណាតែងកើតអំពីហេតុ**
**ព្រះតថាគតសម្តែងប្រាប់នូវហេតុទាំងឡាយនោះ**
**ព្រមទាំងសេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះផង**
**នេះគឺជាការបង្រៀននៃមហាសមណៈ"។**

ឧបតិស្សៈ ចាប់ខ្លឹមសារបានភ្លាមៗ ហើយបានសម្រេចនូវ សោតាបត្តិមគ្គ ដោយពិចារណាថា **"អ្វីណាដែលមានកិរិយាកើតឡើង ទាំងអស់នោះមានកិរិយារលត់ទៅវិញជាធម្មតា"** (**យំ កិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មំ**)។

ជាមួយចិត្តពោរពេញដោយបីតិ ឧបតិស្សៈបានប្រញាប់វិលត្រឡប់ទៅរកសម្លាញ់របស់ខ្លួនគឺ កោលិតៈ ហើយបានប្រាប់ពីការបានជួបជាមួយព្រះអរហន្ត និងការបង្រៀន

ដែលខ្លួនបានទទួល។ កោលិតៈ ក៏ដូចគ្នានឹងឧបតិស្សៈដែរ បានសម្រេចនូវសោតាបត្តិមគ្គរំពេចនោះ ក្រោយពីបានស្តាប់ធម៌អំពីមិត្តរបស់ខ្លួន។

បន្ទាប់មក អ្នកទាំងពីរបានចូលទៅកាន់សំណាក់អាចារ្យសញ្ជ័យ ហើយបានសុំអាចារ្យដើម្បីចូលទៅបួសបដិបត្តិតាមព្រះសម្មាសម្ពុទ្ធ។ ប៉ុន្តែដោយការភ័យខ្លាចបាត់បង់កិត្តិសព្ទក្នុងនាមជាសាសនាចារ្យមួយរូប អាចារ្យសញ្ជ័យក៏បានបដិសេធនូវសំណើរនោះ។ ឧបតិស្សៈ និងកោលិតៈ បន្ទាប់មក បានចាកចេញពីអាចារ្យសញ្ជយ ដោយប្រឆាំងនឹងពាក្យតវ៉ារបស់គ្រូ ឆ្ពោះទៅកាន់វត្តវេឡុវន ហើយបានសម្តែងនូវសេចក្តីប្រាថ្នាដើម្បីក្លាយជាសាវ័កនៃព្រះពុទ្ធ។ ព្រះសម្មាសម្ពុទ្ធបានស្វាគមន៍ដោយសេចក្តីជ្រះថ្លា ហើយមានពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ ចូរមក ព្រះធម៌គឺតថាគតបានសម្តែងហើយដោយល្អ។ ចូររស់នៅក្នុងព្រហ្មចរិយធម៌ដើម្បីធ្វើនូវទីបំផុតនៃសេចក្តីទុក្ខចុះ"។ ព្រះអង្គទ្រង់បានអនុញ្ញាតឱ្យពួកគេឲ្យចូលសាងផ្នួស។ ទាំងពីរព្រះអង្គក៏បានរួចរដោះ ហើយបានក្លាយជាអគ្គសាវ័កទាំងពីររបស់ព្រះពុទ្ធ។

បុគ្គលដ៏អស្ចារ្យមួយរូបទៀត ដែលបានចូលបួស ក្នុងកំឡុងពេលព្រះសម្មាសម្ពុទ្ធគង់នៅវត្តវេឡុវន គឺជាព្រាហ្មណ៍ម្នាក់ឈ្មោះ មហាកស្សប ដែលបានលះបង់ទ្រព្យសម្បត្តិដ៏មហាសាលដើម្បីចេញស្វែងរកមាគ៌ាការរួចរដោះចាកទុក្ខ។ គឺព្រះមហាកស្សបនេះឯងដែល ៣ខែ ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធ បានធ្វើការកោះប្រជុំព្រះអរហន្តទាំងឡាយ (អរហន្តសន្និបាត បឋមសង្គាយនា) នៅគុហាសត្តបណ្ណិ ជិតក្រុងរាជគ្រឹះ ក្រោមព្រះរាជូបត្ថម្ភនៃព្រះបាទអជាតសត្តុ ដើម្បីប្រមូល និងចងក្រងនូវធម៌វិន័យ។

## The Order of Nuns

In the early days of the Order, only men were admitted to the Sangha since the Buddha was reluctant to admit women. But there were many devout women among the lay followers who had a keen desire for a life of renunciation as nuns. Urged by their keenness, Pajāpati Gotamī, the foster-mother of the Buddha, in the company of many ladies of rank, approached the Buddha, beseeching him to grant them ordination. But the Buddha still hesitated to accept them.

Seeing their discomfiture, and urged by their zeal, the Venerable Ānanda took up their cause and pleaded with the Buddha on their behalf. The Buddha finally yielded to this appeal, placing, however, eight cardinal rules on the ordination of women. Thus was established, in the fifth year after his enlightenment, the Order of Nuns, the Bhikkhunī Sāsana, for the first time in history; for never before this had there been an Order where woman could lead a celibate life of renunciation.

Women from all walks of life joined the Order. Foremost in the Order stood the Therīs Khemā and Uppalavaṇṇā. The lives of quite a number of these noble nuns, their strenuous endeavours to win the goal of freedom, and their peons of joy at deliverance of mind, are graphically described in the Therīgāthā, the Psalms of the Sisters.

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

**The Order of Nuns** **ភិក្ខុនីសង្ឃ**

devout women ស្រ្តីដែលប្រកបដោយភក្តីភាព ឬសទ្ធាជ្រះថ្លា

keen desire សេចក្តីប្រាថ្នាមុតមាំ

a celibate life ជីវិតព្រហ្មចរិយធម៌

be alert, be mindful ចូររវាំងប្រយ័ត្ន, ចូរមានស្មារតី

a righteous life ជីវិតប្រកបដោយធម៌

to salute វន្ទា, ក្រាបសំពះ

pride of self (Asmi-māna) អស្មិមានៈ (សេចក្តីប្រកាន់ថាអញមាន)

cultivate the meditation ចម្រើនកម្មដ្ឋាន ឬសមាធិ

highest sanctity (Arahatship) អរហត្តផល

loving-kindness (Mettā) មេត្តា; compassion (Karuṇā) ករុណា

appreciative joy (Muditā) មុទិតា; equanimity (Upekkhā) ឧបេក្ខា

meditation on impurity (Asubha-kammaṭṭhāna) អសុភកម្មដ្ឋាន

the concept of impermanence (Anicca-saññā) អនិច្ចសញ្ញា

ill-will (Vyāpāda) ព្យាបាទ; aversion, hatred ទោសៈ

Therīgāthā, the Psalms of the Sisters ថេរីគាថា

exhortations to Rāhula (Rāhulovāda) ឱវាទចំពោះរាហុល (រាហុលោវាទ)

mindfulness of in-and-out-breathing (Ānāpāṇassati) អានាបាណស្សតិ

eight cardinal rules (ordination of women) អដ្ឋគរុធម៌ (របស់ភិក្ខុនីសង្ឃ)

# ភិក្ខុនីសង្ឃ

ក្នុងសម័យដំបូងនៃអ្នកបួសក្នុងពុទ្ធសាសនា(គណៈសង្ឃ) មានតែបុរសប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យសាងផ្នួសជាសង្ឃ ដោយសារព្រះសម្មាសម្ពុទ្ធមានការស្ទាក់ស្ទើរដើម្បីឲ្យស្ត្រីចូលបួស។ ប៉ុន្តែមានស្ត្រីជាច្រើនដែលប្រកបដោយសទ្ធាជ្រះថ្លាក្នុងចំណោមឧបាសិកាទាំងឡាយដែលមានសេចក្តីប្រាថ្នាមុះមុត ដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ បួសជាភិក្ខុនី។ សេចក្តីប្រាថ្នារបស់ពួកគេ បានជំរុញឱ្យ **ព្រះនាងបជាបតិគោតមី** ជាព្រះមាតាចិញ្ចឹមរបស់ព្រះសម្មាសម្ពុទ្ធ ហែហមដោយស្ត្រីជាច្រើនដែលមានឋានៈខ្ពង់ខ្ពស់ បានចូលគាល់ព្រះសម្មាសម្ពុទ្ធ ស្នើសុំព្រះអង្គអនុញ្ញាតឱ្យពួកគេបានចូលសាងផ្នួស។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធ នៅតែស្ទាក់ស្ទើរក្នុងការទទួលពួកគេ។

ដោយឃើញសេចក្តីខកបំណងរបស់ពួកស្ត្រី និងដោយការជម្រុញទឹកចិត្តពីវិរិយភាពរបស់ពួកគេផង **ព្រះអានន្ទ** បានជួយជ្រោមជ្រែងក្នុងករណីនេះ ហើយបានជួយទូលសុំព្រះសម្មាសម្ពុទ្ធជំនួសពួកគេ។ ទីបំផុត ព្រះសម្មាសម្ពុទ្ធក៏ទ្រង់អនុញ្ញាតតាមការស្នើសុំនេះ ប៉ុន្តែបានដាក់កំណត់នូវ **អដ្ឋគរុធម៌** សំរាប់ភិក្ខុនីសង្ឃ។ **ភិក្ខុនីឧបសម្បទា ឬ ភិក្ខុនីសាសនា** ត្រូវបានស្ថាបនាឡើង ពោលគឺ ៥ ឆ្នាំក្រោយការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ជាលើកទី១នៅក្នុងប្រវត្តិសាស្ត្រ ដែលពីមុនមិនធ្លាប់មានការអនុញ្ញាតឱ្យស្ត្រីចូលសាងផ្នួសប្រព្រឹត្តនូវព្រហ្មចរិយធម៌ឡើយ។

ស្ត្រីទាំងឡាយពីគ្រប់វណ្ណៈ គ្រប់មជ្ឈដ្ឋាននៃជីវិតបានចូលបួស។ ដែលសំខាន់ជាងគេ និង ជាកំពូលក្នុងភិក្ខុនីសង្ឃគឺ **ព្រះមហាថេរី ខេមា** (ព្រះនាងខេមា) និង **ឧប្បលវណ្ណា**។ ដំណើរជីវិតនៃស្ត្រីដ៏ខ្ពង់ខ្ពស់មួយចំនួននេះ សេចក្តីព្យាយាមយ៉ាងខ្លាំងក្លារបស់ពួកគេដើម្បីសម្រេចគោលដៅពោលគឺសេរីភាព(ការរួចចាកទុក្ខ) និង ភាពរីករាយនៃការរួចរដោះផ្លូវចិត្ត( វិមុត្ត) មានរៀបរាប់យ៉ាងពិស្តារច្បាស់លាស់នៅក្នុង **ថេរីគាថា** ។ (Therī-gāthā, the Psalms of the Sisters)

## At Kapilavatthu

While at Rājagaha, the Blessed One heard that his father wished to see him, and he set out for Kapilavatthu. He did not, however, go straight to the palace, but, according to custom, stopped in a grove outside the town. The next day the Buddha, with his bowl, went for his alms from house to house in the streets of Kapilavatthu. King Suddhodana, startled at the news, rushed to the Buddha and said; “Why, Master, why do you put us to shame? Why do you go begging for your food? Not one of our race has ever done so.” Replied the Buddha: “You and your family may claim descent from kings; my descent is from the Buddhas of old; and they, begging their food, always lived on alms.” Then explaining the Dhamma the Master said, “Be alert, be mindful, lead a righteous life. The righteous live happily both in this world and the next.” And so the king became established in the Path, he realized the Dhamma.

The Buddha was then conducted into the palace where all came to pay their respects to him, but not Princess Yasodharā. The Buddha went to her, and the princess, knowing the impassable gulf between them, fell on the ground at his feet and saluted him. Then relating the Candakinnarā Jātaka, a story of his previous birth revealing how great her virtue had been in that former life, he made her an adherent to the Doctrine. Later when the Buddha was induced to establish an Order for women, Yasodharā became one of the first nuns and attained arahatship, highest sanctity.

When the Buddha was in the palace, Princess Yasodharā arrayed her son Rāhula in all his best attire and sent him to the Blessed One, saying,
“That is your father, Rāhula, go and ask for your inheritance.”

Prince Rāhula went to the Buddha, stood before him, and said, “Pleasant indeed is your shadow, sage.”

And when the Blessed One had finished his meal and left the palace, Prince Rāhula followed him saying, “Give me my inheritance, sage; give me my

inheritance.” At that the Blessed One spoke to the Venerable Sārīputta: “Well then, Sārīputta, take him into the Order.”

Then the Venerable Sārīputta gave Prince Rāhula the ordination. In the Majjhima Nikāya, one of the five original collections in Pāli containing the Buddha's discourses, there are three discourses (Nos.61, 62, 147) entitled Rāhulovāda or exhortations to Rāhula, delivered by the Blessed One to teach the Dhamma to little Rāhula. The discourses are entirely devoted to advice on discipline and meditation. Here is an extract from the Master's exhortation in the Mahā Rāhulovāda Sutta:

“Cultivate the meditation on loving-kindness (mettā), Rāhula; for by cultivating loving-kindness, ill will is banished. Cultivate the meditation on compassion (karuṇā), Rāhula, for by cultivating compassion, cruelty is banished. Cultivate the meditation on appreciative joy (muditā), Rāhula, for by cultivating appreciative joy, aversion is banished. Cultivate the meditation on equanimity (upekkhā), Rāhula, for by cultivating equanimity, hatred is banished. Cultivate the meditation on impurity (asubha), Rāhula, for by meditating on impurity, lust is banished. Cultivate the meditation on the concept of impermanence (anicca-saññā), Rāhula, for by meditating on the concept of impermanence, pride of self (asmi-māna) is banished. Cultivate the meditation on mindfulness of in-and-out-breathing (aṇāpānasati), Rāhula, for mindfulness of breathing, cultivated and frequently practised, bears much fruit and is of great advantage.”

# Dhamma Terminology ពាក្យសព្ទព្រះធម៌

| | |
|---|---|
| **At Kapilavatthu** | **នៅនគរកបិលវត្ថុ** |
| went for his alms / lived on alms | យាងទៅបិណ្ឌបាត/រស់អាស្រ័យបិណ្ឌបាត |
| go begging for your food | ដើរសុំទានគេ |
| The righteous | មនុស្សដែលប្រកបដោយធម៌ (មនុស្សត្រឹមត្រូវ) |
| became established in the Path | បានតាំងនៅលើមគ្គផល |
| fell on the ground at his feet and saluted him | ក្រាបវន្ទាព្រះអង្គ |
| made her an adherent to the Doctrine | បានញ៉ាំងនាងឱ្យបានលុះក្នុងធម៌ ឬជាសាវ័កនៃព្រះសាសនា |
| Be alert, be mindful, lead a righteous life | ចូរប្រុងប្រយ័ត្ន មានស្មារតី ចូររស់នៅតាមគន្លងធម៌ |
| Order for women | ការចូលបួសរបស់ស្ត្រី |
| highest sanctity | សេចក្តីបរិសុទ្ធដ៏ខ្ពង់ខ្ពស់បំផុត (អរហត្តផល) |
| sage | អ្នកប្រាជ្ញ មុនីឥសី (អ្នកបួស ឬ តាបស) |
| take him into the Order | អនុញ្ញាតិឱ្យគាត់ចូលបួស ordination ការសាងផ្នួស |
| exhortations to Rāhula | ឱវាទចំពោះព្រះរាហុល |
| loving-kindness (mettā) | មេត្តា |
| ill will (vyāpāda) | ព្យាបាទៈ |
| compassion (karuṇā) | ករុណា |
| meditation on appreciative joy (muditā) | មុទិតាកម្មដ្ឋាន ឬភាវនាដែលយកមុទិតាជាអារម្មណ៍ |
| the meditation on equanimity (upekkhā) | ឧបេក្ខាកម្មដ្ឋាន |
| meditation on impurity (asubha) | អសុភកម្មដ្ឋាន |
| meditation on the concept of impermanence (anicca-saññā) | អនិច្ចសញ្ញាកម្មដ្ឋាន |
| pride of self (asmi-māna) | អស្មិមានៈ |
| meditation on mindfulness of in-and-out-breathing (aṇāpānasati) | អនាបាណស្សតិកម្មដ្ឋាន |

# នៅនគរកបិលវត្ថុ

ពេលគង់នៅក្រុងរាជគ្រឹះ ព្រះដ៏មានព្រះភាគបានឮដំណឹងថាព្រះពុទ្ធបិតា មានបំណងចង់ជួបព្រះអង្គ ទើបយាងចេញទៅកាន់នគរកបិលវត្ថុ។ ទោះបីយ៉ាងណា ព្រះអង្គមិនបានយាងត្រង់ទៅព្រះរាជវាំងភ្លាមទេ តាមពុទ្ធទំនៀម ព្រះអង្គតែងឈប់សម្រាកក្នុងឧទ្យានក្រៅក្រុង។ ថ្ងៃបន្ទាប់ ព្រះសម្មាសមាសម្ពុទ្ធ ប្រដាប់ដោយបាត្រ និមន្តគោចរពីផ្ទះមួយទៅផ្ទះមួយ តាមដងវិថីនៃក្រុងកបិលព័ស្តុ។ ព្រះបាទសុទ្ធោទនៈ បានភ្ញាក់ផ្អើលចំពោះដំណឹងនោះ ក៏ប្រញាប់ប្រញាល់ទៅជួបព្រះពុទ្ធ ហើយមានបន្ទូលថា "**បពិត្រព្រះសាស្តា ហេតុអ្វីបានជាអ្នកធ្វើឱ្យយើងអាម៉ាស់មុខ? ហេតុអ្វីបានជាព្រះអង្គដើរសុំអាហារគេ? មិនមាននរណាម្នាក់ក្នុងរាជវង្សយើង ធ្លាប់បានធ្វើដូច្នេះឡើយ**" ព្រះសម្មាសម្ពុទ្ធបានមានពុទ្ធដីកា តបវិញថា: "**មហាបពិត្រ និង ព្រះញាតិវង្សានុវង្ស អាចអះអាងថាជាខត្តិយវង្ស** ចំណែកឯវង្សរបស់តថាគតគឺជា **ពុទ្ធវង្ស** មានមកតាំងពីបុរាណ តែងមាន **ប្រក្រតីដើរបិណ្ឌបាត្រ និងរស់នៅអាស្រ័យចង្ហាន់បិណ្ឌបាត្រនេះឯង"។** បន្ទាប់មកបានសម្តែងធម៌ ព្រះសាស្តាត្រាស់ថា "ចូរប្រុងប្រយ័ត្ន ចូរមានស្មារតី ចូររស់នៅតាមគន្លងធម៌។" បុគ្គលដែល ដឹកនាំជីវិតតាមគន្លងធម៌ រមែងរស់នៅជាសុខក្នុងលោកនេះ និងលោកខាងមុខ។"

ពេលនោះ ព្រះរាជាបានជាក់ច្បាស់ក្នុងធម៌ ហើយបានតាំងនៅក្នុងសោតាបត្តិមគ្គ។

ព្រះសម្មាសម្ពុទ្ធ បន្ទាប់មក ទ្រង់យាងឆ្ពោះទៅកាន់ព្រះរាជវាំងដែលគ្រប់ៗគ្នាបានចេញមកគោរពវន្ទាចំពោះព្រះអង្គ លើកលែងតែព្រះនាងយសោធរា។ ព្រះសម្មាសម្ពុទ្ធក៏បានយាងទៅជួបព្រះនាង ដោយបានយល់អំពីរនាំងឃាំងឃាត់រវាងព្រះនាង និងព្រះពុទ្ធម្ចាស់ក្សត្រីបានឱនក្រាបនឹងព្រះបាទា ហើយថ្វាយបង្គំ។ ពេលនោះ ព្រះពុទ្ធអង្គទ្រង់ប្រោសដោយផ្សារភ្ជាប់រឿងអតីតជាតិមួយឈ្មោះថា ចន្ទកិន្នរាជាតក ដែលបង្ហាញពីគុណធម៌ដ៏អស្ចារ្យរបស់ព្រះនាងក្នុងជាតិនោះ ហើយព្រះពុទ្ធបានញ៉ាំងព្រះនាងឱ្យលុះក្នុងធម៌។ ក្រោយមក ពេលព្រះសម្មាសម្ពុទ្ធអនុញ្ញាតឱ្យស្ត្រីចូលបួស ព្រះនាងយសោធរាបានបួស

ជាភិក្ខុនីមួយរូបក្នុងចំណោមភិក្ខុនីដំបូងនៃពុទ្ធសាសនា និងបានសម្រេចនូវអរហត្តផល ដែលជាសេចក្តីបរិសុទ្ធដ៏ខ្ពស់បំផុត។

ពេលដែលព្រះសម្មាសម្ពុទ្ធគង់នៅក្នុងព្រះរាជវាំង ព្រះនាងយសោធរាបានរៀបចំតុបតែងព្រះកាយព្រះរាហុលយ៉ាងប្រណីតបំផុត ហើយបានបញ្ជូនឲ្យព្រះរាជបុត្រទៅគាល់ព្រះដ៏មានព្រះភាគ ដោយពោលថាៈ "ម្នាលរាហុល បុត្រសំឡាញ់ នោះជាបិតារបស់អ្នក ហើយ ចូរអ្នកទៅសុំកេរមរតករបស់អ្នកចុះ" ។

ព្រះរាហុលកុមារ បានចូលទៅរកព្រះសម្មាសម្ពុទ្ធ ឈរនៅទីចំពោះព្រះភ័ក្ត្រនៃព្រះដ៏មានព្រះភាគ ហើយពោលថា "បពិត្រសមណៈ ម្លប់របស់អ្នក ពិតជាគួរឱ្យរីករាយប្រាកដណាស់។"

នៅពេលដែលព្រះដ៏មានព្រះភាគបានទទួលភត្ត និងយាងចេញពីព្រះរាជវាំងទៅ ព្រះរាហុលបានដើរតាមក្រោយព្រះអង្គហើយពោលថាៈ "បពិត្រសមណៈ សូមប្រគល់នូវមរតកដល់ខ្ញុំព្រះអង្គៗ" ។ ពេលនោះព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដីកាទៅកាន់ព្រះសារីបុត្តថា "ម្នាលសារីបុត្ត ចូរអ្នកទទួលនូវ **រាហុលកុមារ** ឱ្យបួសផងចុះ"។

បន្ទាប់មក ព្រះសារីបុត្តបានបំបួស រាហុលរាជកុមារ។ ក្នុងមជ្ឈិមនិកាយ ដែលជាគម្ពីរ១ក្នុងចំណោមគម្ពីរទាំង៥ នៃព្រះសូត្រដែលព្រះដ៏មានព្រះភាគបានសម្តែង មានព្រះសូត្រ ៣ (លេខ៦១, ៦២, ១៤៧) មានចំណងជើងថា **រាហុលោវាទ** ឬ ឱវាទចំពោះព្រះរាហុល ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងដើម្បីប្រោសដល់រាហុលសមាណេរ។ ព្រះសូត្រទាំងនេះ ផ្តោតទាំងស្រុងទៅលើការទូន្មានក្នុងព្រះវិន័យ និង ព្រះកម្មដ្ឋាន។ នេះគឺជាដំណកស្រង់១ចេញពីឱវាទរបស់ព្រះសាស្តា នៅក្នុង **មហារាហុលោវាទសូត្រៈ**

"ម្នាលរាហុល ចូរចម្រើននូវមេត្តាកម្មដ្ឋាន ព្រោះការចម្រើននូវមេត្តាកម្មដ្ឋាននេះ អាចកម្ចាត់បង់នូវព្យាបាទៈ។ ម្នាលរាហុល ចូរចម្រើននូវករុណាកម្មដ្ឋាន ព្រោះការចម្រើននូវករុណាកម្មដ្ឋាននេះ អាចកម្ចាត់បង់នូវហឹង្សា។ ម្នាលរាហុល ចូរចម្រើននូវមុទិតាកម្មដ្ឋាន ព្រោះការចម្រើននូវមុទិតាកម្មដ្ឋាននេះ អាចកម្ចាត់បង់នូវឥស្សា។ ម្នាលរាហុល ចូរចម្រើននូវឧបេក្ខាកម្មដ្ឋាន ព្រោះការចម្រើននូវឧបេក្ខាកម្មដ្ឋាននេះ អាចកម្ចាត់បង់នូវបដិឃៈ។ ម្នាលរាហុល ចូរចម្រើននូវអសុភកម្មដ្ឋាន ព្រោះការចម្រើនននូវអសុភកម្មដ្ឋាននេះ អាចកម្ចាត់បង់នូវរាគៈ។ ម្នាលរាហុល ចូរចម្រើននូវអនិច្ចសញ្ញាកម្មដ្ឋាន ព្រោះការ

ចម្រើននូវអនិច្ចសញ្ញាកម្មដ្ឋាននេះ អាចកម្ចាត់បង់នូវអស្មិមានះ។ ម្នាលរាហុល ចូរចម្រើន នូវអនាបាណស្សតិកម្មដ្ឋាន ព្រោះអនាបាណស្សតិកម្មដ្ឋាននេះ បើចម្រើន និងបដិបត្តិ រឿយៗ រមែងនាំមកនូវផលប្រយោជន៍យ៉ាងច្រើនក្រៃលែង"។

## Women in Buddhism

Generally speaking, during the time of the Buddha, owing to brahminical influence, women were not given much recognition. Sometimes they were held in contempt and in servility to man. It was the Buddha who raised the status of women and there were cases of women showing erudition in matters of philosophy. In his large-heartedness and magnanimity he always treated women with consideration and civility, and pointed out to them, too, the path to peace, purity, and sanctity. Said the Blessed One: “A mother is the friend at one's home. A wife is the highest friend of the husband”

The Buddha did not reject the invitation for a meal though Ambapālī was of bad repute. Whatever food she offered he accepted, and in return, gave her the Dhammadāna, the gift of truth. She was immediately convinced by the teaching and leaving aside her frivolous lay life, she entered the Order of Nuns. Ardent and strenuous in her religious practices, she then became an arahat. Kịsāgotamī was another woman to whom the Buddha gave the assistance of his great compassion. Her story is one of the most touching tales recorded in our books. Many more are the instances where the Buddha helped and consoled women who suffered from the vicissitudes of life.

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| **Women in Buddhism** | **ស្ត្រីក្នុងព្រះពុទ្ធសាសនា** |
| servility | លក្ខណៈដូចទាសៈ |
| frivolous lay life | ជីវិតឃរាវាសដែលរឡិករឡក់ |
| vicissitudes of life | ដំណើរផ្លាស់ប្តូរនៃជីវិត ឬដំណើរវិបរិត (ជីវិតវិបរិត) |
| admonition, exhortation | ឱវាទ ឬដំបូន្មាន(ការដាស់តឿន) |
| funeral rites | ពិធីបុណ្យសព |
| mercy | សេចក្តីអាណិត អត់ឱន |
| erudition ពហុស្សុត | (ភាពមានវិជ្ជាជ្រៅជ្រះ ឬសិក្សារៀនសូត្រនិងស្តាប់បានច្រើន) |
| altar អាសនៈ (បុស្បុក); | outdoor altar រានព្រះភូមិ |
| large-heartedness | ចិត្តអាណិតមេត្តាទូលំទូលាយ |
| magnanimity | ទឹកចិត្តសប្បុរស |
| civility | អាកប្បកិរិយាទន់ភ្លន់ |

# ស្ត្រីក្នុងព្រះពុទ្ធសាសនា

និយាយជាទូទៅ នៅក្នុងពុទ្ធសម័យ ដោយសារឥទ្ធិពលនៃព្រហ្មញ្ញសាសនា ស្ត្រីមិនត្រូវបានគេផ្តល់តម្លៃខ្ពស់នោះទេ។ ពេលខ្លះ ពួកគេត្រូវបានទទួលការមើលងាយ និងជាទាសភាពសម្រាប់បុរស។ មានតែព្រះសម្មាសម្ពុទ្ធ ដែលលើកតម្លៃស្ត្រី ហើយមានករណីជាច្រើនដែលស្ត្រីបានបង្ហាញនូវភាពជាពហុស្សូត ក្នុងបញ្ហាទស្សនវិជ្ជា។ នៅក្នុងព្រះទ័យមេត្តាករុណាដ៏ធំទូលាយនិងសប្បុរស ព្រះអង្គតែងរាប់អានស្ត្រីទាំងឡាយដោយសមានចិត្ត និងភាពទន់ភ្លន់ ហើយបានចង្អុលបង្ហាញផ្លូវដល់ពួកគេ ទៅកាន់សន្តិភាព និងសេចក្តីបរិសុទ្ធ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងថា "**មាតាគឺជាមិត្តក្នុងផ្ទះ។ ភរិយាគឺជាមិត្តដ៏ប្រសើរបំផុតរបស់ស្វាមី**"។

ព្រះសម្មាសម្ពុទ្ធ មិនបានបដិសេធការនិមន្តទទួលភត្តឡើយ ទោះបីជានាងអម្ពបាលី មានកិត្តិនាមមិនល្អក៏ដោយ ។ ចង្ហាន់បែបណាក៏ដោយដែលនាងបានប្រគេនទៅ ព្រះអង្គទ្រង់ទទួលទាំងអស់ ហើយជាការតបស្នងវិញ ព្រះអង្គទ្រង់សម្តែងនូវធម្មទាន ជាអំណោយនៃសច្ចធម៌។ នាងមានសទ្ធាតាំងមាំភ្លាមៗ នៅក្នុងព្រះធម៌ ហើយបានចាកចេញពីជីវិតឃរាវាសដែលឥតខ្លឹមសារ ចូលទៅបួសជាភិក្ខុនី។ ដោយសេចក្តីព្យាយាមប្រឹងប្រែងក្នុងការបដិបត្តិធម៌ នាងក៏បានត្រាស់ជាព្រះអរហន្តីមួយអង្គ។

កិសាគោតមី ជាស្ត្រី១រូបទៀត ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសដោយមហាករុណា។ ប្រវត្តិរបស់នាង គឺជារឿងមួយដ៏គួរឲ្យចាប់អារម្មណ៍ខ្លាំងបំផុត ដែលបានកត់ត្រានៅក្នុងគម្ពីរផ្សេងៗ។ នៅមានឧទាហរណ៍ជាច្រើនទៀត ដែលព្រះសម្មាសម្ពុទ្ធបានជួយសង្គ្រោះ និងផ្តល់ប្រឹក្សាដល់ស្ត្រីទាំងឡាយដែលរងទុក្ខដោយសារដំណើរវិបរិតនៃជីវិត។

## Ministering to the Sick

Great indeed, was the Master's compassion for the sick. On one occasion the Blessed One found an ailing monk, Pūtigatta Tissa, with festering ulcers lying on his soiled bed. Immediately the Master prepared hot water, and with the help of the Venerable Ānanda washed him, tenderly nursed him with his own hands, and taught the Dhamma, thus enabling him to win arahatship before he died. On another occasion, too, the Master tended a sick monk and admonished his disciples thus:

“Whosoever, monks, would follow my admonition (would wait upon me, would honour me), he should wait upon the sick.”

When the arahat Tissa passed away, the funeral rites were duly performed and the Buddha caused the relics to be enshrined in a stupa.

The Buddha's mettā or loving-kindness was all pervading and immeasurable. His earnest exhortation to his disciples was:

“Just as with her own life
a mother shields from hurt
her own, her only child,
let all-embracing thoughts
for all that lives be thine.”

Being one who always acted in constant conformity with what he preached, loving-kindness and compassion always dominated his actions.

While journeying from village to village, from town to town, instructing, enlightening, and gladdening the many, the Buddha saw how superstitious folk, steeped in ignorance, slaughtered animals in worship of their gods.

He spoke to them:

“Of life, which all can take but none can give,
Life which all creatures love and strive to keep,

Wonderful, dear, and pleasant unto each,
Even to the meanest."

Thus when people who prayed to the gods for mercy were merciless, and India was blood-stained with the morbid sacrifices of innocent animals at the desecrated altars of imaginary deities, and the harmful rites and rituals of ascetics and brahmins brought disaster and brutal agony, the Buddha, the Compassionate One, pointed out the ancient path of the Enlightened Ones, the path of righteousness, love, and understanding.

Mettā or love is the best antidote for anger in oneself. It is the best medicine for those who are angry with us. Let us then extend love to all who need it with a free and boundless heart. The language of the heart, the language that comes from the heart and goes to the heart, is always simple, graceful, and full of power.

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| **Ministering to the Sick** | **ការជួយផ្គត់ផ្គង់ដល់អ្នកជំងឺ** |
| antidote | ថ្នាំបន្សាប |
| to wait on/upon the sick | នៅបម្រើអ្នកជំងឺ |
| to preach the Dhamma | សម្តែងព្រះធម៌ (ធម្មទេសនា) |
| the path of righteousness | មាគ៌ាធម៌ ឬមាគ៌ាប្រកបដោយធម៌ |
| to enshrine the relics in a stupa | តម្កល់ព្រះសារីរិកធាតុក្នុងចេតិយ |
| Dhammadāna, the gift of truth | ធម្មទាន |
| morbid sacrifices of innocent animals | ការបូជាយញ្ញផ្តាច់ផ្តិលជីវិតសត្វពាហនៈដែលស្លូតត្រង់ |
| large-heartedness and magnanimity | ព្រះទ័យអាណិតមេត្តាទូលំទូលាយ និងសប្បុរស |

# ការជួយផ្គត់ផ្គង់ដល់អ្នកជំងឺ

ជាការអស្ចារ្យប្រាកដណាស់ គឺព្រះទ័យករុណារបស់ព្រះសាស្តាចំពោះអ្នកមានជំងឺ។ សម័យថ្ងៃមួយ ព្រះភគវាបានជួបភិក្ខុ១អង្គដែលមានអាពាធ គឺព្រះ **បូតិគត្តតិស្សៈ** លោកមានដំបៅពោរពេញដោយខ្ទុះ កំពុងសម្រាកលើគ្រែដែលប្រឡាក់ដោយធូលី។ រំពេចនោះ ព្រះសាស្តាបានរៀបចំទឹកក្តៅ ហើយដោយមានការជួយពីព្រះអានន្ទផង បានជូតខ្លួនភិក្ខុនោះ បានខ្វល់ខ្វាយបម្រើដោយភាពទន់ភ្លន់ផ្ទាល់ព្រះហស្ត ហើយបានសម្តែងធម៌ដូច្នេះ បានញ៉ាំងឱ្យលោកបានសម្រេចនូវអរហត្តផល មុនពេលអនិច្ចធម្ម។ នៅឱកាសមួយទៀតដែរ ព្រះបរមសាស្តា បានបម្រើភិក្ខុដែលមានអាពាធ ហើយបានដាស់តឿនសាវ័ករបស់ព្រះអង្គ ដូច្នេះថា៖

**"ម្នាលភិក្ខុទាំងឡាយ បុគ្គលណាដើរតាមដំបូន្មានតថាគត (គាល់បម្រើតថាគត គោរពបូជាតថាគត) បុគ្គលនោះគួរបម្រើអ្នកជំងឺយ៉ាងនោះដែរ"។**

នៅពេលព្រះតិស្សៈ បានទទួលអនិច្ចធម្មទៅ ពិធីបុណ្យសពបានប្រព្រឹត្តទៅដោយត្រឹមត្រូវ ហើយព្រះសម្មាសម្ពុទ្ធបានញ៉ាំងអដ្ឋិធាតុរបស់លោកតម្កល់ក្នុងចេតិយ។ ព្រះទ័យមេត្តារបស់ព្រះសម្មាសម្ពុទ្ធ បានផ្សព្វផ្សាយទៅឥតដែនកំណត់។ ការទូន្មានរឿយៗចំពោះសាវ័ករបស់ព្រះអង្គដូចខាងក្រោម៖

"ប្រៀបដូចជា ដោយជីវិតរបស់នាងផ្ទាល់
មាតា ការពារបុត្រពីការបៀតបៀននានា
ដែលជាបុត្ររបស់ខ្លួន ជាបុត្រតែមួយគត់របស់ខ្លួន
ដូចគ្នានេះដែរ ចូរផ្សាយមេត្តាចិត្តពោរពេញដោយក្តីស្រឡាញ់
ចំពោះសព្វសត្វទាំងអស់ ដូចខ្លួនរបស់អ្នកដែរ" ។

ទ្រង់ជាបុគ្គល មានប្រក្រតីបដិបត្តិស្របតាមអ្វីដែលព្រះអង្គបានបង្រៀន មេត្តា និងករុណាធម៌ តែងតែគ្របដណ្តប់គ្រប់សកម្មភាពរបស់ព្រះអង្គជានិច្ច។

ពេលនិមន្តធ្វើដំណើរពីភូមិ១ទៅភូមិ១ ពីក្រុង១ទៅក្រុង១ ទ្រង់ប្រៀនប្រដៅ បំភ្លឺផ្លូវ និងញ៉ាំងជនជាច្រើនឲ្យជ្រះថ្លា ព្រះសម្មាសម្ពុទ្ធបានឃើញមនុស្សមួយចំនួនពោរពេញដោយអបិយជំនឿ ស៊ប់ជ្រៅក្នុងអវិជ្ជា គេសម្លាប់សត្វពាហនៈដើម្បីបូជាយញ្ញចំពោះព្រះអាទិទេពរបស់គេ ។ ទើបព្រះអង្គមានពុទ្ធដីកាទៅកាន់ពួកគេថាៈ

**"ជីវិត គេងាយផ្តាច់ផ្តិល តែគ្មាននរណាម្នាក់អាចឱ្យបានឡើយ**
**ជីវិតដែលសព្វសត្វស្រឡាញ់ហួងហែង ព្យាយាមថែឥតស្បើយ**
**អស្ចារ្យ ជាទីស្រឡាញ់ និងពេញចិត្ត រៀងៗខ្លួនគេងកៀកកើយ**
**សូម្បីចំពោះសត្វដែលអាក្រក់កាចសាហាវយ៉ាងណាក៏ដោយ"។**

ហេតុនេះហើយ នៅពេលមនុស្សបួងសួងដល់ព្រះជាម្ចាស់ដើម្បីការប្រោសប្រណី តែបែជាមិនបានការប្រោសប្រណី ហើយប្រទេសឥណ្ឌា មានការបង្ហូរឈាមជាច្រើនតាមរយៈពិធីបូជាយញ្ញ ផ្តាច់ជីវិតសត្វស្លូតត្រង់ នៅឯអាសនៈដែលគេបានរៀបចំថ្វាយអាទិទេពតាមការស្រមើស្រមៃ និងពិធីសាសនាប្រកបដោយការបៀបបៀនរបស់ពួកតាបស និងព្រាហ្មណ៍ទាំងឡាយ បាននាំមកនូវសេចក្តីវិនាសអន្តរាយ និងសេចក្តីទុក្ខយ៉ាងខ្លាំង។ ព្រះសម្មាសម្ពុទ្ធ ពោរពេញដោយសេចក្តីមេត្តាករុណា បានចង្អុលបង្ហាញនូវមាគ៌ាពីបុរាណនៃព្រះសម្មាសម្ពុទ្ធទាំងឡាយមុនៗ ជាមាគ៌ាប្រកបដោយសុចរិតធម៌ សេចក្តីស្រឡាញ់ និងការយោគយល់។

មេត្តា ឬ សេចក្តីស្រឡាញ់រាប់អាននេះ គឺជាថ្នាំបន្សាបដ៏ល្អបំផុតដើម្បីព្យាបាលទោសៈ ការស្អប់ខ្ពើម នៅក្នុងបុគ្គលម្នាក់ៗ។ នោះគឺជាឱសថដ៏សក្តិសិទ្ធិបំផុតសម្រាប់ផ្តល់ឱ្យដល់ជនណា ដែលខឹងស្អប់យើង។ ចូរយើងផ្សព្វផ្សាយ ពង្រីកនូវសេចក្តីស្រឡាញ់ចំពោះសព្វសត្វទាំងឡាយដែលត្រូវការ ប្រកបដោយបេះដូងទូលំទូលាយឥតព្រំដែន។ ភាសាបេះដូង ភាសាដែលចេញពីបេះដូង និងចូលទៅបេះដូង គឺតែងតែសាមញ្ញ ស្រស់ស្អាត និងពោរពេញដោយថាមពល។

## Equanimity and Self-composure

Amid all the vicissitudes of life-gain and loss, repute and ill-repute, praise and censure, pain and happiness --the Buddha never wavered. He was firm as a solid rock. Touched by happiness or by pain he showed neither elation nor depression. He never encouraged wrangling and animosity. Addressing the monks he once said: "I do not quarrel with the world, monks. It is the world that quarrels with me. An exponent of the Dhamma does not quarrel with anyone in the world.

He admonished his disciples in these words:

“Monks, if others were to speak ill of me or ill of the Dhamma or ill of the Sangha (the Order), you should not on that account entertain thoughts of enmity and spite, and be worried. If, monks, you are angry and displeased with them, it will not only impede your mental development but you will also fail to judge how far that speech is right or wrong. You should unravel what is untrue and make it all clear. Also, monks, if others speak highly of me, highly of the Dhamma and the Sangha, you need not on that account be elated; for that too will mar your inner development. You should acknowledge what is right and show the truth of what has been said.”

There never was an occasion when the Buddha manifested unfriendliness towards anyone-even to his opponents and enemies. There were those who opposed him and his doctrine, yet the Buddha never regarded them as enemies. When others reproached him in strong terms, the Buddha neither manifested anger nor aversion nor uttered an unkind word, but said:

“As an elephant in the battlefield endures the arrows shot from a bow, even so will I endure abuse and unfriendly expressions of others.”

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| **Equanimity and Self-composure** | **ឧបេក្ខា និងលំនឹងចិត្ត ( ការគ្រប់គ្រងខ្លួនឯង )** |
| elation ការរីករាយ ; | depression ការបាក់ទឹកចិត្ត |
| wrangling and animosity | ជម្លោះ និង ការស្អប់គុំកួន |
| an exponent of the Dhamma | អ្នកផ្សព្វផ្សាយធម៌ |
| to speak ill of the Dhamma | និយាយមិនល្អអំពីព្រះធម៌ |
| thoughts of enmity and spite | គំនិតអរិភាព និងគំនុំ |
| to impede mental development | រារាំងការបដិបត្តិអប់រំចិត្ត |
| to reproach | រិះគន់ស្តីបន្ទោស |
| Eight Worldly Dhamma | លោកធម៌៨៖ |

*gain មានលាភ # loss ឥតលាភ ; repute មានយស # ill-repute ឥតយស ;*

*praise សរសើរ # censure និន្ទា ; happiness សុខ # pain ទុក្ខ*

# ឧបេក្ខា និងលំនឹងចិត្ត

បិតក្នុងដំណើរវិបរិតនៃជីវិត **លោកធម៌ៈ មានលាភ និងឥតលាភ មានយស និង ឥតយស សរសើរ និងនិន្ទា ទុក្ខ និងសុខ** ព្រះសម្មាសម្ពុទ្ធមិនដែលកម្រើកញាប់ញ័រទេ ព្រះអង្គនៅនឹងដូចជាដុំថ្មដ៏រឹងមាំ។ ពាល់ត្រូវដោយសេចក្តីសុខក្តី ដោយសេចក្តីទុក្ខក្តី ព្រះអង្គមិនដែលសម្តែងនូវការរីករាយភ្លើតភ្លើន ឬការធ្លាក់ទឹកចិត្តឡើយ។ ព្រះអង្គមិនដែលលើកទឹកចិត្តនូវជម្លោះ និងការស្អប់ខ្ពើមឡើយ។ ទ្រង់ត្រាស់ទៅកាន់ភិក្ខុទាំងឡាយនាពេលមួយថាៈ "ម្នាលភិក្ខុទាំងឡាយ តថាគតមិនទំនាស់ជាមួយលោកនេះទេ។ គឺលោកនេះទេ ដែលទំនាស់ជាមួយតថាគត។ អ្នកផ្សព្វផ្សាយធម៌ មិនទំនាស់ជាមួយជនណាម្នាក់ក្នុងលោកឡើយ។

ព្រះអង្គបានដាស់តឿនទូន្មានសាវ័កទាំងឡាយដោយពាក្យយ៉ាងនេះៈ

"ម្នាលភិក្ខុទាំងឡាយ ប្រសិនបើជនដទៃ និយាយតិះដៀលតថាគតក្តី និយាយតិះដៀលព្រះធម៌ក្តី និយាយតិះដៀលព្រះសង្ឃក្តី ក្នុងករណីនេះ អ្នកមិនគួរមានគំនិតអរិភាព គុំកួន ឬព្រួយបារម្ភឡើយ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកខឹង និងទោមនស្សចំពោះអ្នកទាំងនោះ មិនត្រឹមតែរារាំងដល់ការបដិបត្តិអប់រំចិត្តរបស់អ្នកប៉ុណ្ណោះទេ ថែមទាំង អ្នកនឹងមិនអាចបែងចែកការនិយាយនោះថាត្រូវ ឬខុសផង។ អ្នកទាំងឡាយគួរតែស្រាយបំភ្លឺនូវអ្វីដែលមិនពិតនោះ ហើយធ្វើវាឲ្យច្បាស់ឡើង។
ម៉្យាងទៀត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើជនដទៃ ពោលសរសើរតថាគតក្តី ពោលសរសើរព្រះធម៌ក្តី ពោលសរសើរព្រះសង្ឃក្តី ក្នុងករណីនេះ អ្នកទាំងឡាយមិនគួរសប្បាយចិត្តឡើយ ព្រោះថា ការនេះផងដែរ នឹងធ្វើឱ្យប៉ះពាល់ដល់ការអប់រំចិត្តរបស់អ្នក។ អ្នកទាំងឡាយ គួរទទួលយកនូវអ្វីដែលត្រឹមត្រូវ ហើយបង្ហាញនូវសេចក្តីពិតតាមហេតុដែលបានពោលមកនេះ។"

ក្នុងគ្រាណាក៏ដោយ ព្រះពុទ្ធអង្គមិនដែលសម្តែងនូវភាពអមិត្ត(ភាពជាសត្រូវ) ចំពោះជនណាម្នាក់ឡើយ សូម្បីចំពោះអ្នកដែលប្រជែង និងជាសត្រូវជាមួយព្រះអង្គ។ មានមនុស្សមួយចំនួនដែលប្រឆាំងព្រះអង្គ និងព្រះធម៌របស់ព្រះអង្គ តែព្រះសម្មាសម្ពុទ្ធពុំ

ដែលចាត់ទុកពួកគេជាសត្រូវឡើយ។ នៅពេលជនដទៃតិះដៀលព្រះអង្គដោយសម្តីធ្ងន់ៗ ព្រះសម្មាសម្ពុទ្ធមិនដែលបង្ហាញនូវកំហឹង ទោសៈ បដិឃៈ ឬបញ្ចេញនូវវាចាមិនពីរោះណាមួយឡើយ ប៉ុន្តែទ្រង់សម្តែងថា៖

"ដូចជាដំរីនៅក្នុងសមរភូមិ អត់ទ្រាំនឹងផ្លែព្រួញដែលបាញ់ចេញពីធ្នូយ៉ាងណា តថាគតក៏នឹងអត់ទ្រាំជាមួយពាក្យជេរប្រមាថ និងអរិភាពពីអ្នកដទៃយ៉ាងនោះដែរ។"

# Devadatta

A striking example of this mental attitude is seen in his relation with Devadatta. Devadatta was a cousin of the Buddha who entered the Order and gained supernormal powers of the mundane plane (puthujjana-iddhi). Later, however, he began to harbour thoughts of jealousy and ill will toward his kinsman, the Buddha, and his two chief disciples, Sārīputta and Mahā Moggallāna, with the ambition of becoming the leader of the Saṅgha, the Order of Monks.

Devadatta wormed himself into the heart of Ajātasattu, the young prince, the son of King Bimbisāra. One day when the Blessed One was addressing a gathering at the Veluvana Monastery, where the king, too, was present, Devadatta approached the Buddha, saluted him, and said: “Venerable sir, you are now enfeebled with age. May the Master lead a life of solitude free from worry and care. I will direct the Order."

The Buddha rejected this overture and Devadatta departed irritated and disconcerted, nursing hatred and malice toward the Blessed One. Then, with the malicious purpose of causing mischief, he went to Prince Ajātasattu, kindled in him the deadly embers of ambition, and said:

“Young man, you had better kill your father and assume kingship lest you die without becoming the ruler. I shall kill the Blessed One and become the Buddha.”

So when Ajātasattu murdered his father and ascended the throne Devadatta suborned ruffians to murder the Buddha, but failing in that endeavour, he himself hurled down a rock as the Buddha was climbing up Gijjhakūṭa Hill in Rājagaha. The rock tumbled down, broke in two, and a splinter slightly wounded the Buddha. Later Devadatta made an intoxicated elephant charge at the Buddha; but the animal prostrated himself at the Master's feet, overpowered by his loving-kindness. Devadatta now proceeded to cause a schism in the Saṅgha, but this discord did not last long. Having failed in all his intrigues, Devadatta retired, a

disappointed and broken man. Soon afterwards he fell ill, and on his sick-bed, repenting his follies, he desired to see the Buddha. But that was not to be; for he died on the litter while being carried to the Blessed One. Before his death, however, he uttered repentance and sought refuge in the Buddha.

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| Devadatta | (ភិក្ខុ) ទេវទត្ត |
| overture | សំណើរសុំចរចា |
| to hurl down a rock | រមៀលថ្មទម្លាក់ |
| to suborn ruffians | ញុះញង់ជនអន្ធពាល |
| intrique | ផែនការសំងាត់ |
| malicious purpose of causing mischief | បំណងព្យាបាទក្នុងការបង្កអន្តរាយ |
| to prostrate himself at the Master's feet | ក្រាបចុះក្បែរព្រះបាទារបស់ព្រះបរមសាស្តា |
| to cause a schism in the Saṅgha | បង្កការបំបែកសង្ឃ (សង្ឃភេទ) |
| supernormal powers of the mundane plane (puthujjana-iddhi) | បុថុជ្ជនឥទ្ធិ (ឫទ្ធិរបស់បុថុជ្ជន) |
| repenting his follies | សោកស្តាយចំពោះកំហុស ឬភាពឆោតល្ងង់របស់គាត់ |

# ភិក្ខុទេវទត្ត

ឧទាហរណ៍ជាក់ស្តែងមួយនៃសភាពផ្លូវចិត្តបែបនេះ ឃើញនៅក្នុងទំនាក់ទំនងរបស់ព្រះអង្គជាមួយភិក្ខុទេវទត្ត។ ទេវទត្ត គឺជាបងប្អូនជីដូនមួយរបស់ព្រះសម្មាសម្ពុទ្ធ ដែលបានចូលបួស ហើយបានសម្រេចនូវលោកិយឈានដោយមានបុថុជ្ជនឥទ្ធិ ឫទ្ធិរបស់បុថុជ្ជន ។ ប៉ុន្តែក្រោយមក លោកមានគំនិតច្រណែន និងព្យាបាទចំពោះព្រះញាតិរបស់ខ្លួន គឺព្រះសម្មាសម្ពុទ្ធ និងអគ្គសាវ័កទាំង២របស់ព្រះអង្គៈ ព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន ដោយមហិច្ឆិតាចង់ក្លាយទៅជាមេដឹកនាំសង្ឃ។

ទេវទត្ត បានប្រើឧបាយកលយកព្រះទ័យព្រះរាជបុត្រ អជាតសត្តុ ដែលជាបុត្ររបស់ព្រះបាទពិម្ពិសារ។ ថ្ងៃមួយ ពេលព្រះដ៏មានព្រះភាគកំពុងសម្តែងធម៌ទៅកាន់បរិស័ទ ដែលមកត្រៀបត្រាក្នុងវត្តវេឡុវ័ន ហើយព្រះរាជាក៏មានព្រះវត្តមាននៅទីនោះដែរ ភិក្ខុទេវទត្ត បានទៅចូលទៅរកព្រះសម្មាសម្ពុទ្ធ ថ្វាយបង្គំហើយពោលថា "បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះព្រះអង្គទ្រុឌទ្រោមដោយវ័យហើយ។ សូមព្រះសាស្តា គង់នៅជាសុខក្នុងកម្មដ្ឋានចាកកង្វល់ និងសេចក្តីព្រួយទាំងឡាយចុះ ។ ខ្ញុំព្រះអង្គនឹងដឹកនាំសហគមន៍សង្ឃ។"

ព្រះសម្មាសម្ពុទ្ធបានបដិសេធចំពោះសំណើរនេះ ហើយទេវទត្តបានចាកចេញទៅទាំងកំហឹង និងមិនអស់ចិត្ត ដោយចិញ្ចឹមទោសៈ និងគំនិតព្យាបាទចំពោះព្រះដ៏មានព្រះភាគ។ ក្រោយមក ដោយបំណងព្យាបាទក្នុងការបង្កអន្តរាយ ទេវទត្តបានទៅជួបព្រះរាជកុមារ អជាតសត្តុ បានបញ្ឆេះភ្លើងកំហឹងនៃមិហិច្ឆិតា ហើយបានពោលថាៈ

"ម្នាលព្រះរាជបុត្រ ព្រះអង្គគួរតែសម្លាប់ព្រះបិតារបស់ព្រះអង្គ ហើយបន្តគ្រងរាជ្យ បើមិនធ្វើដូច្នោះទេ ព្រះអង្គនឹងទីវង្គត់ដោយមិនបានឡើងគ្រងរាជ្យ។ ចំណែកអាត្មាវិញនឹងសម្លាប់ព្រះដ៏មានព្រះភាគ ហើយក្លាយជាព្រះពុទ្ធ។"

ដូច្នេះ នៅពេលព្រះបាទអជាតសត្តុ បានធ្វើឃាតព្រះបិតា ហើយបានឡើងគ្រងរាជ្យ ទេវទត្តបានញុះញង់ជនអន្ធពាលឲ្យទៅធ្វើឃាតព្រះសម្មាសម្ពុទ្ធ ប៉ុន្តែការព្យាយាមនោះមិនបានជោគជ័យឡើយ ទេវទត្តខ្លួនឯង បានទៅរមៀលថ្មទម្លាក់ ខណៈពេលព្រះ

សម្មាសម្ពុទ្ធកំពុងយាងឡើងភ្នំគិជ្ឈកូដឯក្រុងរាជគ្រឹះ។ ដុំថ្មបានធ្លាក់ចុះ បែកជាពីរ ហើយកម្ទេចថ្ម១ចម្រៀក បានធ្វើឱ្យព្រះសម្មាសម្ពុទ្ធមានរបួសស្រាល (ហូរព្រះលោហិត)។ ក្រោយមក ទេវទត្តបានញ៉ាំងដំរីចុះប្រេងដេញព្រេចព្រះសម្មាសម្ពុទ្ធ ប៉ុន្តែដំរីបែរជាក្រាបចុះក្បែរព្រះបាទានៃព្រះបរមសាស្តា ដោយអានុភាពនៃមេត្តាចិត្តរបស់ព្រះអង្គ។ ទេវទត្តពេលនេះ បានងាកមកបង្កការបំបែកសង្ឃវិញម្តង ប៉ុន្តែការបែកបាក់នេះមិនបានយូរឡើយ។ ក្រោយទទួលបរាជ័យគ្រប់ផែនការអាក្រក់របស់ខ្លួន ទេវទត្តដល់ពេលចូលនិវត្តន៍ ហើយក្លាយជាបុគ្គលម្នាក់ដែលខូចចិត្ត និងធ្លាក់ទឹកចិត្តយ៉ាងខ្លាំង។ ភ្លាមបន្ទាប់នោះ ទេវទត្ត បានធ្លាក់ខ្លួនឈឺដេកនៅលើគ្រែ លោកមានការសោកស្តាយចំពោះកំហុស និងភាពឆោតល្ងង់របស់ខ្លួន ហើយមានបំណងចង់ជួបព្រះសម្មាសម្ពុទ្ធ។ ប៉ុន្តែមិនទាន់បានសម្រេចផង លោកបានទទួលអនិច្ចធម្មនៅលើគ្រែស្នែងខណៈពេលដែលគេកំពុងសែងទៅគាល់ព្រះភគវា។ ថ្វីបើដូច្នេះក្តី មុនពេលអនិច្ចធម្ម ទេវទត្តបានពោលនូវពាក្យសោកស្តាយ ហើយបានយកព្រះពុទ្ធជាទីពឹងទីរឭក។

# The Last Days

The Mahā Parinibbāna Sutta, the discourse on the passing away of the Blessed One, records in moving detail all the events that occurred during the last months and days of the Buddha's life.

The Blessed One had now reached the ripe age of eighty; his two chief disciples, Sārīputta and Mahā Moggallāna, had passed away three months earlier. Pajāpati Gotamī, Yasodharā, and Rāhula were also no more. The Buddha was now at Vesālī, and the rainy season having come, he went together with a great company of monks to Beḷuva to spend the rains there. There a severe sickness fell upon him, causing him much pain and agony, but the Blessed One, mindful and self-possessed, bore it patiently. He was on the verge of death; but he felt he should not pass away without taking leave of the Order. So with a great effort of will he suppressed that illness and kept his hold on life. His sickness gradually abated and when quite recovered he called the Venerable Ānanda, his personal attendant, and addressing him said:

"Ānanda, I am now grown old and full of years, my journey is drawing to a close. I have reached my sum of days, I am turning eighty years of age; and just as a worn-out cart, Ānanda, can only with much additional care be made to move along, so the body of the Tathāgata can only be kept going with much infusion of will-power. It is only when the Tathāgata, ceasing to attend to any outward thing and to experience any worldly sensation, attains to the sinless (animitta) concentration of mind, and dwells in it-it is only then that the body of the Tathāgata is at ease.

“Therefore, Ānanda, be islands unto yourselves. Be your own refuge. Have recourse to none else for refuge. Hold fast to the Dhamma as an island. Hold fast to the Dhamma as a refuge. Resort to no other refuge. Whosoever, Ānanda, either now or after I am gone, shall be islands unto themselves, refuges unto themselves, shall seek no external refuge-it is they,

Ānanda, among my disciples who shall reach the very topmost height! But they must be keen to progress.”

From Beḷuva the Buddha journeyed to the Mahāvana, and there calling up an assembly of all the monks residing in the neighbourhood of Vesālī, addressed them saying: “Disciples, the Dhamma realized by me, I have made known to you. Make yourselves masters of the Dhamma, practise it, meditate upon it, and spread it abroad: out of pity for the world, for the good and the gain and welfare of gods and men.”

The Buddha concluded his exhortation by saying:

“My age is now full ripe, my life draws to its close;
I leave you, I depart, relying on myself alone!
Be earnest then, O disciples, holy, full of thought!
Be steadfast in resolve! Keep watch o'er your own hearts!
Who wearies not but holds fast to this Truth and Law
Shall cross this sea of life, shall make an end of grief.”

Worn out with sickness, with feeble limbs, the Blessed One now journeyed on with much difficulty, followed by the Venerable Ānanda and a great company of monks. Even in this last, long, wearisome journey of his, the Buddha never failed in his attention to others. He instructed Cunda, the smith, who offered him his last meal. Then on the way, he stopped for Pukkusa, a disciple of Ālāra Kālāma, replied to all his questions, and so instructed him that Pukkusa offered himself as a follower of the Buddha, the Dhamma, and the Sangha.

The Blessed One now reached the Sala Grove of the Mallas at Kusiṇārā the journey's end. Knowing that here would be his last resting place, he told the Venerable Ānanda: “I am weary, Ānanda, and would lie down. Spread over for me the couch with its head to the north between the twin sāla trees.”

He then lay down on his right side, composed and mindful, with one leg resting on the other. Speaking now to the Venerable Ānanda, the Blessed One said:

“They who fulfil the greater and lesser duties, they who are correct in life, walking according to the precepts --it is they who rightly honour, reverence, and venerate the Tathāgata, the Perfect One, with the worthiest homage. Therefore, Ānanda, be steady in the fulfilment of the greater and the lesser duties, and be correct in life, walking according to the precepts. Thus, Ānanda, should you train yourselves."

# Dhamma Terminology វាក្យសព្ទព្រះធម៌

| | |
|---|---|
| **The Last Days** | **សម័យចុងក្រោយ** |
| The discourse on the passing away | មហាបរិនិព្វានសូត្រ |
| a severe sickness fell upon him | មានព្រះអាពាធខ្លាំងក្លាកើតឡើង |
| bore it patiently | ទ្រង់អត់សង្កត់ (ដោយអធិវាសនខន្តី) |
| Be islands unto yourself. | ចូរធ្វើនូវទីជម្រកដល់ខ្លួន (ធ្វើនូវទីពឹង) |
| Be your own refuge. | ចូរយកខ្លួនជាទីពឹងទីរឭក |
| Have recourse to none else for refuge. | កុំយករបស់ដទៃជាទីពឹងទីរឭក |
| Hold fast to the Dhamma as an island. | ចូរយកធម៌ជាកោះ ឬជម្រក (ទីពឹងទីរឭក) |
| Hold fast to the Dhamma as a refuge. | ចូរយកធម៌ជាទីពឹកទីរឭក |
| Resort to no other refuge. | កុំយករបស់ដទៃជាទីពឹងទីរឭកឡើយ |
| Seek no external refuge. | កុំយករបស់ខាងក្រៅជាទីពឹងទីរឭកឡើយ |
| shall reach the very topmost height | នឹងតាំងនៅក្នុងគុណដ៏ប្រសើរបំផុត |
| Be earnest! ចូរព្យាយាមប្រកបដោយស្មារតី | (មិនប្រមាទធ្វេស) |
| Be steadfast in resolve! | ចូរមានតម្រិះតម្កល់នឹងល្អ |
| Twin Sāla trees | ដើមសាលព្រឹក្សទាំងគូ |
| reverence and venerate | គោរពនិងបូជា |
| the worthiest homage | ការគោរពដ៏ឧត្តម (មានតម្លៃបំផុត) |
| signless (Animitta) concentration of mind | ចេតោសមាធិ (សេចក្តីតាំងចិត្តមាំ) ដែលមិនមាននិមិត្ត |
| The Blessed One was mindful and self-possessed | ព្រះមានព្រះភាគទ្រង់មានសតិ និងសម្បជញ្ញៈ |

Ānanda, personal attendant ព្រះអានន្ទ ជាពុទ្ធុបដ្ឋាកៈ (អ្នកគាល់បម្រើព្រះពុទ្ធដោយផ្ទាល់)

# សម័យចុងក្រោយ

មហាបរិនិព្វានសូត្រ គឺជាព្រះសូត្រស្ដីអំពីការបរិនិព្វាននៃព្រះដ៏មានព្រះភាគ ជាកំណត់ត្រាពិស្ដារ នៃព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងក្នុងរយៈកាលប៉ុន្មានខែថ្ងៃចុងក្រោយ ក្នុងជីវិតរបស់ព្រះសម្មាសម្ពុទ្ធ។

ព្រះដ៏មានព្រះភាគ ឥឡូវនេះបានឈានមកដល់វ័យជរា ព្រះជន្ម៨០វស្សា។ អគ្គសាវ័កទាំងពីររបស់ព្រះអង្គគឺ ព្រះសារីបុត្ត និង ព្រះមហាមោគ្គល្លាន បានចូលបរិនិព្វាន ៣ខែមុនព្រះអង្គហើយដែរ។ ព្រះនាងបជាបតិគោតមី ព្រះនាងយសោធរា និងព្រះរាហុល ក៏លែងមានវត្តមានទៀតដែរ។ ព្រះសម្មាសម្ពុទ្ធ ពេលនេះកំពុងគង់នៅក្រុងវេសាលី ហើយរដូវវស្សាក៏ចូលមកដល់ល្មម។ ព្រះអង្គបានយាងទៅដោយមានភិក្ខុសង្ឃជាបរិវារ ឆ្ពោះទៅកាន់ក្រុងពេឡុវៈ (វេឡុវៈ) ដើម្បីគង់ចាំព្រះវស្សានៅទីនោះ។ នៅទីនោះ អាពាធដ៏ខ្លាំងក្លាបានកើតឡើងដល់ព្រះអង្គ ធ្វើឱ្យព្រះអង្គមានសេចក្ដីទុក្ខ និងឈឺចាប់ដ៏ក្រៃលែង ប៉ុន្តែព្រះដ៏មានព្រះភាគ ប្រកបដោយសតិ និងសម្បជញ្ញៈ ទ្រង់អត់សង្កត់ដោយអធិវាសនខន្តី។

ព្រះអង្គស្ទើរនឹងក្ស័យសង្ខារ ប៉ុន្តែទ្រង់មានព្រះតម្រិះថា ព្រះអង្គមិនគួរចូលបរិនិព្វានដោយមិនបានលាភិក្ខុសង្ឃផងគ្នាឡើយ។ ដូច្នេះហើយ ដោយការព្យាយាមដ៏ក្រៃលែងក្នុងការគ្របសង្កត់នូវអាពាធ និង ការអធិដ្ឋាននូវជីវិតសង្ខារ។ អាពាធរបស់ព្រះអង្គក៏បានស្រាកស្រាន្តធូរស្បើយជាលំដាប់ ហើយពេលបានជាសះស្បើយទាំងស្រុង ព្រះអង្គបានត្រាស់ហៅព្រះអានន្ទ ដែលជាពុទ្ធុបដ្ឋាកៈ អ្នកគាល់បម្រើព្រះអង្គផ្ទាល់ ហើយត្រាស់ថា៖

“ម្នាលអានន្ទ តថាគត ពេលនេះមានវ័យជរាហើយ ដំណើររបស់តថាគតកាន់តែកៀកខិតហើយ។ ម្នាលអានន្ទ តថាគតបានមកដល់ថ្ងៃទីបំផុតហើយ តថាគតមានវ័យ៨០ហើយ ហាក់បីដូចជារទេះបាក់បែក ដោយការយកចិត្តទុកដាក់ជួសជុលបន្ថែមទើបអាចដំណើរការទៅបាន ដូចគ្នានេះដែរ កាយរបស់តថាគត អាចប្រព្រឹត្តទៅបាន ដោយអំណាចនៃឆន្ទៈប៉ុណ្ណោះ។ លុះណាតែតថាគត មិនដាក់អារម្មណ៍ជាមួយវេទនាទាំងឡាយក្នុងលោក ហើយចូលកាន់អនិមិត្តចេតោសមាធិ អាស្រ័យនៅទីនោះ នោះទើបកាយតថាគតបានធូរស្រាលខ្លះ។

"ព្រោះហេតុដូច្នេះ ម្នាលអានន្ទ ចូរធ្វើនូវទីជម្រកដល់ខ្លួនអ្នក។ ចូរយកខ្លួនជាទីពឹង។ កុំយកអ្នកដទៃជាទីពឹងឡើយ ។ ចូរយកព្រះធម៌ជាទីជម្រក។ ចូរយកព្រះធម៌ជាទីពឹងទីរឭក ។ កុំយកអ្នកដទៃជាទីពឹងឡើយ។ ម្នាលអានន្ទ បុគ្គលណាក៏ដោយ ទោះបីក្នុងកាលឥឡូវនេះក្តី ក្រោយពេលតថាគតចូលបរិនិព្វានទៅហើយក្តី ចូរធ្វើនូវទីជម្រកដល់ខ្លួនគេ ចូរធ្វើទីពឹងដល់ខ្លួនគេចុះ មិនគួរស្វែងរកវត្ថុក្រៅដទៃជាទីពឹងឡើយ បុគ្គលនោះឯង ម្នាលអានន្ទ ក្នុងចំណោមសាវ័កទាំងឡាយរបស់តថាគត ជាបុគ្គលនឹងបានតាំងនៅក្នុងគុណធម៌ដ៏ប្រសើរបំផុតដោយពិត! ប៉ុន្តែពួកគេត្រូវតែព្យាយាមប្រឹងប្រែងដើម្បីការរីកចម្រើន។"

ពីក្រុងពេឡុវៈ ព្រះសម្មាសម្ពុទ្ធ បានយាងទៅកាន់ព្រៃមហាវ័ន ហើយនៅទីនោះ ព្រះអង្គទ្រង់កោះប្រជុំសន្និបាតភិក្ខុសង្ឃដែលជាអ្នកមានប្រក្រតីគង់នៅជុំវិញក្រុងវេសាលី ដោយព្រះតម្រាស់ថា "ម្នាលសាវ័កទាំងឡាយ ព្រះធម៌ដែលតថាគតបានត្រាស់ដឹងហើយ តថាគតបានបង្រៀនដល់អ្នកទាំងឡាយហើយ។ ចូរធ្វើខ្លួនអ្នកឱ្យក្លាយជាគ្រូនៃធម៌ចុះ ចូរបដិបត្តិ និងចម្រើននូវធម៌ ហើយផ្សព្វផ្សាយឲ្យបានទូលំទូលាយៈ ដោយសេចក្តីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ និងសេចក្តីចម្រើននៃទេព្តា និងមនុស្សទាំងឡាយ។"

ព្រះសម្មាសម្ពុទ្ធទ្រង់សរុបនូវឱវាទរបស់ព្រះអង្គ ដោយពាក្យថាៈ

"វ័យតថាគតឥឡូវនេះចាស់គ្រាំគ្រា ជីវិតតថាគតកាន់តែកៀកហើយ
តថាគតនឹងលះបង់អ្នកទាំងឡាយ តថាគតនឹងចាកចេញទៅ
ដោយទីពឹងនៃតថាគតតែម្នាក់ឯង!
ម្នាលសាវ័កទាំងឡាយ ចូរព្យាយាមប្រឹងប្រែង ចូរតាំងនៅក្នុងសីល
ប្រកបដោយស្មារតីពេញលេញ!
ចូរមានការតាំងចិត្តដោយល្អ រក្សាចិត្តរបស់ខ្លួនឱ្យរឿយៗ!
បុគ្គលណាមិនប្រមាទ តាំងនៅក្នុងធម៌ និងវិន័យនេះ
នឹងបានឆ្លងផុតនូវសាគរជីវិត ហើយធ្វើនូវទីបំផុតនៃទុក្ខ។"

មានការបៀតបៀនដោយអាពាធ ជាមួយកាយដ៏ទ្រុឌទ្រោម ព្រះដ៏មានព្រះភាគឥឡូវនេះ បានធ្វើដំណើរប្រកបដោយសេចក្តីលំបាកបំផុត ហែហមដោយព្រះអានន្ទ និងសង្ឃសាវ័កជាច្រើនរូប។ សូម្បីនៅក្នុងដំណើរចុងក្រោយ ដ៏វែងឆ្ងាយ ប្រកបដោយការ

នឿយហត់របស់ព្រះអង្គក្តី ព្រះសម្មាសម្ពុទ្ធមិនដែលខកខានក្នុងការយកព្រះទ័យទុកដាក់ប្រោសសត្វឡើយ។ ព្រះអង្គបានប្រោស នាយចុន្ទ ជាជាងមាស ដែលបានថ្វាយភត្តចុងក្រោយដល់ព្រះអង្គ។ ពេលនោះនៅតាមផ្លូវ ព្រះអង្គបានឈប់ដើម្បីជួប បុក្កុសៈ ជាសាវ័ករបស់អាឡារៈកាលាមៈ ទ្រង់បកស្រាយរាល់សំណួររបស់គាត់ ហើយបានប្រោសបុក្កុសៈ ហើយគាត់ក៏បានថ្វាយខ្លួនជាសាវ័កដល់នូវត្រៃសរណគមន៍គឺ ព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ។

ពេលនេះ ព្រះដ៏មានព្រះភាគបានយាងមកដល់សាលឧទ្យាន នៃដែនមល្លៈនៅឯនគរកុសិនារា ជាដំណើរចុងក្រោយ។ ដោយទ្រង់ជ្រាបថា ទីនេះជាទីសម្រាកចុងក្រោយហើយ ព្រះអង្គបានត្រាស់ប្រាប់អានន្ទថា "ម្នាលអានន្ទ តថាគត នឿយហត់ណាស់ តថាគតចង់សម្រាកនៅទីនេះ។ ចូររៀបអាសនៈឱ្យតថាគត ដោយមានក្បាលឆ្ពោះទៅទិសខាងជើង នៅចន្លោះដើមសាលព្រឹក្សទាំងគូ។"

ពេលនោះ ព្រះអង្គទ្រង់ផ្ទុំដោយឥរិយាបថទម្រេតទៅខាងស្តាំ ព្រះទ័យស្ងប់ស្ងាត់ប្រកបដោយស្មារតី ព្រះបាទាម្ខាងសណ្តូកលើម្ខាងទៀត។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទៅកាន់ព្រះអានន្ទថាៈ

"បុគ្គលណាដែលបានបំពេញនូវកិច្ចទាំងឡាយ ដ៏ច្រើនក្តី តិចតួចក្តី ពួកគេរស់នៅប្រកបដោយសុចរិតធម៌ ដើរតាមគន្លងសីល បុគ្គលទាំងឡាយនោះ ជាអ្នកគោរព បូជាយ៉ាងត្រឹមត្រូវចំពោះតថាគត ជាព្រះអរហន្ត គឺជាការគោរពបូជាដ៏ប្រសើរបំផុត។ ព្រោះហេតុដូច្នោះ ម្នាលអានន្ទ ចូរអ្នកបំពេញនូវកិច្ចទាំងឡាយ ដ៏ច្រើនក្តី តិចតួចក្តី ចូររស់នៅប្រកបដោយសុចរិតធម៌ ដើរតាមគន្លងសីល។ ម្នាលអានន្ទ ព្រោះហេតុនេះ អ្នកគប្បីទូន្មានខ្លួន។"

## The Last Convert

At that time, a wandering ascetic named Subhadda, who was at Kusinārā, heard the news of the Blessed One's approaching death; and in order to clear up certain doubts that troubled his mind. he hurried to the Sala Grove to speak to the Buddha. The Venerable Ānanda, however, did not wish the Buddha to be disturbed in his last moments, and though Subhadda made several appeals, access to the Master was refused. The Blessed One overheard the conversation. He knew at once that Subhadda was making his investigations with a genuine desire for knowledge; and knowing that Subhadda was capable of quickly grasping the answers, he desired that Subhadda be allowed to see him. Subhadda's uncertainty was whether the leaders of the other schools of thought such as Pūraṇa Kassapa, Nigantha Nāṭaputta, and others had attained a true understanding. The Blessed One then spoke:

"In whatsoever Doctrine and Discipline (dhamma-vinaya), Subhadda, the Noble Eightfold Path is not found, neither in it is there found a man of true saintliness of the first, or of the second, or of the third, or of the fourth degree. And in whatsoever Doctrine and Discipline, Subhadda, the Noble Eight-fold Path is found. in it is found the man of true saintliness of the first, and the second, and the third, and the fourth degree. Now, in this Doctrine and Discipline, Subhadda, is found the Noble Eightfold Path, and it too are found the men of true saintliness of all the four degrees. Void are the systems of other teachers-void of true saints. And in this one, Subhadda, may the brethren live the life that is right, so that the world be not bereft of arahats."

Hearing the words of the Blessed One, Subhadda gained confidence, and took refuge in the Buddha, the Dhamma, and the Saṅgha. Furthermore, he desired to be admitted into the Order, and the Buddha requested the Venerable Ānanda to receive him. Subhadda thus became the last convert and the last disciple of the Blessed One, and before long by his strenuous effort he attained the final stage of arahatship.

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

| | |
|---|---|
| **The Last Convert** | **បុគ្គលដែលបានផ្លាស់ប្តូរចុងក្រោយ ( ផ្លាស់ប្តូរទិដ្ឋិ )** |
| a man of true saintliness of the first | បុគ្គលដែលបានសម្រេចនូវមគ្គផលថ្នាក់ទី១ (សោតិបត្តិមគ្គ/ផល) |
| uncertainty/doubt | វិចិកិច្ឆា (សេចក្តីសង្ស័យ) |
| Doctrine and Discipline (Dhamma-Vinaya) | ធម្មវិន័យ (ព្រះធម៌ និងព្រះវិន័យ) |
| to take refuge in the triple gem | យកព្រះរតនត្រ័យជាទីពឹងទីរឭក |
| closed fist of a teacher (Ācāriya-muṭṭhi) | អាចារិយមុដ្ឋិ (គ្រូបង្រៀនដែលលាក់វិជ្ជាពិសេស) |

# បច្ឆិមសាវ័ក
## (អ្នកដែលបានផ្លាស់ប្តូរចុងក្រោយគេ)

គ្រានោះឯង សុភទ្ទបរិព្វាជក ដែលនៅឯកុសិនារា បានឮដំណឹងថា ព្រះដ៏មានព្រះភាគនឹងចូលបរិនិព្វាន ដើម្បីជម្រះនូវសេចក្តីសង្ស័យមួយចំនួន ក៏បានប្រញាប់ចូលទៅកាន់សាលឧទ្យានដើម្បីគាល់ព្រះពុទ្ធ។ ទោះបីយ៉ាងណាក៏ដោយ ព្រះអានន្ទ មិនចង់ឱ្យនរណាម្នាក់ចូលទៅរំខានព្រះអង្គនៅនាទីចុងក្រោយនេះឡើយ ទោះបីសុភទ្ទៈបានទទូចសុំជាច្រើនដង ក៏នៅតែមិនព្រមឱ្យចូលគាល់ឡើយព្រះសាស្តាឡើយ។ ព្រះដ៏មានបុណ្យ ទ្រង់បានឮនូវការសន្ទនានោះ។ ទ្រង់បានជ្រាបភ្លាមថា សុភទ្ទ ពិតជាមានបំណងចង់សាកសួរព្រះធម៌ប្រាកដមែន ហើយទ្រង់ជ្រាបទៀតថា គាត់មានឧបនិស្ស័យអាចយល់ធម៌បានភ្លាមៗ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឱ្យចូលជួប។

ចម្ងល់របស់សុភទ្ទគឺ ថាតើគ្រូអាចារ្យដែលជាអ្នកដឹកនាំនៃលទ្ធិផ្សេងៗមានដូចជាបុរាណកស្សប និគន្ថនាដបុត្ត និងគ្រូផ្សេងៗទៀត បានសម្រេចនូវវិជ្ជាពិតប្រាកដដែរឬទេ។ ព្រះមានព្រះភាគទ្រង់សម្តែងដូចខាងក្រោមៈ

"ម្នាលសុភទ្ទ នៅក្នុងធម៌ និងវិន័យ(ធម្មវិន័យ)ណាក៏ដោយ កាលបើអរិយមគ្គអង្គប្រាំបីមិនមាន បុគ្គលដែលសម្រេចមគ្គទី១ក៏មិនមាន មគ្គទី២ក៏មិនមាន មគ្គទី៣ក៏មិនមាន មគ្គទី៤ក៏មិនមានយ៉ាងពិតប្រាកដ។ ផ្ទុយមកវិញ នៅក្នុងធម៌ និងវិន័យណាក៏ដោយ បើអរិយមគ្គអង្គប្រាំបីមានហើយ បុគ្គលដែលសម្រេចមគ្គទី១ក្តី មគ្គទី២ក្តី មគ្គទី៣ក្តី និងមគ្គទី៤ក្តី ក៏មានយ៉ាងពិតប្រាកដ។ ម្នាលសុភទ្ទ ឥលូវនេះ ក្នុងធម្មវិន័យនេះ ប្រកបព្រមហើយដោយអរិយមគ្គប្រាំបីប្រការ ដូច្នេះបុគ្គលដែលបានសម្រេចនូវមគ្គ៤ ផល៤ មានពិតប្រាដកដោយឥតសង្ស័យ។ លទ្ធិនៃគ្រូអាចារ្យណាដែលប្រាសចាកហើយនូវអរិយអដ្ឋង្គិមគ្គ ការសម្រេចមគ្គផលក៏មិនមាន។ ម្នាលសុភទ្ទ នៅក្នុងព្រះសាសនានេះ សូមឱ្យអ្នកទាំងឡាយជាបងប្អូន ប្រព្រឹត្តនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធចុះ ដើម្បីបន្តនូវពូជពង្សនៃព្រះអរហន្តទាំងឡាយ។"

ក្រោយពីបានស្ដាប់នូវព្រះពុទ្ធដីកាហើយ សុភទ្ទមានសទ្ធាជ្រះថ្លាយ៉ាងក្រៃលែង ក៏បានដល់នូវព្រះត្រៃសរណគមន៍ មានព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹង។ ជាងនេះទៀត សុភទ្ទមានប្រាថ្នាដើម្បីបួស ព្រះពុទ្ធទ្រង់ឱ្យព្រះអានន្ទទទួលសំណើរនេះ។ ហេតុនេះ សុភទ្ទភិក្ខុ បានក្លាយជាសាវ័កចុងក្រោយគេរបស់ព្រះមានព្រះភាគ មិនយូរប៉ុន្មានដោយការព្យាយាមដ៏ក្រៃលែង លោកក៏បានសម្រេចអរហត្តផល។

## The Last Scene

Now the Blessed One, addressing the Venerable Ānanda, said:

"I have taught the Dhamma, Änanda, without making any distinction between exoteric and esoteric doctrine, for in respect of the truth, Ānanda, the Tathāgata has no such thing as the 'closed fist' of a teacher who hides some essential knowledge from the pupil.

"It may be, Ánanda, that in some of you the thought may arise,
The word of the Master is ended. We have no teacher any more." But it is not thus, Ānanda, that you should think.

"The Doctrine and the Discipline which I have set forth and laid down for you-let them, after I am gone, be your teacher. It may be, monks, that there may be doubts in the minds of some brethren as to the Buddha, or the Dhamma, or the Sangha, or the path (magga) or method (paṭipadā). Inquire, monks, freely. Do not have to reproach yourselves afterwards with the thought: 'Our teacher was face to face with us, and we could not bring ourselves to inquire of the Exalted One when we were face to face with him.'

When the Buddha had thus spoken the monks were silent.

A second and a third time the Blessed One repeated these words to the monks, and yet the monks were silent. And the Venerable Ānanda said to the Blessed One: "How wonderful a thing is it, Lord, how marvellous! Truly, I believe that in this whole assembly of the monks there is not one who has any doubt or misgivings as to the Buddha or the Dhamma or the Sangha, or the path or the method."

The Blessed One confirmed the words of the Venerable Ānanda, adding that in the whole assembly even the most backward one was assured of final deliverance. And after a short while the Master made his final exhortation to those who wished to follow his teaching now and in the future:

“Behold now, O monks, I exhort you: impermanent are all compounded things. Work out your deliverance with mindfulness (vayadhammā saṃkhārā, appamādena sampādetha).

These were the last words of the Buddha.

Then the Master entered into those nine successive stages of meditative absorption (jhāna) which are of increasing sublimity: first the four fine material absorptions (rūpa-jhāna), then the four immaterial absorptions (arūpa-jhāna), and finally the state where perceptions and sensations entirely cease (saññā-vedayita-nirodha). Then he returned through all these stages to the first fine-material absorption and rose again to the fourth one. Immediately after having re-entered this stage (which has been described as having “purity of mindfulness due to equanimity”), the Buddha passed away (parinibbāyi). He realized Nibbāna that is free from any substratum of further becoming (parinibbāna).

In the Mahā Parinibbāna Sutta are recorded, in moving detail, all the events that occurred during the last months and days of the Master's life.

In the annals of history, no man is recorded as having so consecrated himself to the welfare of all beings, irrespective of caste, class, creed, or sex, as the Supreme Buddha. From the hour of his enlightenment to the end of his life, he strove tirelessly and unostentatiously to elevate humanity regardless of the fatigue involved and oblivious to the many obstacles and handicaps that hampered his way. He never relaxed in his exertion for the common weal and was never subjected to moral or spiritual fatigue. Though physically he was not always fit, mentally he was ever vigilant and energetic.

Therefore it is said:

“Ah, wonderful is the Conqueror,
who e'er untiring strives,
for the blessings of all beings,
for the comfort of all lives."

Though twenty-five centuries have gone since

the passing away of the Buddha, his message of love and wisdom still exists in its purity, decisively influencing the destinies of humanity. Forests of flowers are daily offered at his shrines and countless millions of lips daily repeat the formula: Buddhaṃ saraṇaṃ gacchāmi, "I take refuge in the Buddha." His greatness yet glows today like a sun that blots out lesser lights, and his Dhamma yet beckons the weary pilgrim to Nibbāna's security and peace.

# Dhamma Terminology **វាក្យសព្ទព្រះធម៌**

**The Last Scene** **ព្រឹត្តិការណ៍ចុងក្រោយ**

set forth and lay down ទ្រង់កំណត់ និងបញ្ញត្តទុក

method (Paṭipadā) បដិបទា ឬមាគ៌ាបដិបត្តិ

Buddha's final exhortation ពុទ្ធឱវាទចុងក្រោយ (បច្ឆឹមពុទ្ធវចនៈ)

Behold, monks! ម្នាលភិក្ខុទាំងឡាយ ចូរកុំប្រមាទ (កុំធ្វេសប្រហែស)

free from any substratum of further becoming (Parinibbāna) បរិនិព្វាន

vigilant and energetic ដែលប្រុងប្រយ័ត្ន និងប្រកបដោយសេចក្តីព្យាយាមស្វាហាប់

Buddha's shrine/stupa ធាតុចេតិយ ឬព្រះស្តូប

nine successive stages of meditative absorption (Jhāna) សមាបត្តិ ឬឈាន ៩

four fine-material absorptions (Rūpa-jhāna) រូបឈាន ៤

four immaterial absorptions (Arūpa-jhāna) អរូបឈាន ៤

the state where perceptions and sensations entirely cease (Saññāvedayita-nirodha) -សញ្ញាវេទយិតនិរោធសមាបត្តិ (ការចូលដល់និរោធគឺរលត់សញ្ញា និងវេទនា ជាធម៌ល្អិតជាងនេវសញ្ញានាសញ្ញាយតនៈ ទៅមួយជាន់ទៀត (ព្រះអរហន្ត និងព្រះអនាគាមីដែលបានសមាបត្តិ៨ហើយ ទើបចូលនិរោធសមាបត្តិបាន)។

# ព្រឹត្តិការណ៍ចុងក្រោយ

ឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទៅកាន់ព្រះអានន្ទថាៈ

"ម្នាលអានន្ទ តថាគតបានសម្តែងធម៌ ដោយមិនមានការបែងចែករវាងជនទូទៅ និងជនមួយក្រុមឡើយ ដោយផ្អែកទៅលើសច្ចធម៌ តថាគតមិនមានអ្វីដែលជា អាចរិយ-មុដ្ឋិ គឺគ្រូបង្រៀនដែលមានការលាក់វិជ្ជាពិសេសអំពីសិស្សនោះឡើយ"។

"ម្នាលអានន្ទ ប្រហែលជា សាវ័កមួយចំនួនអាចនឹងមានគំនិតដូចនេះកើតឡើង "ការទូន្មានរបស់ព្រះសាស្តាបានបញ្ចប់ហើយ។ យើងនឹងមិនមានសាស្តាទៀតទេ"។ ម្នាលអានន្ទ មិនមែនដូច្នោះទេ អ្នកមិនគួរគិតបែបនេះឡើយ។

"ព្រះធម៌ និងព្រះវិន័យដែលតថាគតបានបញ្ញត្តទុកហើយសម្រាប់អ្នក អស់ពីតថាគតទៅ ចូរយកព្រះធម៌ និងព្រះវិន័យនេះ ជាគ្រូរបស់អ្នកចុះ។ ម្នាលភិក្ខុទាំងឡាយ ប្រហែលជា អ្នកខ្លះអាចនៅមានមន្ទិលសង្ស័យក្នុងចិត្តអំពី ព្រះពុទ្ធ ព្រះធម៌ ឬ ព្រះសង្ឃ ឬមគ្គ និងបដិបទា។ ម្នាលភិក្ខុទាំងឡាយ អ្នកចូរសាកសួរដោយសេរីចុះ។ ចូរកុំស្តីបន្ទោសខ្លួនឯងក្នុងកាលជាក្រោយដោយគំនិតថា "ព្រះសាស្តាគង់នៅនឹងមុខពួកយើង តែពួកយើងមិននាំគ្នាសាកសួរព្រះអង្គសោះ"។

ពេលដែលព្រះសម្មាសម្ពុទ្ធមានពុទ្ធដីកាដូច្នេះ ភិក្ខុទាំងឡាយគង់នៅស្ងៀម។

អស់វារៈ២ដងផង អស់វារៈ៣ដងផង ព្រះដ៏មានព្រះភាគមានពុទ្ធដីកាដដែលៗ ទៅកាន់ភិក្ខុទាំងឡាយ តែភិក្ខុទាំងឡាយនៅតែស្ងាត់ស្ងៀមដដែល។ ហើយព្រះអានន្ទ បានទូលទៅកាន់ព្រះដ៏មានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ជារឿងគួរឲ្យអស្ចារ្យណាស់ នេះជារឿងអស្ចារ្យ! ជាការពិតណាស់ ខ្ញុំព្រះអង្គជឿជាក់ថានៅក្នុងជំនុំសង្ឃនេះ មិនមានអង្គណាដែលនៅមានវិចិកិច្ឆា ឬសេចក្តីសង្ស័យក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ឬមគ្គ ឬបដិបទាឡើយ" ។

ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ជាក់នូវពាក្យរបស់ព្រះអានន្ទ ហើយមានពុទ្ធដីកាបន្ថែមថា នៅក្នុងជំនុំសង្ឃនេះទាំងមូល សូម្បីភិក្ខុដែលទាបបំផុតក៏បានសម្រេចនូវសោតាបត្តិផលដែរ ហើយទៀងនឹងបានទីបំផុតទុក្ខ។ បន្ទាប់មកមិនយូរប៉ុន្មាន

ព្រះសាស្តាទ្រង់ប្រទាននូវឱវាទចុងក្រោយ សម្រាប់អ្នកដែលប្រាថ្នាដើរតាមការបង្រៀនរបស់ព្រះអង្គ ទាំងក្នុងបច្ចុប្បន្ន និងក្នុងពេលជាអនាគតៈ

**"ម្នាលភិក្ខុទាំងឡាយ ចូរកុំប្រមាទ កុំធ្វេសប្រហែសឡើយ តថាគតងាស់តឿនអ្នកៈ សង្ខារធម៌ទាំងឡាយមិនទៀងទាត់ឡើយ មានការសាបសូន្យទៅវិញជាធម្មតា។ ចូររំដោះខ្លួនអ្នកដោយសេចក្តីមិនប្រមាទ (វយធម្មា សំខារា អប្បមាទេន សម្បាទេថ)។**

នេះគឺជាបច្ឆិមពុទ្ធវចនៈ។

បន្ទាប់មក ព្រះសាស្តា ទ្រង់ចូលទៅកាន់**ឈានសមាបត្តិ៩** ដែលមានភាពល្អិតទៅតាមលំដាប់៖ **រូបឈាន៤ អរូបឈាន៤ និង សញ្ញាវេទយិតនិរោធសមាបត្តិ** គឺជាសភាវៈដែល សញ្ញា និងវេទនា រលត់ទាំងស្រុង។ បន្ទាប់មក ព្រះអង្គត្រឡប់បញ្ច្រាស់គ្រប់លំដាប់នៃឈាន ចុះទៅដល់រូបឈានទី១ ហើយត្រឡប់ឡើងវិញទៅដល់រូបឈានទី៤។ រំពេចនោះ បន្ទាប់ពីបានត្រឡប់ចូលមកម្តងទៀតតាមលំដាប់យ៉ាងនេះ (ដូចដែលបានអធិប្បាយថា ដូចជាការបាន "សេចក្តីបរិសុទ្ធនៃសមាធិប្រកបដោយឧបេក្ខា") ព្រះសម្មាសម្ពុទ្ធបានចូលបរិនិព្វាន (បរិនិព្វាយិ)។ ព្រះអង្គបានសម្រេចព្រះនិព្វាន ដែលរួចចាកពីភព ឬជាតិកំណើត។

នៅក្នុង**មហាបរិនិព្វានសូត្រ** បានកត់ត្រាយ៉ាងពិស្តារ គ្រប់ព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរយៈកាលប៉ុន្មានខែថ្ងៃចុងក្រោយនៃអាយុសង្ខាររបស់ព្រះសាស្តា។

នៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រ មិនមានមនុស្សណាម្នាក់ ដែលមានកំណត់ត្រានៃការលះបង់ខ្លួនផ្ទាល់ ដើម្បីសុខុមាលភាពនៃសព្វសត្វ ដោយគ្មានការរើសអើងវណ្ណៈឋានៈ លទ្ធិសាសនា ឬភេទ ដូចជាព្រះបរមសាស្តាឡើយ។ ចាប់ពីពេលត្រាស់ដឹងរហូតដល់ចុងក្រោយនៃជីវិតរបស់ព្រះអង្គ ព្រះអង្គបានព្យាយាមដោយមិនខ្លាចនឿយហត់ និងមិនមែនដោយការសម្តែង គឺដើម្បីលើកស្ទួយមនុស្សជាតិ ដោយមិនគិតអំពីសេចក្តីលំបាក និងឧបសគ្គដែលកើតមាន រារាំងដល់ផ្លូវរបស់ព្រះអង្គឡើយ។ ព្រះអង្គមិនដែលផ្អាកក្នុងវិរិយភាពដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់មនុស្សទូទៅ ហើយមិនដែលខ្លាចនឿយហត់ក្នុងការអប់រំទូន្មានចិត្តនោះទេ។ ទោះបីជាពេលខ្លះ ផ្លូវកាយមិនបរិបូរណ៍ក្តី តែព្រះទ័យព្រះអង្គតែងមានការប្រុងប្រយ័ត្ន និងពោរពេញដោយថាមពលជានិច្ច។

ដូច្នេះហើយ ទើបមានការលើកឡើងថា៖

“អាហ៏ អស្ចារ្យពិត គឺជាបុគ្គលដែលឈ្មោះ

បុគ្គលណាក៏ដោយដែលមានសេចក្តីព្យាយាមដោយមិនខ្លាចនឿយហត់

ដើម្បីសុភមង្គលនៃសព្វសត្វទាំងឡាយ

ដើម្បីផាសុកភាពដល់ជីវិតទាំងអស់” ។

ថ្វីបើ ២៥ សតវត្សរ៍បានកន្លងផុតទៅមែន ចាប់តាំងពីការបរិនិព្វានរបស់ព្រះពុទ្ធបរមគ្រូ ប៉ុន្តែមេរៀននៃមេត្តា និងបញ្ញា ស្ថិតនៅក្នុងភាពបរិសុទ្ធដូចដើម ហើយបានជះឥទ្ធិពលយ៉ាងខ្លាំង ទៅលើជោគវាសនានៃមនុស្សជាតិ។ ផ្កាជាច្រើន រាប់សួនមិនអស់ ត្រូវបានបូជានៅតាមព្រះស្តូបនានារបស់ព្រះអង្គ បបូរមាត់រាប់លានប្រមាណមិនត្រូវ បានស្វាធ្យាយនូវធម៌នេះ ជារៀងរាល់ថ្ងៃ ដដែលៗ៖

**"ពុទ្ធំ សរណំ គច្ឆាមិ : ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីពឹង៕"**

ភាពអស្ចារ្យរបស់ព្រះអង្គ នៅរះចែងចាំងរហូតដល់បច្ចុប្បន្នសម័យ ប្រៀបបីដូចព្រះអាទិត្យដែលគ្របដណ្តប់អស់ពន្លឺតូចៗទាំងឡាយ ហើយព្រះធម៌របស់ព្រះអង្គជាធម្មយាត្រាដឹកនាំពាំយកសត្វលោក ឆ្ពោះទៅរក សុខសន្តិភាពពោលគឺ **អមតៈមហានិព្វាន៕**

# នាមសប្បុរសជនចូលបោះពុម្ពសៀវភៅ

## សហរដ្ឋអាមេរិក

- ❖ ភិក្ខុ អគ្គវីរិយោ កុល វិន វត្តខ្មែរហាវៃ ពុទ្ធារាម (រដ្ឋហាវៃ) $100
- ❖ ភិក្ខុ ធម្មប្បញ្ញោ ជិន ភិរុណ វត្តពុទ្ធសាសនរង្សី Fresno (CA) $100
- ❖ Upāsikā Sovanna Peng and Mother Kim Tho (Texas) $500
- ❖ ឧទ្ទេសាចារ្យ ប៉ូ ពិសិដ្ឋ និងអ្នកម្តាយ ឈឹម សារិទ្ធ (រដ្ឋលូវីស៊ីអែនណា) $500
- ❖ ក្រុមឧបាសិកា រដ្ឋមិនីសូតា ដឹកនាំដោយ ឧបាសិកា រី សុជាត្រា $200
- ❖ អ្នកស្រី ឌី ច័ន្ទធរី និងស្វាមី ព្រមទាំងបុត្រ (រដ្ឋកូឡូរ៉ាដូ) $100
- ❖ អ្នកស្រី ហ៊ុល ដាណា និងស្វាមី ព្រមទាំងបុត្រ (រដ្ឋអ៊ីលីណយ) $100
- ❖ ឧបាសិកា Sikheang Nhem (រដ្ឋនូវយ៉ក) $100
- ❖ ព្រះភិក្ខុ ជោតថេរោ ប៊ុន ហេង (រដ្ឋតិចសាស) $50
- ❖ ឧបាសិកា ពុធ ធិតា និងស្វាមី ព្រមទាំងបុត្រ (រដ្ឋអ៊ែរីហ្សូណា) $50
- ❖ Kunmealy Malai and Family (Washington State) $100
- ❖ Venerable Chean Sothy (Texas) $100
- ❖ Sokkhorn Tan & family (Texas) $50
- ❖ លោកអាចារ្យ ហេង សិរី (រដ្ឋតិចសាស) $50
- ❖ Mrs. Phany Sann and Daughter Thida Sou (Texas) $50
- ❖ Mrs. Chanren So and Daughter Lauren Kang (Connecticut) $25
- ❖ Mr. Robert Foster and Mrs. Channary Hong (Utah) $25
- ❖ Mr. Donald Foster (Utah) $25
- ❖ Mrs. Marlene Metta Long and Sons: Joshua, Davis Long,
- ❖ Jaiden Rotana Long (Massachusetts) $25
- ❖ Phillip Blackbum & Mrs. Samrech Blackbum & family (Tennessee) $25
- ❖ Melanie Y Lim (Oregon) $50
- ❖ Chou Sa-Ngoun (WA) $100
- ❖ Senny Sa-Ngnou (WA) $20
- ❖ Tieng Chartier (WA) $100
- ❖ Chamroeun Hul (WA) $20
- ❖ Kim Khout (WA) $20
- ❖ Peov Bun (WA) $5
- ❖ Kimseng Sun (WA) $20
- ❖ Sarith and Sambath (WA) $30

# ប្រទេសកម្ពុជា

| | | | |
|---|---|---|---|
| ❖ | ភិក្ខុ សង្ឃ មនាបោ អៀម យ៉ែន | (ភ្នំពេញ និង ភូមា) | $15 |
| ❖ | ហ៊ូ ស្រីពេជ្រ និងក្រុមគ្រួសារ | (ភ្នំពេញ) | $100 |
| ❖ | លាង ស្រីស្រស់ | (ភ្នំពេញ) | $10 |
| ❖ | លាង ដាលីន | (ភ្នំពេញ) | $10 |
| ❖ | សាយ ទេវិន្ទ | (ភ្នំពេញ) | $10 |
| ❖ | ឧបាសិកា ចាន់ ធី | (ភ្នំពេញ) | $20 |
| ❖ | សៅ សំភី | (ភ្នំពេញ) | $50 |
| ❖ | ហ៊ុន ប៊ុនណា | (ភ្នំពេញ) | $30 |
| ❖ | ស៊ីម សុធន | (ភ្នំពេញ) | $10 |
| ❖ | ប្រាក់ សុខចិន្តា | (ភ្នំពេញ) | $8 |
| ❖ | ជួប ដាឡែន | (ភ្នំពេញ) | $14 |
| ❖ | ហ៊ាង សុគីម | (បាត់ដំបង) | $20 |
| ❖ | នូ គីនីន | (កំពង់ស្ពឺ) | $5 |
| ❖ | ផន ផានី | (កណ្តាល) | $10 |
| ❖ | ជា បុព្វេ | (ភ្នំពេញ) | $10 |
| ❖ | ហ៊ីន គន្ធា | (ភ្នំពេញ)) | $10 |
| ❖ | ភន ជាសុកា | (ភ្នំពេញ) | $50 |
| ❖ | វង្ស សុធារី | (បាត់ដំបង) | $20 |
| ❖ | ឃីន គឹមឈាង | (ភ្នំពេញ) | $5 |
| ❖ | ឌី សេងឃា | (ព្រៃវែង) | $10 |
| ❖ | ឃីន ពិសី និង ចក់ សុភាព | (ភ្នំពេញ) | $50 |



## ប្រវត្តិសង្ខេប (អ្នកបកប្រែ)

៙ ភិក្ខុ **សុខ ធារី** កើតនៅ ភូមិបុសថ្លាន់ ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម

៙ បួសជាសាមណេរអាយុ ៩ ឆ្នាំ ក្នុងឆ្នាំ ១៩៩៨ បព្វជិតនាម **សុមនសាមណេរ** នា វត្តគិរីសុវណ្ណារាម ហៅបុសថ្លាន់។

៙ ឧបសម្បទា អាយុ ២៩ ក្នុងឆ្នាំ ២០១៧ នាមបញ្ញត្តិ **មុនីបុត្តោ** នាពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា ស្រុកពញាឮ ខេត្តកណ្ដាល

**ប្រវត្តិការសិក្សា និងបទពិសោធន៍ការងារ**

៙ បរិញ្ញាបត្រពុទ្ធសាសនា (Buddha Dhamma) សកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ (ITBMU) ប្រទេសភូមា (២០០៧ - ២០១០)។

៙ បរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) ទស្សនវិជ្ជាពុទ្ធសាសនា (Buddhist Studies) សកលវិទ្យាល័យ Kelaniya ប្រទេសស្រីលង្កា (២០១១ - ២០១៣)។

៙ អតីតសាស្ត្រាចារ្យនៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ ភ្នំពេញ (២០១៤)

៙ បង្រៀនពុទ្ធសាសនា ជាភាសាអង់គ្លេសតាំងពីឆ្នាំ ២០១៣ មកទល់បច្ចុប្បន្ន ឆ្នាំ ២០២៣ មានរយៈពេល ១០ឆ្នាំ គត់

៙ បច្ចុប្បន្ន គង់នៅវត្តខ្មែរហាវៃ ពុទ្ធារាម រដ្ឋហាវៃ សហរដ្ឋអាមេរិក។

៙ ជានាយកប្រតិបត្តិ មូលនិធិធម្មិកជីវិត *Dhammika Life Foundation, USA*

៙ ជានាយក វិទ្យាស្ថានធម្មិកៈអន្តរជាតិ *Dhammika Academy International*

# ប្រវត្តិសង្ខេប វិទ្យាស្ថានធម្មិកៈអន្តរជាតិ

**វិទ្យាស្ថានធម្មិកៈអន្តរជាតិ** (វ.ធ.អ) គឺជាគម្រោងចំបងរបស់ **មូលនិធិធម្មិកជីវិត** មានទីតាំងនៅទីក្រុងស៊ីអាថុល រដ្ឋវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៨ ដោយព្រះតេជគុណ **មុនីបុត្តោ សុខ ធារី** សព្វថ្ងៃគង់នៅវត្តខ្មែរហាវៃ រដ្ឋហាវៃ។

វត្ថុបំណងធំបំផុតរបស់វិទ្យាស្ថានធម្មិកៈអន្តរជាតិ គឺផ្ដល់ឱកាសដល់ពុទ្ធបរិស័ទខ្មែរ ទាំងព្រះសង្ឃ និងគ្រហស្ថ បានសិក្សាឈ្វេងយល់ **ព្រះពុទ្ធសាសនាជាភាសាអង់គ្លេស** ក្នុងន័យបណ្ដុះបណ្ដាលធម្មទូត ដើម្បីចូលរួមផ្សព្វផ្សាយពុទ្ធសាសនាខ្មែរលើឆាកអន្តរជាតិ។ មិនតែប៉ុណ្ណោះ វិទ្យាស្ថានធម្មិកៈអន្តរជាតិកន្លងមកក៏បានផ្ដល់ឱកាសដល់យុវជនយុវនារី និងមហាជនទូទៅទាំងនៅក្នុងប្រទេសកម្ពុជា និងនៅតាមបណ្ដាប្រទេសនានាជាងពាន់នាក់កន្លងមកហើយ បានចូលរួមសិក្សាបន្ថែមទៅលើមុខវិជ្ជា ព្រះពុទ្ធសាសនាផ្សេងៗ ផ្សារភ្ជាប់ការបដិបត្តិសមាធិជាក់ស្ដែង និងតាមរយៈការផ្សព្វផ្សាយក្នុងបណ្ដាញសង្គមនានា ព្រមទាំងថ្នាក់សិក្សាមួយចំនួនដែលមានដំណើរការជារៀងរាល់ថ្ងៃ។

**វិទ្យាស្ថានធម្មិកៈអន្តរជាតិ** គឺជាកម្មវិធីអប់រំពុទ្ធសាសនា បែបសម័យទំនើបមួយ ដែលមិនស្វែងរកប្រាក់កម្រៃ ពោលគឺចូលរួមជាធម្មទាន ក្នុងការផ្សព្វផ្សាយ **ព្រះធម៌ អក្សរសាស្ត្រ វប្បធម៌ប្រពៃណី ជាភាសាខ្មែរផង និងអង់គ្លេសផង។** ដទៃពីនេះ វិទ្យាស្ថាន ក៏បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គមជាតិ និងព្រះពុទ្ធសាសនា

តាមរយៈ **កម្មវិធីធម្មិកសង្គហៈ** ដែលមាន៖ **កម្មវិធីលើកទឹកចិត្តពុទ្ធិកអប់រំ បរិស្ថាន អនាម័យ ដាំដើមឈើ បង្រៀនសមាធិ និងកម្មវិធីសប្បុរសធម៌នានា។**

បច្ចុប្បន្ននេះ **វិទ្យាស្ថានធម្មិកៈអន្តរជាតិ** មានបើកថ្នាក់សិក្សាព្រះធម៌ ព្រមទាំងកម្មវិធីផ្សព្វផ្សាយ ផ្សេងៗតាមប្រព័ន្ធអ៊ិនធើណែត **ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ដែលរួមមាន៖**

1. ថ្នាក់ព្រះធម៌ជាភាសាអង់គ្លេស ៤ កម្រិត
2. ថ្នាក់ព្រះធម៌ជាភាសាអង់គ្លេសទូទៅ
3. ថ្នាក់ព្រះអភិធម្ម ៩ បរិច្ឆេទ
4. ថ្នាក់ព្រះសូត្រ
5. ថ្នាក់ភាសាបាលីកម្រិតមូលដ្ឋាន ៣ វគ្គ
6. ថ្នាក់ចិត្តវិទ្យាពុទ្ធសាសនាដើម្បីសុខមាលភាពជីវិត
7. ថ្នាក់សិក្សាធម៌សូត្រ
8. ថ្នាក់សមាធិអប់រំចិត្ត
9. កម្មវិធីធម្មសប្បាយ (Q & A)
10. កម្មវិធីធម្មសន្ទនាធម្មិកជីវិត ភាសាខ្មែរ និងអង់គ្លេស

**សម្រាប់ពត៌មានបន្ថែម៖**

| | |
|---|---|
| Email: | dhammikaacademy@gmail.com |
| Website: | www.dhammikalife.org |
| Telegram Channel: | *វិទ្យាស្ថានធម្មិកៈអន្តរជាតិ DAI-official* |
| Youtube Channel: | *Dhammika Academy International* |
| Facebook Page: | *មូលនិធិធម្មិកជីវិត Dhammika Life Foundation* |
| Facebook Group: | *វិទ្យាស្ថានធម្មិកៈអន្តរជាតិ Dhammika Academy International* |

# Dhammika Academy International (DAI)

**Dhammika Academy International (DAI)** is currently a popular online learning platform and one of the main projects under the umbrella of the **Dhammika Life Foundation (DLF)** among many others that have played role in part of our equitable society inclusively locating in Seattle, State of Washington, United States of America which officially established in 2020 by a group of monks and lay devotees that have shared the same passion and vision, found and led by **Venerable Munīputto Sok Theavy**, who currently resides at **Wat Khmer Hawaii Buddharam** in the **State of Hawaii**, Big Island. **DLF** is also registered and recognized by the Secretary of State in the **State of Washington** as a non-profit charitable entity.

The primary objective of Dhammika Academy International is as follow:

• To forge and reinforce creating opportunity among the native Khmer language speakers, ordained monks, laypeople, and other non-Khmer speakers alike. This approach can enrich their skills & knowledge, fluency, and deeper understanding “the teaching of the Buddha.

• **Dhammika Academy International** aims at offering the Buddha’s teaching classes that aligned with modern way of life and today’s technological advancement. Furthermore, it is not seeking any profit in general and mainly sustains its longevity by abundance of compassionate community volunteering folks along with public and private generosity.

• **DAI** has been directly engaged in tutoring and teaching of the Dhamma, Pāli Studies, English and Khmer literature part of its academic curriculum

throughout Cambodia and several other foreign countries via online and social media platforms live daily.

In addition, **DAI** has also been part of the Dhamma training program for many Cambodian monks and laypeople who like to strengthen their knowledge of Dhamma in English medium for the sake of oversea propagation.

Since the opening regardless of facing many obstacles and challenges, DAI has been a source of a significant gateway engaging in the social function activities among the communities back home and locally, proved to be a positive impact in transforming and lives changing among the youth and senior communities with today's ever-changing world.

Those subsequent programs include, **Dhammika Saṅgaha** that mainly tailored to cultivation and development of well-being, loving-kindness, environmental contribution (tree planting, environmental clean-up, humanitarian fundraising efforts for Children Hospital in Cambodia**), teaching mindfulness meditation, and Dhammika International Library** project being run in Cambodia.

Following is the list of some programs that have been successfully launched out and completed along with the new programs of 2023 being launch out as follows:

1. Buddhism in English level 4
2. Buddhism in English for All
3. Abhidhamma 9 Chapters
4. Pali Chanting Class
5. The Fundamental of Pali Language
6. Buddhist Psychology for Well-being
7. Sutta Pitaka class
8. Mindfulness Meditation Course
9. Abhidhamma Q&A course
10. DhammikaLife DhammaSandanā, the Dhamma discussion program hosts in Khmer and English every Friday

**<u>For more information about DAI:</u>**

Email: dhammikaacademy@gmail.com

Website: www.dhammikalife.org

Telegram Channel: *វិទ្យាស្ថានធម្មិកៈអន្តរជាតិ DAI-official*

Youtube Channel: *Dhammika Academy International*

Facebook Page: *មូលនិធិធម្មិកជីវិត Dhammika Life Foundation*

Facebook Group: *វិទ្យាស្ថានធម្មិកៈអន្តរជាតិ Dhammika Academy International*

**បរិយត្តិ បដិបត្តិ បដិវេធ**

Pariyatti Paṭipatti Paṭivedha

ការផ្សាយរបស់វិទ្យាស្ថានធម្មិកៈអន្តរជាតិ

# សីល សមាធិ បញ្ញា

## Virtue Concentration Wisdom

"ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថៈ
ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារ
ទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឲ្យសម្រេច
ដោយសេចក្តីមិនប្រមាទចុះ ។
អយំ តថាគតស្ស បច្ឆិមា វាចាៈ នេះជាបច្ឆិមវាចារបស់តថាគត ។"

"Handadāni bhikkhave āmantayāmi vo vayadhammā saṅkhārā appamādena sampādetha ". " Behold now, O monks, I exhort you: impermanent are all compounded things. Work out your deliverance with mindfulness."

Ayaṃ tathāgatassa pacchimā vācā: This is the last word of the Buddha.

មហាបរិនិព្វានសូត្រ Mahāparinibbāna Sutta

សម្រាប់ជាធម្មទានតែប៉ុណ្ណោះ

For Free Distribution Only

9 789924 940616

គាំទ្រដោយៈ មូលនិធិធម្មិកជីវិត